ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ១០០ឆ្នាំក្រោយមក ៖ ទិវាអន្តរជាតិដំបូងបំផុតដើម្បីរំឭកអំពីជនរងគ្រោះ

◆ យុត្តិធម៌អន្តរកាលតាមរយៈការស្តាប់សំឡេងស្ត្រីកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៩២ ខែធ្នូ ឆ្នាំ២០១៥

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៩២ ខែធ្នូ ឆ្នាំ២០១៥


## មាតិកា


◆១០០ឆ្នាំក្រោយមក ៖ ទិវាអន្តរជាតិដំបូងបំផុត ..................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព ម៉ក់ វ៉ន ហៅ រី ប្រធានបច្ចេកទេស ..................២

◆ បេក្ខជាកសាងសង្គមនិយមឲ្យបានលោតផ្លោះតាមមាគ៌ារបស់បក្ស ..................៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ នឹកស្មានមិនដល់ថានៅរស់ជីវិត ..................៧

◆ ៣០ឆ្នាំក្រោយមក ទើបដឹងឈ្មោះអ្នកថតរូបពីរសន្លឹក..................១៤

◆ ជូ យ៉ន អតីតប្រធានកងចល័ត ..................១៦

◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ..................១៨

◆ ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី ..................២៣

**ផ្នែកច្បាប់**

◆ យុត្តិធម៌អន្តរកាលតាមរយៈការស្តាប់សំឡេងស្ត្រីកម្ពុជា ..................៤០

◆ សេចក្តីថ្លែងការណ៍ ទាក់ទងនឹងសំណុំរឿង០០៣ ..................៤៦

◆ សេចក្តីថ្លែងការណ៍ ទាក់ទងនឹងសំណុំរឿង០០៤ ..................៤៨

**វេទិកាពិភាក្សាសាធារណៈ**

◆ ការពិភាក្សាលើការដាក់ភ័ស្តុតាងបន្ថែម ..................៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ រសាត់តាមខ្យល់ ..................៥២




ស្តូបរំឭកវិញ្ញាណក្ខន្ធ នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៖ វ៉ាន់ថាន់ ពៅដារ៉ា, អេង កុកថាយ, បេនី យេ, ឌី សុជាតា, ប៉ុក ប៊ុនសូម៉ាដ ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ ទាវ សារៈមុនិន្ទ ***អ្នកបកប្រែ*** ៖ សុភ័ក្រ្ត ភាណា ***និពន្ធនាយកខ្ទង់*** ៖ ឆាំង យុ និង ញាណ សុជាតិ ***ជំនួយការនិពន្ធនាយក*** ៖ សោម ប៊ុនថន ***ក្រាហ្វិកកុំព្យូទ័រ*** ៖ សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ*** ៖ ឆេង វើង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ១០០ឆ្នាំក្រោយមក ៖ ទិវាអន្តរជាតិដំបូងបំផុត ដើម្បីរំឭកអំពីជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ អង្គការសហប្រជាជាតិបានប្រារព្ធនូវទិវាអន្តរជាតិដំបូងបំផុតដើម្បីរំលឹកអំពីជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ។ អនុសញ្ញាស្តីពីការទប់ស្កាត់ និងការផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលត្រូវបានចុះហត្ថលេខាអនុម័តនៅថ្ងៃដដែល ក្នុងឆ្នាំ១៩៤៨ លន់តួសុំដល់អង្គការសហប្រជាជាតិ និងពិភពលោកឲ្យអនុវត្ត ។ ជាង១០០ឆ្នាំកន្លងមក ប្រជាជនអាមេនាន រងទុក្ខជាទម្ងន់នៅក្រោមចក្រភពអូតូម៉ង់ ទួគី ។ ចាប់តាំងពីមានអំពើប្រល័យពូជសាសន៍នេះមក ហើយដែលនៅតែមានកង្វះការទទួលស្គាល់ពីពិភពលោកសព្វថ្ងៃ យើងបានដឹងថា អំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅទ្រង់ទ្រាយធំនៅតែកើតមានម្តងហើយម្តងទៀត ។ នៅពេលដែលសកម្មភាពអស់ទាំងនេះត្រូវបានដឹងឮ យើងបានដាក់ចេញនូវការប្រកាស ដំណោះស្រាយ និងអនុសញ្ញាអន្តរជាតិ ក៏ប៉ុន្តែ យើងនៅតែឯាយរងគ្រោះពីសកម្មភាពប្រល័យពូជសាសន៍ដែលកើតមានបន្ថែមទៀត ។

អំពើឃោរឃៅទ្រង់ទ្រាយធំ មិនត្រូវបានដាក់កំហិតលើតែក្រុមសាសនា វប្បធម៌ ឬការអនុវត្តនយោបាយជាក់លាក់ណាមួយនោះទេ ។ វាគឺជាជំងឺមួយប្រភេទ ដែលញាំញីលើមនុស្សគ្រប់រូប ដូចដែលប្រជាជនកម្ពុជាបានដឹងយ៉ាងច្បាស់ណាស់ ។ យើងក៏បានចែករំលែកនូវប្រវត្តិសាស្ត្ររួមនៃអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅដែរ ។ យើងក៏បានទទួលរងនូវការញាំញីនេះដែរ ។ យើងត្រូវតែទទួលស្គាល់ថា ការប្តេជ្ញារបស់យើងក្នុងការបញ្ចប់នូវអំពើប្រល័យពូជសាសន៍ មិនត្រឹមតែធ្វើឡើងតាមរយៈពាក្យសម្តី ឬទិវារំឭកទេ ក៏ប៉ុន្តែគឺជាសកម្មភាពទាំងឡាយណាដែលប្រព្រឹត្តទៅដោយយូរអង្វែង ។ ការទទួលស្គាល់នូវបរាជ័យរបស់យើងក្នុងការលុបបំបាត់អំពើប្រល័យពូជសាសន៍ អាចនឹងជាជំហានដំបូងដើម្បីទទួលស្គាល់ថា យើងត្រូវតែទទួលយកនូវការទទួលខុសត្រូវសម្រាប់ប្រជាជនជារួមរបស់យើងដោយដាក់ចេញនូវសកម្មភាពប្រឆាំងនឹងជំងឺនេះ ។

យើងនឹងមិនអាចដោះស្រាយនូវបញ្ហានៃអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅ ដែលត្រូវបានឲ្យនិយមន័យដោយពិភពលោករបស់យើងនាពេលបច្ចុប្បន្ន ឬអាចនឹងមិនមាននូវថ្នាំព្យាបាលភ្លាមៗទេ ក៏ប៉ុន្តែ យើងអាចដាក់ចេញសកម្មភាពក្នុងពេលបច្ចុប្បន្ន ដែលនឹងធ្វើឲ្យមានភាពកាន់តែល្អទៀតនាពេលអនាគត ។ ការអប់រំគឺជាយន្តការដ៏ចាំបាច់មួយ ។ វាអាចបំផុសនូវគំនិតរបស់មនុស្សជំនាន់ថ្មី និងបញ្ចូលកម្លាំងរបស់យុវជនទៅក្នុងកិច្ចខិតខំប្រឹងប្រែងយ៉ាងប្តូរផ្តាច់ ដែលអាចលើកកម្ពស់សន្តិភាព និងផ្តល់តម្លៃដល់កិត្តិសព្ទនៃបុគ្គលមួយរូបៗ និងភាពខុសប្លែកគ្នារវាងបុគ្គលនីមួយៗ ។ ការអប់រំមិនអាចដោះស្រាយនូវបញ្ហាទាំងអស់នៃស្ថានភាពមនុស្សទេ ក៏ប៉ុន្តែវាអាចជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយដែលផ្តើមនូវបំលាស់ប្តូរនៃចរិតមនុស្សនាថ្ងៃអនាគត ។ **ឆាំង យុ**



អដ្ឋិធាតុជនរងគ្រោះដោយរបបខ្មែរក្រហម នៅវាលពិឃាតបឹងជើងឯក

# ចម្លើយសារភាព ម៉ក់ រ៉ន ហៅ រី ប្រធានបច្ចេកទេសវះកាត់ពេទ្យ ៣-១៧

***ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D២១២៦៨***

*ម៉ក់ រ៉ន ហៅ រី ភេទស្រី អាយុ២៨ឆ្នាំ កើតនៅភូមិតាប៉ាង ឃុំសំរោងលើ ស្រុកខដុត្ត ភូមិភាគបស្ចិម ។ រី ជាអតីតប្រធានបច្ចេកទេសផ្នែកវះកាត់នៅពេទ្យព-១៧ ។ រី ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃ២៥ ខែតុលា ឆ្នាំ១៩៧៨ និងបានបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ ដើម្បីសួរចម្លើយ ។ ឯកសារចម្លើយសារភាពរបស់ រី ត្រូវបានវាយអង្គុលីលេខដែលមានកម្រាស់២៨ទំព័រ ដោយសាមីខ្លួនបានឆ្លើយសារភាពពីប្រវត្តិ និងសកម្មភាពរបស់ខ្លួន តាំងពីនៅតូចរហូតចូលធ្វើបដិវត្តន៍ និងសកម្មភាពផ្សេងៗជាច្រើនទៀត ដែលបានធ្វើជាបន្តបន្ទាប់ជាមួយបក្ខពួកនៅក្នុងមន្ទីរពេទ្យព-១៧ ដើម្បីប្រឆាំងបដិវត្តន៍ខ្មែរក្រហម ។ យើងមិនដឹងថា ការឆ្លើយសារភាពរបស់ រី ពិតប្រាកដយ៉ាងណានោះទេ ព្រោះគាត់ត្រូវរងនូវទារុណកម្មពីសំណាក់អ្នកសួរចម្លើយ ។ ខាងក្រោមនេះ ជាសេចក្តីដកស្រង់ដោយសង្ខេបពីប្រវត្តិនិងសកម្មភាពនៅក្នុងចម្លើយសារភាពរបស់ រីៈ*

*នៅពេលអាយុបាន១០ឆ្នាំ រី បានចូលរៀននៅវត្តត្នោតពង បានត្រឹមថ្នាក់ទី១០ ។ នៅពេលអាយុ១៨ឆ្នាំ រី បានឈប់រៀន ហើយទៅរស់នៅនិងប្រកបរបររកស៊ីជាមួយឪពុកម្តាយនៅឯខេត្តពោធិ៍សាត់ តាមរយៈបងប្រុស ឈ្មោះ សៀ ។ នៅពេលនោះ រី បានខូចសីលធម៌ជាមួយឈ្មោះ រស់ ដែលត្រូវជាសាច់ញាតិរបស់ខ្លួន ។ ក្រោយមក នៅចុងឆ្នាំ១៩៦៩ ឪពុកម្តាយរបស់ រី បានវិល*




*គិលានដ្ឋានដែលត្រូវបានបោះបង់ចោលនៅក្នុងរបបខ្មែរក្រហម*

ត្រឡប់មកស្រុកកំណើតវិញ ។ ចំណែក រី និងបងប្រុសម្នាក់ទៀតឈ្មោះ នឿន បានដើររាំច្រៀងក្នុងពិធីបុណ្យ ឬពិធីមង្គលការផ្សេងៗ ដើម្បីយកប្រាក់មកចិញ្ចឹមជីវិត ។

ខែសីហា ឆ្នាំ១៩៧១ រី និងបងប្រុសឈ្មោះ នឿន បានចូលបដិវត្តន៍តាមរយៈ តាភិន នៅឃុំបឃុំសំរោងលើ ។ បន្ទាប់ពីចូលបដិវត្តន៍ហើយ ទាំងពីរនាក់បងប្អូនបានមកនៅភូមិតាកែវអស់រយៈពេល៥ខែ ។ ក្រោយមកបានមកនៅមន្ទីរ៣០៥ ភូមិភាគពិសេស ។ រី បានរៀបរាប់ថា នៅពេលមកនៅមន្ទីរ៣០៥ បងនឿន បានធ្វើការទាក់ទងជាមួយ មឿន, នារីហ៊ាង, នារីរ៉ុម និងបានជួបប្រជុំគ្នាញឹកញាប់ណាស់តែមិនដឹងថា បងនឿន ប្រជុំពិភាក្សាគ្នាពីរឿងអីនោះទេ ។ ជាបន្តបន្ទាប់មកទៀត នឿន បានអប់រំ រី មិនឲ្យធ្វើការច្រើនពេកហើយ នៅមន្ទីរភាគពិសេស៣០៥ នឿន តែងដើរស្តីដេរឲ្យគេឯងជាហូរហែ និងធ្វើឲ្យកើតមានទំនាស់ទៀតផង ។

នៅខែកុម្ភៈ ឆ្នាំ១៩៧២ រី បានចូលធ្វើជាបុគ្គលិកពេទ្យនៅមន្ទីរពេទ្យព-២៧ ភូមិភាគពិសេស ចំណែក នឿន ក៏បានចេញទៅខាងយោធាដែរ ។

នៅខែឧសភា ឆ្នាំ១៩៧៤ រី និង នារីធឿន ត្រូវបាន នារីសាវ៉ាត អប់រំឲ្យចូលក្នុងខ្សែក្បត់របស់ខ្លួន នៅពេលដែលអ្នកទាំងបីទៅរកអុសនៅក្នុងព្រៃ ។ បន្ទាប់ពីអប់រំហើយ សាវ៉ាត បានចាត់តាំងឲ្យអ្នកទាំងពីរបង្កប់ខ្លួន នៅក្នុងមន្ទីរពេទ្យព-២៧ និងបានណែនាំឲ្យទាក់ទងជាមួយនារីវ៉ាន ប្រធានផ្នែកពិសោធន៍ និងឃ្លាំងឈាមព-១៧, នារីថេន ប្រធានផ្នែកជំងឺទូទៅ, ម៉ៅ ប្រធានសេដ្ឋកិច្ចពេទ្យព-២៧, ហុង ប្រធានពេទ្យព-២៧ និងឈ្មោះ ឡា សេដ្ឋកិច្ចពេទ្យព-២៧ ព្រមទាំងដាក់ផែនការឲ្យបំផ្លាញរបស់របរសំខាន់ៗ នៅក្នុងមន្ទីរពេទ្យ បំផុសពីរឿងសីលធម៌ រវាងយុទ្ធជន និងយុទ្ធនារីនៅក្នុងមន្ទីរពេទ្យ និងចាក់ថ្នាំឲ្យយុទ្ធជន និងអ្នកជំងឺផ្សេងៗទៀតអាប់សៃ និងពលី ។ ពេលបើកថ្នាំម្តងៗ ធ្វើឲ្យថ្នាំច្របូកច្របល់ច្រឡំចូលគ្នា ទាំងថ្នាំគ្រាប់ ថ្នាំចាក់ ក៏ដូចជាថ្នាំអំពូល និងបានធ្វើសកម្មភាព ដើរហើរសេរីនៅក្នុងអគ្គភាព ។ រី បានចូលរួមធ្វើសកម្មភាពទាំងនេះជាមួយបក្ខពួកយ៉ាងសកម្ម និងបានខូចសីលធម៌ជាមួយយុទ្ធជនពេទ្យម្នាក់ឈ្មោះ សាន់ ។ ក្រោយមកនៅខែធ្នូ រី ត្រូវបានឈ្មោះ ពឿន ចាត់តាំងឲ្យទៅរៀនបច្ចេកទេសផ្នែកវះកាត់នៅពេទ្យព-២៨ ។

ក្រោយរំដោះថ្ងៃ១៧ មេសា ១៩៧៥ រី បានមកធ្វើចម្ការនៅមន្ទីរពេទ្យព-១៧ អស់រយៈពេលមួយខែកន្លះ ។ បន្ទាប់មកបានមកនៅខាងផ្នែកវះកាត់ ហើយបានទាក់ទងភ្ជាប់ខ្សែជាមួយ សាវ៉ាត វិញនៅពេទ្យព-១៧ ។ នៅពេលនោះដែរ សាវ៉ាត បានណែនាំ រី, ធឿន, ថេន និង វ៉ាន ឲ្យបន្តធ្វើសកម្មភាពនៅក្នុងមន្ទីរពេទ្យតទៅទៀត និងបានដាក់ផែនការមួយចំនួនឲ្យអនុវត្ត គឺបំផ្លាញជីវិតអ្នកជំងឺដែលមកសម្រាកនៅក្នុងមន្ទីរពេទ្យ បំផ្លាញរបស់របររួមតាំងពីសឺរ៉ាំង ម្ជុលចាក់ថ្នាំ និងសម្ភារផ្សេងៗទៀត និងបំផុសឲ្យកើតមានទំនាស់រវាងអ្នកជំងឺ និងបុគ្គលិកពេទ្យធ្វើឲ្យមានសភាពច្របូកច្របល់ ។ ក្រោយពីទទួលបានការណែនាំពី សាវ៉ាតរួចមក រី បានធ្វើឲ្យបែកសឺរ៉ាំងអស់៥ បំផ្លាញទុយយោសេរ៉ូមអស់ចំនួន១០០ មិនតែប៉ុណ្ណោះ រី បានបង្កឲ្យមានទំនាស់ជាមួយអ្នកជំងឺនៅក្នុងមន្ទីរពេទ្យទៀត ។ នៅពេលចាក់បន្តោកសេរ៉ូមឲ្យអ្នកជំងឺ រី បានបាញ់ទឹកបញ្ចូលក្នុងសេរ៉ូម ចាក់ឲ្យអ្នកជំងឺ ធ្វើឲ្យអ្នកជំងឺស្លាប់ម្នាក់ ។ ក្រោយមក សាវ៉ាត បានណែនាំ រី ឲ្យស្គាល់ខ្សែរយៈដឹកនាំនៅក្នុងមន្ទីរពេទ្យមានឈ្មោះនារី សី គណៈមន្ទីរពេទ្យព-១៧, សាត ទទួលអ្នកជំងឺទូទៅពេទ្យព-១៧, នារី យន ទទួលខុសត្រូវលើនារីពេទ្យ ព-១៧, នារី ផន ប្រពន្ធ សាត, ម៉ៅ ប្រធានសេដ្ឋកិច្ច, ហុង ទទួលខុសត្រូវ ផ្នែកយុទ្ធជនពេទ្យ ព-១៧ ។

នៅខែមករា ឆ្នាំ១៩៧៦ សាវ៉ាត បានណែនាំ រី ឲ្យស្គាល់កម្លាំងនៅក្នុងផ្នែកវះកាត់ថែមទៀតមានឈ្មោះ នារី វន, សឿន (ចាប់ខ្លួនហើយ), សយ (ចាប់ខ្លួនហើយ), ហន (ចាប់ខ្លួនហើយ), នារី វ៉ាន់ (ចាប់ខ្លួនហើយ), នារី ភាព (ចាប់ខ្លួនហើយ), ណាំ (ចាប់ខ្លួនហើយ), ហេង (ចាប់ខ្លួនហើយ), ដាត (ចាប់ខ្លួនហើយ), នារីភារុន (ចាប់ខ្លួនហើយ), នារី ផាន (ចាប់ខ្លួនហើយ), និង នារី ឃួន ហើយបានប្រគល់កម្លាំងទាំងប៉ុន្មានខាងលើឲ្យមកនារី វន ជាអ្នកទទួលខុសត្រូវជំនួសវិញ ។ ពេលដែលបានទទួលកម្លាំងពី សាវ៉ាត ហើយ វន បានដាក់ផែនការឲ្យអនុវត្ត គឺសម្លាប់យុទ្ធជនពេលកំពុងវះកាត់ ក៏ដូចជាក្រោយពេលវះកាត់រួច គឺត្រូវធ្វើតាមផែនការជាបន្តបន្ទាប់ បើខែនេះធ្វើមិនបាន ខែក្រោយត្រូវធ្វើកិច្ចការនេះបន្តទៀត, បំផ្លាញសម្ភារប្រើប្រាស់រួម ជាពិសេស សម្ភារសម្រាប់វះកាត់ ក្រៅពីនេះត្រូវបំផ្លាញដំណាំដាំដុះផ្សេងៗទៀត, ធ្វើសកម្មភាព

បំផុសអ្នកជំងឺឲ្យខូចសីលធម៌ជាមួយបុគ្គលិកពេទ្យនារីដើម្បីងាយស្រួលអូសទាញកម្លាំង និងបង្កឲ្យមានទំនាស់ក្នុងអង្គភាពជាបន្តបន្ទាប់ ។ ក្រោយពីបានទទួលផែនការពីនារី វ៉ន ហើយ រី និងបក្ខពួកមាន នារីសឿន, នារីសយ, នារីណាំ, នារីឃួន, នារីភាព, និងនារី ណា បានរួមគ្នាធ្វើសកម្មភាពបំផ្លាញរបស់របរប្រើប្រាស់ជាបន្តបន្ទាប់ ដូចជា បាំងវះកាត់ដបថ្នាំ និងបានសម្លាប់យុទ្ធជនម្នាក់ឈ្មោះ សឿន មកពីភូមិភាគនិរតី ។

ខែមីនា ឆ្នាំ១៩៧៦ រី បានទាក់ទងជាមួយ ធន គណៈផ្នែកភ្នែក និង ឡេន គណៈផ្នែកធ្មេញ ។ តាមការប្រាប់ឲ្យដឹងពី សាវ៉ាត ថាអ្នកទាំងពីរបានខូចសីលធម៌ជាមួយនារី យន ហើយត្រូវបាន នារី យន កសាងបាននៅឆ្នាំ១៩៧៦ ។ ក្រោយពីទាក់ទងគ្នាហើយ រី បានណែនាំឲ្យអ្នកទាំងពីរបន្តធ្វើសកម្មភាពរបស់ខ្លួនតទៅទៀត គឺនៅពេលដែលមានអ្នកជំងឺចូលមកព្យាបាល ត្រូវធ្វើឲ្យអ្នកជំងឺខូចភ្នែក ខូចធ្មេញតាមដែលអាចធ្វើទៅបាន ។ ក្នុងពេលនោះដែរ រីកសាងកម្លាំងបានពីរនាក់ គឺ នារីសុកលី និង នារីណាវ ដែលជាបុគ្គលិកផ្នែកថ្នាំសន្លប់នៅមន្ទីរពេទ្យព-១៧ ហើយបានដាក់ផែនការឲ្យអនុវត្តគឺត្រូវរកគ្រប់វិធីដើម្បីសម្លាប់យុទ្ធជនបដិវត្តន៍ និងបំផុសបញ្ហាសីលធម៌រវាងយុទ្ធជន-នារី ។ បន្ទាប់ពីទទួលផែនការហើយ ណាវ, សុកលី និង ណា បានបង្កឲ្យមានទំនាស់ជាមួយភ្ញៀវ លួចសម្ភាររបស់ភ្ញៀវ ធ្វើឲ្យខូចនយោបាយរបស់បក្ស អុកឡុករករឿងទំនាស់ជាមួយអ្នកជំងឺ យកម្ជុលចាក់ថ្នាំ និងកាំបិតវះកាត់ទៅបោះចោលអស់ចំនួន៥០ ។

ខែមិថុនា ឆ្នាំ១៩៧៦ ពេលវះកាត់ រី បានធ្វើឲ្យយុទ្ធជននៅភូមិភាគកណ្តាលម្នាក់ឈ្មោះ ឈុំ ស្លាប់ និងបានខូចសីលធម៌ជាមួយយុទ្ធជនឈ្មោះ សឿន ជាហូរហែ ។ ក្រោយមក រី បានធ្វើការទាក់ទងជាមួយកម្លាំងនៅខាងរោងបាយ និងខាងសំណង់ រួមមាន នារីសុខា, វិត, មុត, នារី ដាន និង ឆន ហើយបានណែនាំអ្នកទាំងនោះឲ្យដាក់ថ្នាំបំពុលទៅក្នុងអាហារធ្វើឲ្យយុទ្ធជនពីរនាក់ពុល ។

ខែកុម្ភៈ ឆ្នាំ១៩៧៧ នារី សី ដែលជាគណៈមន្ទីររួម បានហៅកម្លាំងរបស់ខ្លួនមកប្រជុំនៅសាលាត-១២ មានសមាជិកចូលរួមចំនួន២០នាក់ ។ សី បាននិយាយនៅក្នុងអង្គប្រជុំថា នៅឆ្នាំ១៩៧៧-៧៨ នេះ យើងត្រូវបង្កើនខ្សែសន្ទាក់ គឺកសាងកម្លាំងនៅក្នុងមន្ទីររបស់យើង និងកៀងគរកម្លាំងមហាជននៅពេទ្យព-១៧ ឲ្យបានច្រើន ហើយយកមន្ទីរពេទ្យព-១៧ ធ្វើជាមូលដ្ឋានបង្អែករបស់យើងសម្រាប់កសាងកម្លាំងបន្តទៀត ។ សី បានបន្តថា យើងមានផែនការសម្លាប់បងទី១ និងបងទី២ នៅពេលដែលគាត់ទាំងពីរនាក់ដើរមើលក្នុងមន្ទីរពេទ្យទាំងមូល និងផែនការសម្លាប់បងភា បងពឿន និង ដួន ជឿន នៅក្នុងក្រសួង ។ បន្ទាប់មក សី បានណែនាំ ប្រាប់ដល់សមាជិកនៅក្នុងអង្គប្រជុំទាំងអស់ឲ្យបានស្គាល់កម្លាំងដែលជាខ្សែរយៈខាងក្រៅរបស់ខ្លួនជាកម្លាំងផ្អែក យោធានៅក្នុងខ្សែរបស់ ធុច, យ៉ា និង ភីម ដែលជាកម្លាំងបង្អែកដ៏រឹងមាំ នៅក្នុងការអនុវត្តផែនការសម្លាប់បងទី១ និងបងទី២ នៅពេលធ្វើបុណ្យខួបថ្ងៃទី១៧ មេសា និង ថ្ងៃបុណ្យខួបបក្ស ឆ្នាំ១៩៧៧ ។ មិនតែប៉ុណ្ណោះ សី បានលើកពីផែនការសម្លាប់កម្លាំងរបស់បដិវត្តន៍ផ្សេងៗទៀត ដែលមកសម្រាកនៅក្នុងពេទ្យព-១៧ ។


នារីពេទ្យខ្មែរក្រហមផលិតថ្នាំបុរាណ

ខែមីនា ឆ្នាំ១៩៧៧ សី

បានហៅ រី និងកម្លាំងមួយចំនួនទៀតមកជួបជុំគ្នាដើម្បីដាក់ផែនការសម្រាប់អនុវត្ត ។ ផែនការនោះគឺ ទី១) តាមដាននិងសម្លាប់គា ជួន ជឿន និងមិត្ត ពឿន ទី២) បំផុសអំពីសីលធម៌យុទ្ធជន- នារី ដើម្បីងាយស្រួលអូសទាញកម្លាំង ទី៣) បំផ្លាញកម្លាំងយុទ្ធជនបដិវត្តន៍ដែលមានរបួស មកពីសមរភូមិសម្រាកនៅក្នុងមន្ទីរពេទ្យតាមវិធីវះកាត់ និងប្រើប្រាស់ថ្នាំចាក់សម្លាប់ នៅពេលព្យាបាល ទី៤) បំផុសឲ្យយុទ្ធជនដើរលបនារីនៅពេលយប់ ធ្វើឲ្យច្របូកច្របល់នៅក្នុងអង្គភាព ។ បន្ទាប់ពីទទួលបានផែនការពី សី ហើយ រី បានទាក់ទងកម្លាំងមួយចំនួននៅកន្លែងវះកាត់ និងបានធ្វើសកម្មភាពវះកាត់ឲ្យដាច់សរសៃឈាមរបស់អ្នកជំងឺ ធ្វើឲ្យអ្នកជំងឺពលីអស់ម្នាក់ ។ ប្រាំថ្ងៃបន្ទាប់មកទៀត រី បានវះកាត់ធ្វើឲ្យអ្នកជំងឺដែលត្រូវរបួសពោះម្នាក់ស្លាប់ទៀត ។ បន្ទាប់មក រី រួមជាមួយនារីរ៉ាត, សយ យុរីន, នារីណាវ, នារីសុគលី និងនារីភាព បាននាំគ្នាដុតបំផ្លាញដើមក្រូច ចេក ស្វាយ និងដំណាំផ្សេងៗទៀត ហើយបានប្រមូលសម្ភារដែលប្រើប្រាស់ជាប្រចាំនៅក្នុងមន្ទីរពេទ្យយកទៅបោះចោលនៅក្នុងទឹក និងបានបំផុសបញ្ហាសីលធម៌ឲ្យយុទ្ធជននារីទាក់ទងគ្នាទៀតផង ។

ខែកក្កដា ឆ្នាំ១៩៧៧ រី បានធ្វើសកម្មភាពជាមួយបក្ខពួក វះកាត់អ្នករបួសដែលចូលមកសម្រាកនៅក្នុងមន្ទីរពេទ្យ បណ្តាលឲ្យស្លាប់ជាបន្តបន្ទាប់ ។ រី បានបំផុសឲ្យបុគ្គលិកពេទ្យ និងអ្នកជំងឺស្រឡាញ់គ្នា និងខូចសីលធម៌ជាមួយគ្នាជាហូរហែ ។ នៅពេលនោះ រី ក៏បានខូចសីលធម៌ជាមួយយុទ្ធជន សយ យុរីន នៅក្នុងមន្ទីរពេទ្យដែរ ។ នៅខែវិច្ឆិកា អង្គការបានចាប់ខ្លួន នារីសី ។ ដូច្នេះ រី និងបក្ខពួកមួយចំនួនទៀត បានផ្អាកធ្វើសកម្មភាពមួយរយៈ ដោយខ្លាចបែកការណ៍ត្រូវអង្គការចាប់ខ្លួនទៀត ម្យ៉ាងទៀត អង្គការកំពុងតែតាមដានស្វែងរកចាប់ខ្សែរយៈរបស់នារី សី ។

ខែមករា ឆ្នាំ១៩៧៨ ក្រោយពីអង្គការចាប់ នារីសី រួចឈ្មោះ ធុក បានមកដឹកនាំកម្លាំងក្បត់បន្តពី នារីសី ដោយបានហៅសមាជិកឲ្យមកជួបជុំគ្នានៅផ្ទះរបស់គាត់វេលាម៉ោង៨យប់ ។ ពេលជួបជុំគ្នាហើយ ធុក បានលើកឡើងថា កម្លាំងរបស់យើងនៅក្នុងមន្ទីរពេទ្យព-១៧ នៅមានចំនួនតិចតួចនៅឡើយ ដូច្នេះយើងត្រូវបង្កើនកម្លាំង និងខិតខំធ្វើការអូសទាញកម្លាំងនៅគ្រប់ផ្នែកទាំងអស់ឲ្យបានច្រើនថែមទៀត ។ ធុក បានបន្តថា ថ្វីត្បិតយើងនៅមានកម្លាំងតិច តែយើងអាចកសាង និងពង្រីកកម្លាំងរបស់យើងបានថែមទៀត យើងបង្កប់កម្លាំងរបស់យើងនៅខាងក្នុងជួរបក្ស ហើយយើងធ្វើសកម្មភាពបំផ្លាញបក្សជាបន្តបន្ទាប់ ពិសេសបំផ្លាញកម្លាំងកងទ័ពដែលមានរបួសមកសម្រាកនៅពេទ្យនេះដោយវិធីចាក់ថ្នាំសម្លាប់ កាត់ដៃកាត់ជើងកុំឲ្យធ្វើការអីកើត និងបំផ្លាញសម្ភារប្រើប្រាស់ក្នុងមន្ទីរពេទ្យ ។ យើងនៅមានកម្លាំងខាងក្រៅច្រើនលាននាក់ទៀត ទាំងកម្លាំងយួន ទាំងកម្លាំងសូវៀត ដែលចាំជួយយើង មានទាំងរថក្រោះ មានទាំងកាំភ្លើងគ្រប់ធុន ហេតុនេះ បក្សកុម្មុយនីស្តកម្ពុជាមិនឈ្នះយើងទេ យើងវាយបុកតែមួយព្រឹប គឺអាចយកជ័យជម្នះបានហើយ ។ ដូច្នេះ យើងត្រូវត្រៀមកម្លាំងនៅរដូវប្រាំងនេះព្រោះកងទ័ពយើងបុកទម្លុះវាយយកជ័យជម្នះ ក្នុងឆ្នាំ១៩៧៨-៧៩ នេះឲ្យបានដើម្បីយកកម្ពុជាធ្វើជាឈ្នាន់ទៅវាយយកអាស៊ីអាគ្នេយ៍ទៀត ។ ហេតុនេះ មិត្តទាំងអស់គ្នាត្រូវអនុវត្តតាមផែនការរបស់យើងបន្តទៅទៀត គឺ ទី១) ត្រូវបំផ្លាញផ្នែកសេដ្ឋកិច្ច ទី២) ត្រូវបំផ្លាញកម្លាំងបច្ចេកទេសកុំឲ្យរីកចម្រើន បាន ទី៣) ត្រូវខិតខំអូសទាញកម្លាំងមកខាងយើងឲ្យបានច្រើន និងទី៤) ត្រូវធ្វើសកម្មភាពបំបះបំបោរ ឲ្យមានភាពចលាចលនៅក្នុងមន្ទីរពេទ្យព-១៧ ។ ក្រោយពីបានទទួលផែនការហើយ រី បានទៅជួប មិត្តចន នៅខាងផ្នែកឯកទេសឆ្អឹងដើម្បីពិភាក្សាគ្នារកវិធីសម្លាប់អ្នកជំងឺបន្តទៀត ។

## ផែនការរដូវប្រាំង

ខែកញ្ញា ឆ្នាំ១៩៧៨ ធុក បានហៅ រី, ចន និង នារីរ៉ាត់ មកប្រជុំ ។ នៅពេលជួបជុំគ្នាហើយ ធុក បាននិយាយថា មិត្តចន បាននិយាយថា មិត្ត ម៉ី ឈឺពោះវៀនខ្នែង ហើយ មិត្តចន មិនហ៊ានសម្រេចវះកាត់ទេ ព្រោះ បងប៉ែន មិននៅ ។ ពេលនោះ ធុក បានចាត់តាំងឲ្យ ចន និង រី ធ្វើការវះកាត់ខ្នែងពោះវៀនឲ្យ មិត្តម៉ី ព្រោះមិត្តម៉ី កំពុងមានអាការៈចុកខ្លាំង ។ ធុក បាននិយាយថា ឥឡូវនេះខ្ញុំចង់សម្លាប់ មិត្តម៉ី ក្នុងពេលកំពុងធ្វើការវះកាត់ ។ យើងមិនចាំបាច់យកសម្ភារប្រើប្រាស់ទៅចំហុយទេ គឺយកទៅវះកាត់តែម្តងហើយបើអាចធ្វើទៅបាន គឺយកទឹកថ្នាំឡេស៊ុល ទៅលាងឲ្យល្វែយពោះវៀនតែម្តងក៏បានដែរ ។ ពេលវះកាត់ត្រូវទៅធ្វើនៅជាន់ទីពីរព្រោះកន្លែងនោះស្ងាត់ អត់សូវមានមិត្តយើងចេញចូលច្រើនទេ ងាយស្រួលចាក់ថ្នាំសម្លាប់ មិត្តម៉ី ។

បន្ទាប់មក ឌុក បានបន្តទៀតថា ពេលនេះ មិត្តចន វះកាត់ចុះ តែមិនបាច់សម្លាប់ មិត្តម៉ី នៅពេលកំពុងវះកាត់ក៏បាន ខ្ញុំនឹងយកថ្នាំមកឲ្យ មិត្តចន ដើម្បីយកទៅចាក់ មិត្តម៉ី សាកល្បងមើលក្រោយពីធ្វើការវះកាត់ហើយ ព្រោះចង់ដឹងថាថ្នាំនេះមានប្រសិទ្ធភាពយ៉ាងណា ពេលចាក់ឲ្យ មិត្តម៉ី ហើយស្លាប់ឬក៏មិនស្លាប់ ។ ថ្នាំនេះជាប្រភេទថ្នាំពុល ពេលចាក់ទៅធ្វើឲ្យសាច់ដុំកន្ត្រាក់ រឹងថ្គាម ដូចជំងឺតេតាណុស ។ ពេលប្រជុំចប់ រី បានត្រឡប់មកកន្លែងវះកាត់វិញ ។

ក្រោយពីប្រជុំបានមួយថ្ងៃ ទើបធ្វើការវះកាត់ខ្នែងពោះវៀនឲ្យ មិត្តម៉ី ។ ក្នុងពេលវះកាត់ ចន, រី និងបក្ខពួក មិនបានធ្វើសកម្មភាពអ្វីទេ ព្រោះមានភ្ញៀវចិននៅទីនោះដែរ ។ ក្រោយពេលវះកាត់ខ្នែងពោះវៀន មិត្តម៉ី បានពីរថ្ងៃ ទើប ចន ទៅយកថ្នាំពុលពី ឌុក ហើយចាក់សម្លាប់ មិត្តម៉ី តាមផែនការដែលបានគ្រោងទុក គឺចាក់សម្លាប់ មិត្តម៉ី នៅថ្ងៃទីបី បន្ទាប់ពីវះកាត់រួច ។ នៅពេលចាក់ថ្នាំពុលសម្លាប់ មិត្តម៉ី ហើយ ចន បានទៅរាយការណ៍ប្រាប់ ឌុក ។ ពេលនោះ ឌុក បាននិយាយថា បើថ្នាំនេះមានប្រសិទ្ធភាព យើងទុកថ្នាំនេះ ប្រើសម្រាប់ចាក់សម្លាប់បងៗដែលជាអ្នកដឹកនាំ នៅក្នុងមន្ទីរពេទ្យព- ១៧ និងអ្នកដឹកនាំនៅក្នុងក្រសួងសង្គមកិច្ច មាន បង ប៉ែន ដែលជាគណៈបច្ចេកទេសរួម ពេទ្យព- ១៧ សមមិត្ត រ៉េម, សមមិត្ត ដៃ និង បងភា បន្តទៀត ។

ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៧៨ ឌុក បានហៅបក្ខពួកទៅប្រជុំនៅផ្ទះរបស់គាត់ម្តងទៀត នៅម៉ោង៩យប់ ។ សមាជិកដែលបានចូលរួមនៅពេលនោះមានចំនួន១០ នាក់ ។ នៅក្នុងអង្គប្រជុំ ឌុក បានលើកឡើងថា នៅក្នុងរដូវប្រាំងនេះ យួនត្រៀមវាយប្រទេសកម្ពុជាយើងម្តងទៀត បើពិនិត្យមើលកម្លាំងរបស់យើងនៅផ្នែកខាងក្នុងគឺនៅមានចំនួនតិចណាស់ ហេតុនេះយើងវាយយកកម្ពុជាមិនឈ្នះទេ ដូច្នេះមិត្តត្រូវត្រៀមលក្ខណៈ ទី១) ត្រូវអូសទាញកម្លាំងឲ្យបានច្រើនតាមផ្នែកនីមួយៗ ទាំងអ្នកជំងឺសម្រាកពេទ្យ ពិសេស ប្រជាជន និង បុគ្គលិកពេទ្យ នៅតាមមន្ទីរ ក្រសួងផ្សេងៗ ហើយពេលអូសទាញកម្លាំងបានហើយ ត្រូវបំពាក់គោលជំហរឲ្យ គេធ្វើសកម្មភាពបំផុសបំផុល ធ្វើឲ្យច្របូកច្របល់ និងបំផ្លាញសម្ភារពេលព្យាបាល និងត្រូវធ្វើឲ្យកើតមានទំនាស់ជាមួយអ្នកជំងឺ ។ ទី២) ត្រូវធ្វើសកម្មភាពបំផ្លាញផ្នែកសេដ្ឋកិច្ច ស្បៀងអាហារ ស្រូវអង្ករ អំបិល ប្រហុក ធ្វើឲ្យមានការខ្វះខាតចំពោះអ្នកជំងឺ ។ ទី៣) ត្រូវបំផ្លាញកម្លាំងអ្នកដឹកនាំ និងបំផ្លាញកម្លាំងផ្នែកបច្ចេកទេសគ្រប់ផ្នែកទាំងអស់នៅក្នុងមន្ទីរពេទ្យព- ១៧ និងនៅក្នុងក្រសួងសង្គមកិច្ចទាំងមូល ។

ឌុក បានរៀបចំដាក់ផែនការសម្លាប់កម្មាភិបាលបដិវត្តន៍មានដូចជា ប៉ែន, រ៉េម និង ដៃ ។ ដើម្បីអនុវត្តផែនការនេះ ឌុក បានចាត់តាំង នារីនី និង នារីគីម ឲ្យធ្វើកិច្ចការនេះ ព្រោះអ្នកទាំងពីរទទួលខុសត្រូវក្នុងការព្យាបាលជំងឺឲ្យកម្មាភិបាលទាំងអស់នៅក្នុងពេទ្យព- ១៧ ។ ឌុក បានចាត់តាំងកម្លាំងមួយក្រុមទៀតមាន ឡេន, វ៉ុត, មុត និង វ៉ាត ឲ្យសហការគ្នាដើម្បីជួយធ្វើសកម្មភាពជាមួយ នារីនី និង នារីគីម និងតាមដាន រាល់សកម្មភាពរបស់ ប៉ែន, រ៉េម និង ដៃ ឲ្យបានជាប់ បើមានឱកាសត្រូវសម្លាប់ចោលតែម្តង ។ ឌុក នៅបានចាត់តាំងកម្លាំងមួយផ្នែកទៀតសម្រាប់ធ្វើសកម្មភាពនៅក្នុងផ្នែកវះកាត់ គឺមាន នារីសុកលី, នារីណាវ, នារីណា, នារីមុំ និង នារីវន ។ ផ្នែកនេះ ឌុក បានណែនាំឲ្យទាំងអស់គ្នាត្រៀមកម្លាំងធ្វើសកម្មភាពនៅពេលយួនវាយបុកពីខាងក្រៅខ្លាំង កម្លាំងបដិវត្តន៍នឹងមានអ្នករងរបួសច្រើនចូលមកសម្រាកនៅក្នុងមន្ទីរពេទ្យ ។ មិត្តទាំងអស់គ្នាត្រូវធ្វើយ៉ាងណាឲ្យមានភាពយឺតយ៉ាវក្នុងការជួយសង្គ្រោះអ្នករបួសជាពិសេស ពេលដែលអ្នករបួសធ្ងន់ៗចូល មកច្រើន ដូចជា របួសពោះ របួសក្បាល របួសដាច់ដៃ ដាច់ជើង ដែលត្រូវជួយសង្គ្រោះបន្ទាន់ភ្លាមៗនោះ ត្រូវរកវិធីពន្យារពេល ដើម្បីឲ្យអ្នកជំងឺឈឺចុកចាប់រហូតដល់ស្លាប់ ។ រីឯ ឌុក ខ្លួនឯងផ្ទាល់ រួមជាមួយ មិត្តនារីនី ត្រូវធ្វើសកម្មភាពនៅក្នុងក្រសួងសង្គមកិច្ច គឺសម្លាប់ មិត្តភា ដោយប្រើថ្នាំពុលយកមកលាយជាមួយទឹកដូចឲ្យផឹក ។ បើធ្វើបែបនេះមិនបានសម្រេចទេ ត្រូវប្រើមធ្យោបាយផ្សេងទៀតគឺយកថ្នាំពុលនេះចាក់តាមសរសៃឈាម ឬចាក់តាមសាច់ដុំនៅពេលដែលគាត់មានជំងឺមកឲ្យពេទ្យព្យាបាល ។ ពេលសម្លាប់ មិត្តភា បាន នោះយើង នឹងមានភាពងាយស្រួលបំផុត ក្នុងការអូសទាញកម្លាំងអ្នកដឹកនាំផ្សេងៗនៅក្នុងក្រសួងឲ្យចូលមកខាងយើង ។ ក្រោយពេលប្រជុំហើយ រី បានទៅលេងផ្ទះចំនួន៧ថ្ងៃ ហើយពេលវិលត្រឡប់មកដល់អង្គភាពវិញ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៨ ក៏ត្រូវបានអង្គការចាប់ខ្លួនតែម្តង ។ **ឆេង ឡេង**

# រៀបចំកសាងសង្គមនិយមឱ្យបានលោតផ្លោះ តាមមាគ៌ារបស់បក្ស ដោយផ្អែកលើកសិកម្មជាមូលដ្ឋាន

*ដកស្រង់ចេញពីឯកសារទង់បដិវត្តន៍លេខ៨ ខែសីហា ឆ្នាំ១៩៧៦*

យើងចង់កសាងសង្គមនិយមឲ្យបានឆាប់រហ័ស ។ យើងត្រូវបង្កបង្កើតលក្ខណៈសម្បត្តិឲ្យលោតផ្លោះ ។ ដូច្នេះយើងត្រូវពិនិត្យពិសោធរបស់យើងជាបន្តបន្ទាប់ សរុបពិសោធរបស់យើងជាបន្តបន្ទាប់ ដើម្បីបង្កបង្កើតលក្ខណៈសម្បត្តិថ្មី ជាបន្តបន្ទាប់ និងពង្រឹងជំនឿរបស់យើងជាបន្តបន្ទាប់ ។

តើយើងមានលក្ខណៈសម្បត្តិអីខ្លះហើយ? តើមានអីជាលំបាក មានអីជាការងាយស្រួល ដែលអាចឲ្យយើងឈានទៅមុខបាន? សភាពការណ៍អត្តនោម័តិយើង និងកិត្យានុមតិយើងយ៉ាងម៉េច? បើយើងក្តាប់សភាពការណ៍យើងបានច្បាស់លាស់ យើងនឹងលើកទិសដៅក៏បានច្បាស់លាស់ ហើយយើងក៏នឹងមានជំនឿកាន់តែមុតមាំ ។

យើងចាប់ផ្តើមស្តារសេដ្ឋកិច្ចរបស់យើងពីចុង៧៥ និងដើម៧៦នេះ ។ រយៈពេលនេះខ្លីណាស់ ។ ក្នុងសភាពការណ៍នេះ យើងមានការស្រួល និងលំបាកដូចតទៅ៖

***ការងាយស្រួល៖***

◆ ទី១ កត្តាសង្គម ៖ សង្គមយើង ជាសង្គមសមូហភាពជា



យុវនារីសហករណ៍ នៅស្រុកកៀនស្វាយ បេះល្ហុងយកទៅឧត្តមការដ្ឋានធ្វើស្រូវប្រាំង និងយកទៅឧត្តមកងទ័ពបដិវត្តន៍ នៅសមរភូមិមុខ

ទូទៅ ហើយយើងកំពុងបន្តបដិវត្តន៍របស់យើងតទៅទៀត ។ យើងមិនមែនរៀបចំលក្ខណៈសម្បត្តិដើម្បីបញ្ចប់បដិវត្តន៍ប្រជាធិបតេយ្យប្រជាជនទេ ។ យើងក៏មិនមែនរៀបចំលក្ខណៈសម្បត្តិសម្រាប់ផ្តើមឈានទៅសង្គមនិយមដែរ ។ តាមពិតសង្គមយើងជាសង្គមនិយមទៅហើយ ទាំងនៅជនបទ ទាំងនៅទីក្រុង ។ ក្នុងសង្គមយើងសព្វថ្ងៃ យើងឃើញមានការទាក់ទងផលិតកម្មជាការទាក់ទងថ្មីសមូហភាពមានលក្ខណៈរឹងប៉ឹងមួយកម្រិតហើយ មិនមែននៅមានលក្ខណៈជិះជាន់នៃសង្គមចាស់ទេ ។ ដោយការទាក់ទងថ្មីល្អ កម្លាំងផលិតកម្មថ្មីក៏ល្អ ។ កម្លាំងផលិតកម្មទាំងអស់ គឺសមូហភាព ។ យើងចាត់ចែងកម្លាំងមនុស្ស គោ-ក្របី ឧបករណ៍យ៉ាងម៉េចក៏បាន ។

នេះជាសភាពការណ៍ល្អជាមូលដ្ឋានរបស់យើង ។ ដូច្នេះយើងបានលោតផ្លោះ ពីសង្គមអាណានិគមថ្មីរបស់ចក្រពត្តិអាមេរិករបស់វណ្ណៈសក្តិភូមិ និងនាយទុនគ្រប់ប្រភេទ មកដល់សង្គមសង្គមនិយមតែម្តង ។ សភាពការណ៍នេះ ប្រៀបធៀបនឹងប្រទេសគេ គឺខុសពីគេស្រឡះ ។ នៅប្រទេសគេ ក្រោយរំដោះទូទាំងប្រទេសហើយ គេរៀបចំបញ្ចប់បដិវត្តន៍ប្រជាធិបតេយ្យប្រជាជនសិនហើយរៀបចំកែប្រែសង្គមនិយមបណ្តើរៗទៀត ។ គេត្រូវការរយៈឆ្លងកាត់មួយយូរ ។

ឯយើង យើងមានលក្ខណៈខុសគេ ។ យើងលឿនជាងគេ ។ បើពិនិត្យពីលក្ខណៈសមូហភាព ពីរបបសង្គមនិយម យើងលឿនជាងគេ១០ឆ្នាំ ។ យើងមានការទាក់ទងផលិតកម្មថ្មីអត់អីស្មុគស្មាញដូចគេទេ ។

◆ ទី២ កត្តាបក្សដឹកនាំ ៖ បក្សយើងដាច់ខាត អត់តតាក់តតុប ។ យើងអត់ឆ្លងកាត់បដិរូបដីស្រែ ឬរយៈកាលកែប្រែសង្គមនិយមទេ ។ យើងលោតផ្លោះពីបដិវត្តន៍ប្រជាធិបតេយ្យប្រជាជនមកសង្គមនិយមតែម្តង ។ មាគ៌ាយើងត្រឹមត្រូវ ទាំងយុទ្ធសាស្ត្រទាំងយុទ្ធវិធី ។ បក្សយើងទាំងមូលជ្រួតជ្រាបពីមាគ៌ា ហើយមានពិសោធជាបន្តបន្ទាប់ ។

◆ ទី៣ កត្តាធម្មជាតិ ៖ ខាងដីធ្លី គោក្របី ភោគផលធម្មជាតិប្រភពទឹក ជាបឹង ស្ទឹង ទន្លេ ខ្វាត់ខ្វែង ។ លក្ខណៈធម្មជាតិអនុគ្រោះឲ្យយើងច្រើនណាស់ មិនដូចនៅប្រទេសដទៃទេ ។

***ការលំបាក ៖***

ទន្ទឹមនេះ យើងក៏មានការលំបាកមួយចំនួនដែរ ៖

◆ ទី១ មូលដ្ឋានខាងឧស្សាហកម្មគ្រប់ប្រភេទ ៖

ឧស្សាហកម្មធ្ងន់ ឧស្សាហកម្មស្រាល ពិសេសឧស្សាហកម្មធ្ងន់សឹងតែអត់ ។ ខាងរ៉ែ ខាងថាមពលក៏អត់ ។ មានឧស្សាហកម្មស្រាលបន្តិចបន្តួច ហើយរណបបរទេសខាងវត្ថុធាតុដើមទៀត ។ និយាយមួយម៉ាត់ ឧស្សាហកម្មយើងខ្សោយ ។ ដល់មូលដ្ឋានឧស្សាហកម្មខ្សោយ មូលដ្ឋានបច្ចេកទេសក៏ខ្សោយ ។

ប្រៀបធៀបនឹងគេ យើងខ្សោយជាងគេឆ្ងាយ ខាងឧស្សាហកម្ម ។ ដល់យើងមិនយកអ្នកបច្ចេកទេសចាស់ប្រើទៀត រឹតតែខ្សោយទៀត ។ បើយកអ្នកបច្ចេកទេសចាស់ យើងស្មុគស្មាញច្រើនខាងនយោបាយ ។ បញ្ហានេះក៏នាំឲ្យយើងរឹតតែលំបាកថែមច្រើនជាងទៀត ព្រោះជាបញ្ហានយោបាយ ។

◆ ទី២ យើងគ្មានជំនួយបរទេសមកជួយទេ ៖

ខាងឧស្សាហកម្ម ក៏ដូចជាខាងកសិកម្ម យើងគ្មានជំនួយពីក្រៅទេ ។

និយាយរួម ក្រោយរំដោះ ប្រទេសខ្លះគេមានទុនបរទេសជួយជាច្រើន ។ ចំណែកយើងសព្វថ្ងៃ ជំនួយ មិនមានអីជាធំដុំទេប្រៀបធៀបនឹងប្រទេសដទៃ ។ បញ្ហានេះ ជានយោបាយរបស់បក្សយើង ។ បើយើងសុំជំនួយគេ មុខជាបានខ្លះ តែវាប៉ះពាល់ដល់មាគ៌ានយោបាយរបស់បក្សយើង ព្រោះថា បើសុំគេឲ្យតែច្រើនបន្តិច មុខជាមានលក្ខខណ្ឌខាងនយោបាយពុំខាន ។

◆ ទី៣ ទុនដើម ខាងផលិតផលផ្សេងៗ និងទុនចាស់ជាសេដ្ឋកិច្ច-ហិរញ្ញវត្ថុ របស់យើងក៏តិច ។ លុយចាស់យើងចោលទៀត យើងរឹតតែខ្សត់ថែម ។ មកពីយើងមិនចង់ឲ្យជំពាក់ជំពិនពីរឿងចាស់ ។ យើងមិនចង់ឲ្យមានសល់ទុនចាស់ ។ យើងលើកបញ្ហានេះឡើង ចង់ឲ្យឃើញថា យើងខ្វះទុន ។ បើយើងឲ្យបរទេសចូលទុនមានខ្លះ តែជំពាក់ជំពិនខាងនយោបាយ ។

### យើងឈរលើកសិកម្មជាមូលដ្ឋាន ដើម្បីយកទុនខាងកសិកម្មទៅពង្រីង និងពង្រីកខាងឧស្សាហកម្មទៀត ។

សរុបសេចក្តីទៅ យើងខ្លាំងខាងនយោបាយ ខ្លាំងខាងសមូហភាព ខ្លាំងខាងដីធ្លី ។ តែខ្សោយខាងសម្ភារ ខាងបច្ចេកទេស ។ ក្នុងសភាពការណ៍យ៉ាងនេះ យើងកសាងប្រទេសដោយឯករាជ្យ

ម្ចាស់ការ ខ្លួនទីពឹងខ្លួន បានឆាប់រហ័សឬទេ? ឬមួយយើងត្រូវការជំនួយពីបរទេសឲ្យគេមកជួយយើង? តើយើងទៅរួច ឬមិនរួចដោយខ្លួនយើង ហើយទៅបានរហ័សតាមមាគ៌ាបក្សឬទេ? ។

ក្នុងសភាពការណ៍ទាំងស្រួល ទាំងលំបាក ទូទាត់គ្នាទៅ យើងមានកត្តាងាយស្រួលជាមូលដ្ឋាន ព្រោះកត្តា កំណត់មិនមែនបច្ចេកទេស មិនមែនសម្ភារទេ ។ កត្តាកំណត់នៃបដិវត្តន៍ គឺនយោបាយ គឺមនុស្សបដិវត្តន៍ ។ ឡេនីន ធ្វើបដិវត្តន៍ពីដៃទទេ យើងក៏ដូច្នេះ ។ យើងធ្វើបដិវត្តន៍តាំងពីបាតដៃទទេ ។ តែយើងមានមាគ៌ា មានជំហររឹងប៉ឹង យើងធ្វើបដិវត្តន៍ ហើយយើងវាយខ្លាំងឈ្នះ ។ កសាងប្រទេសខាងសេដ្ឋកិច្ច ក៏ដូច្នេះ ។ សព្វថ្ងៃកម្លាំងបដិវត្តន៍របស់បក្សរបស់ប្រជាជនយើង ជាកម្លាំងខ្លាំងសម្បើម ។ កម្លាំងនេះ នឹងទៅប្រែក្លាយដីធ្លីយើង ដែលជាទុនមួយសំខាន់បំផុត ដើម្បីឲ្យបានផលយ៉ាងឆាប់រហ័ស ។ យើងអាចប្រែក្លាយកសិកម្មយើងបានឆាប់រហ័ស ។ ផ្ទុយទៅវិញ ពិតមែនតែយើងមានកម្លាំងហើយ ពិតមែនតែបក្សយើងខ្លាំង និងប្រជាជនយើងខ្លាំង តែបើយើងវាយខុសទិស នេះចលនាយើងមិនខ្លាំងទេ ។ ឧទាហរណ៍ បើយើងទៅវាយខាងឧស្សាហកម្ម យើងមិនខ្លាំងទេ ព្រោះយើងគ្មានលក្ខណៈសម្បត្តិខាងឧស្សាហកម្ម ។ ដូច្នេះហើយ បានជាយើងវាយខាងកសិកម្ម ព្រោះយើងមានទុនខាងកសិកម្ម ។ តាមសន្ទុះចលនានេះ ឃើញថាយើងវាយបានឆាប់រហ័ស ។ យើងឈរលើមូលដ្ឋាន កសិកម្មជាមូលដ្ឋាន ដើម្បីយកទុនខាងកសិកម្មនេះទៅពង្រីង និងពង្រីកខាងឧស្សាហកម្មទៀត ។ ដូច្នេះ យើងដោះស្រាយទំនាស់របស់យើងខាងឧស្សាហកម្ម ដោយឈរលើទុនយើងខាងកសិកម្ម ។ យើងមិនពង្រឹង និងពង្រីកខាងឧស្សាហកម្ម ដោយទៅសុំជំនួយពីបរទេសទេ ។ ដូច្នេះយើងដោះស្រាយទំនាស់យើងបាន ដោយឈរលើទុនកសិកម្មយើងផង ឈរលើមាគ៌ាឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួនរបស់យើងផង ។

តើយើងធ្វើបានឬមិនបាន? យើងឃើញថាយើងមានលក្ខណៈសម្បត្តិធ្វើបានពេញទី ។ ឆ្នាំ១៩៧៥ យើងធ្វើបាន ។ ៧៦ យើងធ្វើបានទៀត ។ ៧៧ រឹតតែធ្វើបានទៀត ។ នេះនិយាយតែខាងកសិកម្ម ។ ឯខាងឧស្សាហកម្ម ក៏យើងដំណើរការបាន ។ តាមពិសោធរបស់យើង ជាងមួយឆ្នាំកន្លងទៅនេះ ឃើញថាយើងក្តាប់បាន និងគ្រប់គ្រងបាន ។ តទៅមុខ ឲ្យតែយើងមានទុនខាងកសិកម្ម ដើម្បីទៅទិញរោងចក្រ និងទិញម៉ាស៊ីនផ្សេងៗ យើងច្បាស់ជាធ្វើបាន ព្រោះយើងមានមាគ៌ាហើយ ។ ឧទាហរណ៍ រោងចក្រត្រាក់ទ័រ បើយើងមានម៉ាស៊ីនគ្រឿងផ្សេងៗគ្រប់គ្រាន់ យើងច្បាស់ជាធ្វើម៉ាស៊ីនត្រាក់ទ័របាន ។ ឯឧស្សាហកម្មធុនក៏ធ្វើបានឲ្យតែមាន ទុនទិញឡដែក ។ ខាងកៅស៊ូ បើយើងមានទុន យើងអាចទិញម៉ាស៊ីន ឬទិញរោងចក្រយកមកពង្រីកឆ្នៃកែប្រែធ្វើជារបស់ផ្សេងៗទៀតបាន ។ បញ្ហាទាំងនេះ បើយើងទៅសុំជំនួយពីបរទេសមិនងាយទេ ។

និយាយរួម បើយើងមានទុនខាងកសិកម្មច្រើន យើងពង្រឹងនិងពង្រីកឧស្សាហកម្ម យើងបានលឿនដែរ ។ តាមលក្ខណៈសម្បត្តិយើងសព្វថ្ងៃ និងទុនយើងសព្វថ្ងៃ យើងអាចកសាងប្រទេសយើងបាន ហើយយើងកសាងតាមខ្សែសន្ទាក់ តាមផែនការ តាមទិសច្បាស់លាស់ ដោយឯករាជ្យម្ចាស់ការ ។ ទាល់តែធ្វើជាខ្សែសន្ទាក់ជាផែនការ ទើបយើងមានមូលដ្ឋានច្បាស់លាស់ ខាងសេដ្ឋកិច្ច ទើបយើងឯករាជ្យខាងសេដ្ឋកិច្ច ។ ទាល់តែឯករាជ្យខាងសេដ្ឋកិច្ច ទើបយើងឯករាជ្យខាងនយោបាយ ខាងការពារប្រទេសបាន ។

សកលលោកគេមើលយើង ហើយតែងវិភាគយើងតាមទស្សនៈរបស់គេ ។ គេអាចថាយើងឆ្កួត ដោយយើងចោលផលិតករតូចតាច ឬនាយទុនតូចតាច ។ អ្នកខ្លះថាយើងឆ្កួត ហើយអ្នកខ្លះឆ្ងៀតបន្តុះបង្អាប់ ញុះញង់ ចាក់រុកថែមទៀត ។ នេះជាពិសោធមួយថ្មី ពិសោធមួយធំនៅលើសកលលោក ព្រោះយើងមិនធ្វើដូចគេ ។ យើងលោតពីបដិវត្តន៍ប្រជាធិបតេយ្យប្រជាជន មកបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមភ្លាម មិនបាច់រយៈឆ្លងកាត់ ។ ពិសោធនេះថ្មី គេចាំមើលទៀត ។ យើងមិនគម្ពីរនិយម យើងធ្វើតាមសភាពការណ៍ជាក់ស្តែងនៅក្នុងប្រទេសយើង ។

## ប្តេជ្ញាបោះទីតាំងកសិកម្មសម័យ ក្នុងភូមិភាគនីមួយៗ ឲ្យបានក្នុងរយៈពីបី ទៅ៤ឆ្នាំខាងមុខនេះ

បក្សបានកំណត់ជាបន្តបន្ទាប់មក គឺពី១០ ទៅ ១៥ឆ្នាំ ឲ្យកសិកម្មសម័យទូទាំងប្រទេស ។ ក្នុងន័យម្ចាស់ការលើទឹក លើពូជលើដី លើឧបករណ៍ម៉ាស៊ីន ។ យើងចង់បានឲ្យរហ័ស ។ និយាយរួមទូទាំងប្រទេសពី១០ ទៅ ១៥ឆ្នាំ ។ តែនិយាយដោយឡែក តាម

មូលដ្ឋានមួយៗ លក្ខណៈសម្បត្តិជាសត្យានុម័តិ ជាដីធ្លី ទឹក និង លក្ខណៈអត្តនោមតិ ខាងបក្ស ខាងប្រជាជនល្អ ។ ដូច្នេះ កន្លែងខ្លះ ក្នុង៣-៤-៥ឆ្នាំ មូលដ្ឋានខ្លះ តើអាចបានផល៨តោន ៩តោន ១០តោនទេ ដើម្បីយកទុននេះ ទៅដោះស្រាយបញ្ហាទឹកថែមទៀត ដោះស្រាយបញ្ហា ម៉ាស៊ីនថែមទៀត ថ្នាំកសិកម្មថែមទៀត តើបានឬទេ? ឃើញថាធ្វើបាន ។ មួយហិកតាយកផលពី៨ ទៅ១០ តោន ក្នុងទំហំដី មួយម៉ឺន ពីរម៉ឺន បីម៉ឺនហិកតា ធ្វើពីរដងក្នុងមួយឆ្នាំ គឺទៅរួច ។

ឧទាហរណ៍ៈ ជាទូទៅ ដីតំបន់ខាងលើ ជាដីខ្សាយ តែខាងក្រោមពីបីទៅ ប្រាំឆ្នាំ យក៨តោន ទៅ១០តោន ក្នុងមួយហិកតា បានឬមិនបាន ។ គ្រាន់តែឆ្នាំក្រោយ ក្នុងភូមិភាគមួយៗ ដីខាងក្រោម ធ្វើពីរដងយក ៦តោន មិនពិបាកទេ ។ ឆ្នាំ៧៨ បាន៧តោន ឬ៨តោន បានពេញទី ថែមដីថែមអីទៀត ។ ដូច្នេះយើងពេញចិត្តនឹងដំណើរយើង មកដល់នេះលឿនហើយ ។ តែយើងត្រូវខំបង្កបង្កើតជាលក្ខណៈសម្បត្តិ ឈានឲ្យលឿនទៀត ដើម្បីជួយទុន មកខាងផ្នែកដីខាងលើដែលដីមិនល្អ ។ ជួយជាម៉ាស៊ីនដីករែ្រក ម៉ាស៊ីនបូម...។ល ។

ដូច្នេះ ក្នុងភូមិភាគមួយៗ មានកន្លែងខ្លះ មានលទ្ធភាពឈានទៅកសិកម្មសម័យ បានពេញទី ពីរបី ទៅប្រាំ ឆ្នាំទៀត ។ យើងមិនទាន់មានម៉ាស៊ីនទេ តែដីល្អ ទឹកល្អ យើងថែធួនថែមទៀត វាអនុគ្រោះឲ្យយើងឈានទៅ ៨តោន ៩តោន ១០តោន ។ បានទុនយ៉ាងនេះ យើងទិញម៉ាស៊ីនមករៀបចំ នៅកន្លែងដីមិនល្អថែមទៀត ។ បើយើងដំណើរការយ៉ាងនេះ ឆ្នាំ៧៧-៧៨-៧៩ យើងមានទីតាំងស្នូល សម្រាប់កសាងសង្គមនិយម តាមមូលដ្ឋាននីមួយៗ ហើយ ។ ឈរលើនេះ យើងពង្រីកទុនយើង ។ ឥឡូវយើងរកទុនដោយកសិកម្ម ។ ដូច្នេះ រៀបចំកសិកម្ម ។ បើដំណើរការយ៉ាងនេះ ៥ឆ្នាំ គឺខ្លាំង ។ មិនទាន់បានទូទាំងប្រទេស តែតាមកន្លែងមួយៗ គឺខ្លាំងហើយ ។ ហើយឈរលើនេះ យើងពង្រីកតទៅទៀត ។ កសិកម្មសម័យកម្ពុជាថ្មីឆ្នាំ១៩៨០ វាមានស្នូលហើយ ។ ឈរលើទីតាំង១៩៨០ ប៉ុណ្ណឹង ដល់ឆ្នាំ១៩៨៥ កសិកម្មសម័យនិងបានសម្រេចទូទាំងប្រទេសបានពេញទី ។ ដូច្នេះ១០ឆ្នាំ យើងសម្រេចបានកសិកម្មសម័យ ។ គន្លឹះ គឺនៅក្នុងរយៈពី៣ ទៅ៥ឆ្នាំនេះ ។

## កត្តាដឹកនាំជាកត្តាកំណត់សម្រេច

បញ្ហាចោទ ៈ បញ្ហាដីមិនពិបាកទេ បញ្ហាទឹកក៏មិនពិបាក បញ្ហាជីរមិនពិបាកទេ ។ នៅតែបក្សដឹកនាំ ។ មាគ៌ាយើងឯកភាពគ្នាហើយ ។ តែការអនុវត្តកន្លែងខ្លះខ្លាំង កន្លែងខ្លះមិនខ្លាំង ។ ដំណាក់កាលថ្មី ភារកិច្ចថ្មី ត្រូវរៀបចំកម្មាភិបាលថ្មី ។ កម្មាភិបាលយើងត្រូវជ្រួតជ្រាបមាគ៌ានេះ ជ្រះស្រឡះពីមាគ៌ានេះ វាយសម្រុកពីមាគ៌ានេះ មោះមុតពីមាគ៌ានេះ ។ ប្រជាជនចាំតែធ្វើតាមទេ ។ ដូច្នេះ កម្មាភិបាលអភិរក្សមិនបានទេ ។ ត្រូវរៀបចំមែនទែន ។ សាបពេលណា សំណាបយ៉ាងម៉េច ទប់ទឹកកុំឲ្យវាចូលរហ័សយ៉ាងម៉េច ។ បើធ្វើពីរដង ទាល់តែខែមេសា ម្ចាស់ការស្រេចហើយ ។ ដើម្បីម្ចាស់ការ ទាល់តែរៀបចំទឹក ហើយគិតគូរមែនទែន ។ ម្យ៉ាងទៀត កុំធ្វើតាមបូរាណ ដែលឯកជនធ្វើ ។ ឧទាហរណ៍ ៈ ធាក់ទឹកពីក្រោមមិនងាយទេ ។ នៅកន្លែងខ្លះបងប្អូនចំណាយកម្លាំងច្រើនធាក់ទឹកពីក្រោមមក ។ ឯកជនពីរដើមធាក់ទឹកពីក្រោម ពីព្រោះដីករែ្រកកាត់ដីគេមិនបាន ។ ដូច្នេះធ្វើម៉េចឲ្យវាវិទ្យាសាស្ត្រ ។ គិតគូរឲ្យខ្លាំង ។ មានតារាងថ្ងៃ ថ្ងៃនេះធ្វើអី ខែនេះធ្វើអី ។ កន្លែងណាភ្ជួរមុនកន្លែងណាភ្ជួរក្រោយ ។ បើមិនដូច្នោះ ស្រូវទុំហើយ ច្រូតហើយ អត់សំណាបធ្វើតទៅទៀត ។ ដូច្នេះ ពេលណាត្រូវរៀបចំអី ត្រូវមានតារាងថ្ងៃខែឲ្យច្បាស់ តាមសភាពការណ៍កន្លែងនីមួយៗ ហើយឈរលើនេះ ជ្រើសរើសកម្មាភិបាលតាមនេះ ។ ចលនាណា កម្មាភិបាលនោះ ។ កសាងសង្គមនិយម ជ្រើសរើសកម្មាភិបាលដែលគេចេះផ្នែប្រឌិត ។ ក្នុងនេះ កុំខ្លាចជ្រើសរើសកម្មាភិបាលពីក្នុងសហករណ៍ ពីព្រោះគេជាប់ចលនា ។ ហើយកុំខ្លាចរើសក្នុងក្រុមចល័ត ។ កម្មាភិបាលដឹកនាំក្រុមចល័តនេះ គេប្រយុទ្ធ គេធ្វើជាក់ស្តែង ។ នៅតែអប់រំគេ ពីមាគ៌ាដំណើរការ គេបម្រើចលនាបាន ។ ចលនាតាំងពី៧៥មក វាផលិតកម្មាភិបាលសម្រាប់ចលនានេះបានច្រើនណាស់ ។ ជួនណា កម្មាភិបាលដែលចេញពីចលនាសង្គ្រាមមក គ្រាញ រារាំងចលនាថ្មី ។ កម្មាភិបាលថ្មី គេខ្លាំងជាង គេចេញពីចលនាថ្មី គេបម្រើចលនាថ្មីនេះបាន ។ ជ្រើសរើសទៅ បើជួនណាវាខុសមួយពីរ ជាការធម្មតាទេ ។ តែនិយាយរួម កម្មាភិបាលចេញមកពីចលនាថ្មី វាបម្រើចលនាថ្មី ធ្វើជីរមិនស្ទាក់ស្ទើរ ។ ធ្វើប្រឡាយ

មិនស្មុគស្មាញ ។ ធ្វើពីរ ជងមិនស្មុគស្មាញ ។ ភូមិភាគតែឯង ក្រែងមើលមិនឃើញ តែរួមជាមួយស្រុក រួមជាមួយសហករណ៍ រួមជាមួយកងចល័ត មុខតែឃើញ ។ ធ្វើម៉េចឲ្យតែមាគ៌ាចុះទៅដល់ក្រោម ។ ឧទាហរណ៍ៈ មាគ៌ាធ្វើស្រែពីរដង ត្រូវចុះឲ្យដល់ក្រោម ។ ដូច្នេះកុំចុះតាមថ្នាក់ ។ កុំអភិរក្សពីបញ្ជាកម្មាភិបាល ។ ធ្វើបានឬមិនបាន ចាត់ចែងបាន ឬមិនបាន ពិនិត្យក្នុងចលនា កសាងក្នុងចលនា ។ ទន្ទឹមនេះត្រូវមានៈ

១) កាងារនយោបាយល្អ

២) ការងារសតិអារម្មណ៍ល្អ

៣) ការងារចាត់តាំងល្អ

◆ គណៈកម្មាធិការគ្រប់ថ្នាក់ល្អ

◆ កម្មាភិបាលគ្រប់ថ្នាក់ល្អ

◆ បក្សជនល្អ

◆ សាខាល្អ

◆ របៀបរបបដឹកនាំធ្វើការងារល្អ

◆ អង្គការស្នូលល្អ

**ពង្រឹងពង្រីកកម្លាំងសម្ព័ន្ធភាព កម្មករ-កសិករ ឲ្យខ្លាំង**

នេះជាកត្តាកម្លាំងកសាងសង្គមនិយមរបស់បក្ស ។ ដូច្នេះត្រូវមានៈ

១) ការងារនយោបាយល្អ

២) ការងារសតិអារម្មណ៍ល្អ

៣) ការងារចាត់តាំងល្អ

៤) អនុវត្តផ្ដាច់ការបដិវត្តន៍របស់បក្ស លើពួកប្រឆាំងបដិវត្តន៍ដាច់ខាត

៥) អនុវត្តប្រជាធិបតេយ្យ ជូនប្រជាជន កម្មករ-កសិករ ឲ្យល្អដើម្បីពង្រឹង និងពង្រីកជំនឿលើបដិវត្តន៍ ហើយបំផុសចលនាមហាជនឲ្យខ្លាំង និងឲ្យជាប់ ។

៦) កសាងជាក់ស្ដែង តាមសមាសភាពវណ្ណៈ

◆ កសាងកម្មករ

◆ កសាងកសិករ

◆ កសាងប្រទាប់វណ្ណៈផ្សេងៗ ដែលកំពុងប្រកបជីវភាពជាកសិករថ្មី ឬកម្មករ ដែលគ្មានបញ្ហានយោបាយជាមួយខ្លាំងៈ ជាបញ្ញាជន អនុធន ឬបុគ្គលទាំងអស់ណាដែលខបសក្កសង្គមនិយម ។ ត្រូវយកចិត្តទុកដាក់សំខាន់បំផុត អប់រំបំពាក់បំប៉ន ខាងនយោបាយ សតិអារម្មណ៍ ឲ្យគេក្ដាប់ និងជ្រួតជ្រាប នូវភារកិច្ច កសាងសង្គមនិយមតាមផែនការជាក់ស្ដែងឲ្យគេឃើញលទ្ធភាព និងអនាគតត្រចះត្រចង់នៃជីវភាពគេ និងប្រទេសជាតិគេ ។

បើយើងក្ដាប់ជ្រួតជ្រាប និងអនុវត្តបានល្អ នូវមាគ៌ារបស់បក្ស ដែលផ្អែកលើកសិកម្មជាមូលដ្ឋាន ក្នុងការកសាងសង្គមនិយម យើងពិតជាកសាងប្រទេសយើងបានឆាប់រហ័ស មានល្បឿនលោតផ្លោះ ដោយឈរលើមូលដ្ឋានសមូហភាពនៃវណ្ណៈអធន បានយ៉ាងពិតប្រាកដ ។

**ឆេង ទ៉េង**

# ដំណឹងស្វែងរកប្អូនស្រី

ខ្ញុំបាទឈ្មោះ ហង់ ខេត ភេទប្រុស អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ សូមប្រកាសរកឈ្មោះ ហង់ សាម៉ូត ភេទស្រី ត្រូវជាប្អូនស្រីពៅ (បច្ចុប្បន្ន អាយុប្រហែល៥៤-៥៥ឆ្នាំ) មានស្រុកកំណើតនៅភូមិត្រពាំងអណ្ដើក ឃុំបឹងស្រង៉ៃ ស្រុកត្រាំកក់ ខេត្តតាកែវ ។ កាលពីសម័យខ្មែរក្រហម សាម៉ូត ធ្វើជាកងនារីតំបន់ ស្រុកត្រាំកក់ មានឪពុកឈ្មោះ ជ័យ ឃុន និងម្ដាយ ឈឹម ណេង ។ មានបងប្អូនបង្កើត៧នាក់ (ប្រុស២ ស្រី៥នាក់) ។

បើបងប្អូនណាបានដឹងសូមទាក់ទងមកភូមិជ្រៃ ទូរស័ព្ទលេខ ០៩៧ ៣ ១៧៨ ៩៦៧ ឬ ទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទ ០២៣២១១៨៧៥ ។

***សូមអរគុណ!***

# នឹកស្មានមិនដល់ថានៅរស់ជីវិត

ហោ រ៉ែន ភេទស្រី អាយុ៥៩ឆ្នាំ មានស្រុកកំណើតនៅភូមិពងទឹក ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ។ រ៉ែន ជាកូនទី៣ ក្នុងចំណោមបងប្អូនស្រីបួននាក់ បានរៀបការជាមួយឈ្មោះ ឆែម ហួន (បច្ចុប្បន្ន ធ្វើជាមេភូមិអូរស្វាយ) ។ រ៉ែន មានកូនចំនួន៥នាក់ ប្រុសម្នាក់ និងស្រីបួននាក់ ។ ឪពុកឈ្មោះ ហោ ណង់ មានអាយុ៨៩ឆ្នាំ (ស្លាប់ឆ្នាំ២០១៣) ចំណែកម្តាយឈ្មោះ អោម ផន (ស្លាប់) ។

កាលពីកុមារ រ៉ែន រៀនបានត្រឹមថ្នាក់ទី៧ “ពីសង្គមចាស់” នៅសាលាអន្លុងមន្ត្រី ។ រស់នៅក្នុងសង្គម គ្រួសារកសិករមួយ ដែលឪពុកម្តាយជាអ្នកធ្វើស្រែ មានជីវភាពសមរម្យ និងមានការហូបចុកគ្រប់គ្រាន់ មិនមានការខ្វះខាតឡើយ ។ ក្រោយមក រ៉ែន បានឈប់រៀន ហើយនៅផ្ទះជាមួយឪពុកម្តាយ និងប្រកបរបរធ្វើស្រែចម្ការ ។

មុនរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សភាពការណ៍នៅក្នុងភូមិស្រុកដែល រ៉ែន រស់នៅ មានសភាពធម្មតា មិនមានអ្វីផ្លាស់ប្តូរទេ ព្រោះភូមិឃុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទាហាន លន់ នល់ ។ ប៉ុន្តែ ចាប់តាំងពីឆ្នាំ១៩៧១-៧៣ នៅតាមភូមិ និងតំបន់ដាច់ស្រយាលមួយចំនួន មានកងទ័ពខ្មែរក្រហមចេញចូលជាញឹកញយ ដើម្បីឃោសនាបំផុសឲ្យប្រជាជន ចូលរួមក្នុងចលនាតស៊ូជាមួយក្រុមរបស់ខ្លួន ។ កាលនោះ មានប្រជាជនដែលមានវ័យចំណាស់ៗមួយចំនួនបានស្ម័គ្រចិត្តចូលរួមតាមការឃោសនានេះ ។ ស្របពេលនោះដែរ ក៏មានការវាយប្រហារគ្នាដោយអាវុធទៅវិញទៅមក នៅពេលទាហានទាំងសងខាងពើបប្រទះគ្នានៅតាមភូមិ ដែលស្ថានការណ៍បែបនេះ តែងកើតមានក្នុងអំឡុងពេលមួយអាទិត្យម្តង ។ នៅពេលមានការវាយប្រយុទ្ធគ្នាម្តងៗ រ៉ែន និងអ្នកភូមិឯទៀតបានរត់គេចខ្លួនចេញពីកន្លែងកើតហេតុ ទៅរកកន្លែងដែលមានសុវត្ថិភាព រហូតដល់ស្ងប់ស្ងាត់ ទើបនាំគ្នាវិលត្រឡប់មកផ្ទះសម្បែងរៀងៗខ្លួនវិញ ។

នៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចូលមកកាន់កាប់អំណាចពេញលេញ ប្រជាជនស្ទើរទូទាំងប្រទេស ត្រូវបានឃោធាខ្មែរក្រហមជម្លៀសចេញពីផ្ទះសម្បែងឲ្យទៅរស់នៅតាមទីកន្លែងផ្សេងៗ ។ ដោយឡែក គ្រួសាររបស់ រ៉ែន និងអ្នកភូមិ មិនត្រូវបានខ្មែរក្រហមជម្លៀសឲ្យចេញទៅទីកន្លែងផ្សេងទេ ។ ជាពិសេសនៅក្នុងភូមិមានតែ រ៉ែន ម្នាក់គត់ដែលត្រូវបានអង្គការជ្រើសរើសឲ្យទៅធ្វើការនៅខាងស្រែអំបិល ដែលស្ថិតនៅកំពង់ណុង (នៅជិតវត្តកំពង់ណុង) ក្នុងខេត្តកំពត នៅក្នុងអង្គភាពវរសេនាតូចមួយដែលគ្រប់គ្រងដោយនារី រឹម (មកពីខេត្ត កំពង់ឆ្នាំង) ។

អង្គភាពរបស់ រ៉ែន មានសមាជិកចំនួន១០០នាក់ (ឬហៅថាកងរយ) ។ ជារៀងរាល់ថ្ងៃ រ៉ែន តែងចេញទៅ ធ្វើការតាមទិសរបស់អង្គការបានកំណត់ គឺពេលព្រឹកចាប់ពីម៉ោង៧ព្រឹក និងឈប់សម្រាកនៅម៉ោង៥ល្ងាច ។ ការហូបចុកនៅទីនោះ គឺហូបបាយលាយជាមួយពោត ក្នុងមួយថ្ងៃពីរពេល ។ ការងារនៅខាងស្រែអំបិល គឺធ្វើបានតែនៅខែណាដែលមិនមានភ្លៀងធ្លាក់តែប៉ុណ្ណោះ ។ ហេតុនេះនៅរដូវវស្សា រ៉ែន និងអ្នកផ្សេងទៀត ត្រូវទៅធ្វើចម្ការនៅតាមភ្នំ ឬនៅកន្លែងឯទៀតតាមការចាត់តាំងរបស់អង្គភាព ដើម្បីដាំដុះដំណាំផ្សេងៗ សម្រាប់ផ្គត់ផ្គង់ការហូបចុកនៅក្នុងអង្គភាពទាំងមូល ។

ចំពោះផលិតផលអំបិលដែលកងរបស់ រ៉ែន ផលិតបាន គឺត្រូវយកទៅទុកដាក់នៅក្នុងឃ្លាំង ហើយជារឿយៗ មានឡានមកដឹកអំបិលយកចេញទៅតាមកន្លែងផ្សេងៗទៀត តាមតម្រូវការរបស់អង្គការ ។ ជាធម្មតានៅក្នុងអង្គភាពរបស់ រ៉ែន មានការប្រជុំតាមពួក គឺរយៈពេលបីថ្ងៃប្រជុំម្តង ហើយការប្រជុំច្រើន ធ្វើឡើងពេលល្ងាច ក្រោយពេលហូបបាយរួចប្រហែលជាមួយម៉ោង ។

មួយរយៈពេលដែលទៅធ្វើការនៅស្រែអំបិល រ៉ែន ធ្លាប់បានផ្ញើសំបុត្រ ទៅសួរសុខទុក្ខឪពុកម្តាយបានចំនួនពីរដង ដោយផ្ញើតាមរយៈអ្នកធ្វើការនៅក្នុងកងសេដ្ឋកិច្ច ដែលធ្វើដំណើរឆ្លងកាត់ស្រុកកំណើតរបស់ រ៉ែន ។ រ៉ែន មិនដែលបានទៅលេងស្រុក

កំណើតទេ ព្រោះពីអង្គភាពទៅផ្ទះ មានចមាយផ្លូវឆ្ងាយ ព្រមទាំងគ្មានមធ្យោបាយធ្វើដំណើរផង ។

វ៉ន បាននៅធ្វើការងារក្នុងអង្គភាពស្រែអំបិលនេះ រហូតដល់ពេលដែលកងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជា ទើបរត់តាមកងទ័ពខ្មែរក្រហម ចូលព្រៃ និងឡើងភ្នំរហូតមកដល់ជំរំក្នុងទឹកដីថៃ ។

វ៉ន មិនហ៊ានធ្វើដំណើរវិលត្រឡប់មកស្រុកកំណើតរបស់ខ្លួនវិញទេ ព្រោះខ្លាចកងទ័ពវៀតណាមចាប់យកទៅសម្លាប់ចោល ។ ការហូបចុកនៅពេលរត់គេចខ្លួន ពីដំបូង វ៉ន មានអង្ករហូបខ្លះៗ លុះក្រោយមកអស់អង្ករ ទើបនាំគ្នាជីកក្តួច ជីកដំឡូង កាប់ផ្លែចេក ស្ងោរហូបនៅក្នុងព្រៃ រហូតបានទៅដល់ជំរំ ។ មានអ្នកភៀសខ្លួនជាច្រើន បានស្លាប់នៅតាមផ្លូវ ដោយខប្បទ្វេហេតុផ្សេងៗ និងមិនមានបាយហូប ។

វ៉ន បានរស់នៅកន្លែងមួយ ដែលអ្នកនៅទីនោះហៅថា ច្រក «១០០១» ស្ថិតនៅក្នុងភូមិមួយដែល គ្រប់គ្រងដោយ តាអាន ហេតុនេះទើបប្រជាជននាំគ្នាហៅថា «ភូមិតាអានៗ« ។ ចំពោះជីវភាពនៅពេល នោះមិនមានបញ្ហាអ្វីចោទទេ ប្រជាជនត្រូវបានផ្តល់របបហូបចុកដូចៗគ្នា ហើយជាពិសេសដល់ខែរដូវធ្វើបុណ្យទាន មានជំនួយខបត្ថម្ភពីអង្គការចែករបបជាអង្ករដំណើប អង្ករខ្សាយ ប្រេងឆា មី ត្រីខកំប៉ុងជាដើម ។ វ៉ន បានបន្តថា «ទោះជាយ៉ាងណា ជីវិតរស់នៅទីនោះ មានជួបការលំបាកខ្លះៗដែរ ព្រោះមានការវាយប្រយុទ្ធគ្នា រវាងយោធាខ្មែរក្រហម និងកងទ័ពខាងវៀតណាម ដែលនៅតែកើតមានជារឿយៗ ។

នៅឆ្នាំ១៩៨០ វ៉ន បានរៀបការជាមួយ ឆែម ហួន ជាអ្នកស្រុកជីក្រែង ។ ពីដំបូង ហួន ធ្វើជាយោធាខ្មែរក្រហម តែក្រោយមក ពេលរត់គេចពីការវាយលុករបស់កងទ័ពវៀតណាម ក៏បោះបង់អង្គភាពទ័ពចោល ហើយបានរៀបការជាមួយគាត់ និងរស់នៅជាប្រជាជនសាមញ្ញនៅច្រក «១០០១» បានរយៈពេលពីរឆ្នាំ ទើបចេញទៅរស់នៅច្រក «១០០៣» វិញ នៅក្នុងឆ្នាំ១៩៨២ មូលហេតុដោយសារច្រក «១០០១» ត្រូវកងទ័ពវៀតណាមវាយលុកចូលជាញឹកញាប់ ដោយនៅទីនោះគឺមានតែយោធាខ្មែរក្រហមប៉ុណ្ណោះដែលនៅឈរជើងការពារទីតាំង ។

គ្រួសាររបស់ វ៉ន រស់នៅច្រក ១០០៣ (ប្លុស៊ីងចាន់) បានប្រហែលមួយឆ្នាំក៏បានផ្លាស់ទៅនៅ ដើមរកាវិញ ។ ប្រជាជនដែលរស់នៅដើមរកា នៅតែមានការភ័យខ្លាច និងមានការប្រុងប្រយ័ត្នជាប់ជានិច្ច ព្រោះខ្លាចកងទ័ពវៀតណាមវាយលុកចូលមកទៀត ។ ក្រោយមក គាត់បានទៅរស់នៅជំរំអូរត្រាវ គ្រប់គ្រងដោយ យិន (ដែលត្រូវជាពូរបស់គាត់) ។ នៅជំរំអូរត្រាវ មានបើករបបហូបចុកឲ្យប្រជាជន ព្រោះមានជំនួយពីកាកបាទក្រហម ដែលផ្តល់មកពីប្រទេសបារាំង ។

នៅឆ្នាំ១៩៩១ វ៉ន បានចាកចេញពីជំរំអូរត្រាវ មករស់នៅឃុំត្រពាំងប្រិយ៍ «ជាមួយក្រុមខ្មែរក្រហម» ក្នុងស្រុកអន្លង់វែងបានមួយរយៈ តែដោយខ្លាចកងទ័ពខាងរដ្ឋាភិបាលវាយលុកចូលគាត់ ក៏បានភៀសខ្លួនទៅរស់នៅទំនប់ដាច់ (បច្ចុប្បន្ន ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ) នៅឆ្នាំ១៩៩៣ ។ វ៉ន រស់នៅ និងធ្វើស្រែនៅទីនោះ បានមួយឆ្នាំ កងទ័ពខាងរដ្ឋាភិបាល ក៏បានវាយលុកចូលមក ហេតុដូច្នេះគាត់ក៏បានរត់ភៀសខ្លួនទៅខាងជប់រុន (ស្ថិតនៅតាមបណ្តោយជួរភ្នំដងរែក ជាប់ព្រំប្រទល់ជាមួយប្រទេសថៃ) រហូតដល់មានការបោះឆ្នោត ។

ពេលនោះ ប្រជាជនទាំងអស់មានចិត្តត្រេកអរ សប្បាយរីករាយយ៉ាងខ្លាំង ដោយសង្ឃឹមថា នឹងមានសុខសន្តិភាព ហើយស្រុកទេស នឹងចប់សង្គ្រាម ជាមិនខានឡើយ ។

ក្រោយមក នៅអំឡុងឆ្នាំ១៩៩៥ វ៉ន បានវិលមករស់នៅឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ រហូតមកដល់សព្វថ្ងៃ ។

វ៉ន បានទៅលេងស្រុកកំណើតនៅខេត្តតាកែវ និងបានជួបជុំក្រុមគ្រួសារ ឪពុកម្តាយ និងបងប្អូន ។ វ៉ន បានបន្តថា គាត់មានអារម្មណ៍រំភើប និងសប្បាយរីករាយជាខ្លាំង ព្រោះគាត់មិននឹកស្មានថា អាចមានជីវិតរស់បានទៅដល់ស្រុកកំណើតរបស់ខ្លួនវិញនោះទេ ។ តែទោះយ៉ាងណាក វ៉ន និងគ្រួសារពេញចិត្តបន្តរស់នៅស្រុកគេ (ស្រុកអន្លង់វែង) តទៅទៀត ព្រោះទៅស្រុកកំណើតក៏មិនដឹងជាទៅប្រកបមុខរបរអ្វីដែរ ព្រោះគ្មានដីស្រែចម្ការសម្រាប់បង្កបង្កើនផល ។

**ឆេង ម៉េង**

# ៣៨ឆ្នាំក្រោយមក ទើបដឹងឈ្មោះអ្នកថតរូបពីរសន្ទឹក

រូបនេះថតនៅពេលណា? នរណាជាអ្នកថត? គឺជាសំណួរចោទសួរឡើងជារឿយៗដែលស្ទើរតែគ្មានចម្លើយ ។ ៣៨ឆ្នាំក្រោយមក ទើបយើងដឹងចម្លើយពិតលើរូបថតពីរសន្ទឹក ។ ពូ ឡោ ធន អាយុ៦១ឆ្នាំ នៅប៉ៃលិន បើកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រង់ទំព័រ ១៦ និង៦៩ ហើយប្រាប់ថា គឺឈ្មោះ គីម អតីតខ្មែរក្រហមដែលបម្រើការងារក្នុងមន្ទីរ ៣៥ នៃក្រសួងឃោសនាការនិងព័ត៌មាន ជាអ្នកថតរូប ក្នុងឆ្នាំ១៩៧៧ ។ ក្រសួងនេះដឹកនាំដោយ ហ៊ូ នឹម និងក្រោយមកដឹកនាំដោយ យុន យ៉ាត ភរិយារបស់ សុន សេន វិញ បន្ទាប់ពី ហ៊ូ នឹម ត្រូវបានចាប់ខ្លួនបញ្ជូនមកទួលស្លែងនៅខែមេសាឆ្នាំ១៩៧៧ ។

ពូ ធន បានរៀបរាប់រឿងរ៉ាវជាច្រើនទៀតទាក់ទិននឹងមេដឹកនាំខ្មែរក្រហម និងមន្ទីរ៨៧០ របស់មេដឹកនាំទាំងនោះ ។ ក-៥គឺជាអង្គភាពមួយចំណុះឲ្យមន្ទីរ៨៧០ ដែលមានទីតាំងនៅសាលាតិចណូ និងដឹកនាំដោយឈ្មោះ ភុំ ។ អង្គភាព ក-៥ គឺទទួលខុសត្រូវលើការបណ្តុះបណ្តាលនយោបាយ និងមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា របស់ខ្មែរក្រហមដល់កម្មាភិបាល ដែលក្រៅពី ភុំ មានឈ្មោះ ប៉ង់, យុន យ៉ាត និង ខៀវ សំផន គឺជាអ្នកបង្រៀនផ្ទាល់ក្នុងអំឡុងខែកក្កដា ឆ្នាំ១៩៧៥ ។ ក្រៅពីនោះ នៅមាន "ក" ជាច្រើនទៀតគឺពី ក-១ ដល់ ក-៨ ហើយ ក-១ ជាកន្លែងស្នាក់នៅរបស់មេដឹកនាំ ប៉ុល ពត និង នួន ជា គឺនៅមុំស្ពានទូតកូរ៉េខាងជើង ក្បែរវិមានឯករាជ្យសព្វថ្ងៃ ។ អំឡុងឆ្នាំ១៩៧៦ មានការផ្លាស់ប្តូរដោយអង្គភាព ក-៦ គឺទទួលខុសត្រូវបណ្តុះបណ្តាលនយោបាយ និងមាគ៌



គណៈប្រតិភូចិន ដឹកនាំដោយប្រធានាធិបតី ហ៊ួ ក្វឹហ្វេង មកទស្សនកិច្ចនៅកម្ពុជា ក្នុងឆ្នាំ១៩៧៧ ។ រូបថតនេះ ថតដោយឈ្មោះ គីម ដែលជាមិត្តរួមក្រុមជាមួយ ធន

របស់បក្សកុម្មុយនីស្តដល់កម្មាភិបាលថ្នាក់ភូមិភាគ តំបន់ និងស្រុកវិញ ហើយមាន ប៉ុល ពត ជាអ្នកបើកវគ្គ និង នួន ជា ជាអ្នកបង្រៀនផ្ទាល់ ។ មន្ទីរនេះនៅបូរីកីឡា ។

ពូ ធន បានរៀបរាប់បន្ថែមទាក់ទិននឹងមន្ទីរបឹងត្របែក ។ តាមពិតទៅ មន្ទីរបឹងត្របែកកាលជំនាន់ ប៉ុល ពត មានលក្ខណៈដូចជាភូមិមួយអ៊ីចឹង ។ មន្ទីរនេះមានទីតាំងនៅមុំផ្សារដើមថ្កូវទល់មុខនឹងវត្តសន្សំកុសលសព្វថ្ងៃនេះឯង ។ ពូ ធន និយាយថា មន្ទីរបឹងត្របែក មិនមែនជាគុកទេ ហើយដឹកនាំដោយឈ្មោះ សាន់ និងក្រោយមកដោយ សារ៉ែន ។ ពូ ធន ប្រាប់ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា ការបង្កើតមន្ទីរបឹងត្របែក គឺដើម្បីបង្រៀនភាសាខ្មែរ ចិន និងអង់គ្លេសដល់ក្មេងៗដែលបម្រុងនឹងបញ្ជូនទៅធ្វើការនៅក្រសួងការបរទេស ។

នៅខែកញ្ញា ឆ្នាំ១៩៧៧ ពូ ធន ត្រូវបានអង្គការខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការនៅមន្ទីរ ក-៣៥ ក្រោមចំណុះក្រសួងឃោសនាការ និងព័ត៌មាន ។ ពូ ធន មានតួនាទីជាអ្នកថតរូបភាព និងផលិតខ្សែភាពយន្តសម្រាប់ធ្វើការផ្សព្វផ្សាយដល់អន្តរជាតិ ។ ពូ ធន និងមិត្តរួមក្រុមឈ្មោះ គីម បានធ្វើដំណើរអមថ្នាក់ដឹកនាំក្នុងគោលបំណងថតរូបភាពរបស់គណៈប្រតិភូបរទេសដែលមកបំពេញទស្សនកិច្ចនៅកម្ពុជា ។ តាមរយៈ ពូ ធន រៀបរាប់ប្រាប់ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រសួងឃោសនាការ និងព័ត៌មានដំណើរការដោយមានមន្ទីរជុំវិញជាចំណុះ ដូចជា មន្ទីរ ៣៣, ៣៤, ៣៥, ៣៦, និង ៣៧ ។ មន្ទីរ៣៣ ជាកន្លែងចាក់ផ្សាយព័ត៌មានទីតាំងនៅជិតវត្តភ្នំ និងគ្រប់គ្រងដោយ ឈ្មោះ កុល ។ មន្ទីរ ៣៤ ទទួលខុសត្រូវក្នុងការពង្រីកការផ្សាយមានទីតាំងនៅស្ទឹងមានជ័យ និងគ្រប់គ្រងដោយឈ្មោះ គួយ ។ មន្ទីរ៣៥ ទទួលខុសត្រូវផ្នែកថតរូបភាព ខ្សែភាពយន្ត និងកាត់តរូបភាព និងគ្រប់គ្រងដោយឈ្មោះ ឃឿន ។ មន្ទីរ៣៦ មានទីតាំងនៅច្បារអំពៅទទួលខុសត្រូវផ្នែកសិល្បៈ និងរបាំ ។ ចុងក្រោយគឺមន្ទីរ ៣៧ មានទីតាំងនៅកន្ទួតក្បែរពោធិ៍ចិនតុង ។

**ឌ៉ាន់ថាន់ ពៅដារ៉ា**



គណៈប្រតិភូមា ដឹកនាំដោយប្រធានាធិបតី នេវិន មកទស្សនកិច្ចនៅកម្ពុជា ក្នុងឆ្នាំ១៩៧៧

# ជូ យ៉ន : អតីតប្រធានកងចល័តស្រុក

ជូ យ៉ន ជាអតីតកម្មាភិបាលខ្មែរក្រហមមួយរូប មានស្រុកកំណើត នៅភូមិអណ្តូងប្រាំ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ ជាកូនប្រុសច្បងនៅក្នុងគ្រួសារកសិករ ដែលមានបងប្អូនប្រុសស្រី ៦នាក់ ។ យ៉ន បានចំណាយស្ទើរពេញមួយជីវិតរបស់គាត់ ចូលរួមតស៊ូជាមួយបដិវត្តន៍ខ្មែរក្រហម រហូតដល់ថ្ងៃដែលរបបនេះដួលរលំទាំងស្រុង ។

យ៉ន ជាយុជនមួយរូប ដែលបានរៀនសូត្របានត្រឹមថ្នាក់បំពេញវិជ្ជាថ្នាក់ទី៧ ប៉ុណ្ណោះ នៅសាលា តាភេម ភ្នំស្រង់ ។ ដោយសារតែបញ្ហាជីវភាពគ្រួសារមានការលំបាក យ៉ន បានសម្រេចចិត្តឈប់រៀន ហើយត្រឡប់មកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ ។ ឪពុកម្តាយរបស់ យ៉ន បានរៀបការឲ្យ គាត់នៅឆ្នាំ១៩៦៨ ។

ក្រោយរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ខែមីនា ឆ្នាំ១៩៧០ យ៉ន បានសម្រេចចូលរួមចលនាតស៊ូរបស់យៀកកុង ក្រោយមកខ្មែរក្រហមគ្រប់គ្រងវិញដោយមាននាទីជាឈ្លបភូមិ ។ យ៉ន បានធ្វើការងារជាឈ្លប និងដើរតាមកងទ័ព ដោយមាននាទីសែងអ្នករបួស នៅសមរភូមិកំពង់ស្ពឺ រហូតដល់វាយបែកទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ។

ក្រោយវាយបែកទីក្រុងភ្នំពេញឆ្នាំ១៩៧៥ កងរបស់គាត់ត្រូវអង្គការរំសាយ លែងឲ្យមានកងទ័ពប្រដាប់អាវុធទៀតហើយ គឺតម្រូវឲ្យជីកប្រឡាយ និងរៀបជាកងចល័តវិញ ។ កងចល័តត្រូវបានអង្គការបែងចែកជាពីរប្រភេទគឺកងចល័តស្រុក និងចល័តតំបន់ ដែលរៀបចំដូចកងទ័ពដែរ ។

បន្ទាប់មក យ៉ន ត្រូវអង្គការចាត់តាំង ឲ្យ ធ្វើជាប្រធានកងចល័តស្រុក ក្នុងតំបន់៣២ ខេត្តកំពង់ស្ពឺ ភូមិភាគនិរតី ។ ការងារក្នុងកងចល័តនៅពេលនោះ គឺមានតែរែកដី ជីកប្រឡាយ និងទប់ទំនប់ប៉ុណ្ណោះ ។ អ្នកនៅកងចល័តរបស់ យ៉ន គឺមានអាយុចន្លោះពី២០ ទៅ៣០ឆ្នាំ តែកម្រមានអ្នកមានអាយុ៣០ឆ្នាំណាស់ ។ យ៉ន នៅពេលនោះមានអាយុ២៦ឆ្នាំ ។ យ៉ន ឲ្យដឹងថា ក្នុងកងចល័តភាគច្រើនជាកូនអ្នកស្រុកភូមិនៅទីនោះតែម្តង ចំពោះអ្នកថ្មី ប្រជាជន១៧ ដែលជម្លៀសមក លុះត្រាតែមានប្រវត្តិរូបល្អទើបអាចធ្វើការនៅកងចល័តបាន ។ យ៉ន មាននាទីជាប្រធានកងចល័តកងហាហើយការងារទៀតសោធ ក៏មានអ្នកនៅពិនិត្យមើលពីលើដែរ ។ ការងារនៅកងចល័តគឺពេលព្រឹកត្រូវធ្វើពី ម៉ោង៦ ឬ៧ និងល្ងាចពីម៉ោងមួយ ឬម៉ោងពីរ រហូតដល់ម៉ោងប្រាំល្ងាច ។ ចំពោះការហូបចុកវិញ គឺខ្វះខាតខ្សោយណាស់ មានតែបបរទេ ជួនកាល ដាំលាយជាមួយនឹងពោត ឬដំឡូង ។

យ៉ន ពេលនោះនៅធ្វើការជាមួយឈ្មោះ ប៉ន ដែលជាគណៈស្រុក ។ នៅអំឡុងឆ្នាំ១៩៧៦ ទំនប់មួយនៅជិតវត្តអំពែភ្នំបានបាក់ និងធ្វើឲ្យលិចស្រូវខូចអស់ ។ ប៉ន ត្រូវអង្គការចាប់ខ្លួនដោយចោទថា ក្បត់ និងយកមកឃុំឃាំងនៅវត្តអង្គ (កំពង់ត្រាំ) ។

នៅខែមិថុនា ឆ្នាំ១៩៧៧ យ៉ន ត្រូវអង្គការផ្លាស់មកខាងភូមិភាគពាយ័ព្យ ។ ប៉ុន្តែគាត់ត្រូវមកស្នាក់នៅវិទ្យាល័យតាកែវកន្លះខែសិន ។ ពេលនោះ តាម៉ុក បានបើករៀនសូត្រកម្មាភិបាល ។ តាម៉ុក បានលើកឡើងក្នុងវគ្គរៀនសូត្រនោះថា “តួនាទីរបស់សមមិត្តទាំងអស់នេះ សុទ្ធជាកម្មាភិបាល ព្រោះនៅខាងសមរភូមិសុទ្ធតែខាងភូមិភាគពាយ័ព្យ កម្មាភិបាលខ្លះល្អ ខ្លះមិនល្អទេ ។ ដូច្នេះយើងត្រូវបញ្ជូនកម្មាភិបាលធ្វើការងារនៅទីនោះ ។ អ៊ីចឹងត្រូវក្តាប់អំពីសភាពការណ៍ខ្លាំង ។ ខ្មាំងមានសកម្មភាពច្រើនណាស់បំផ្លិចបំផ្លាញរបស់រួម” ។ បន្ទាប់ពីរៀនចប់នៅតាកែវ យ៉ន ត្រូវអង្គការឲ្យមកកាន់នាទីជាកងផលិតធំ នៅភូមិក្តុល ស្រុកដូនទាវតំបន់៤ ដែលមានសមាជិកពី ៥០០ ទៅ ៦០០នាក់ ។ នៅស្រុកដូនទាវ គឺមានឈ្មោះ អេន ជាគណៈស្រុក និងនៅតំបន់៤នេះ គឺមានឈ្មោះ ឯក ជាគណៈតំបន់ មកពីខេត្តតាកែវ ។ យ៉ន ឲ្យដឹងថា ឯក ជាមនុស្សខូចខិលណាស់ ជាពិសេសរឿងស្រីញី ។ គាត់មិនចូលចិត្ត ឯក នេះទេ ហើយក្រោយមក តាម៉ុក ក៏ដក ឯក ទៅវិញ តែមិនដឹងថា ដកយកទៅខាងណានោះទេ ។ បន្តមក យ៉ន បានជួប តាទិត នៅ

បាត់ដំបង ដែលនៅពេលនោះ តាទិត មាននាទីជាគណៈតំបន់៣ ហើយ រស់ ញឹម ជាគណៈភូមិភាគ ។ បន្ទាប់ពី រស់ ញឹម ត្រូវអង្គការចាប់ គឺមានឈ្មោះ សៀន ជាមនុស្សជំនិតរបស់ តាម៉ុក មកគ្រប់គ្រងបន្ត ។ យ៉ន បានឲ្យដឹងថា ពីមុនមិនទាន់មាន សៀន គឺរបាយការណ៍ត្រូវផ្ញើទៅ តាម៉ុក តែក្រោយមក តាម៉ុក ប្រាប់ថា របាយការណ៍ត្រូវផ្ញើទៅ សៀន វិញដើម្បីតាមដានសភាពការណ៍ ។ ចំពោះ តាទិត គឺ យ៉ន បាន ជួបតែពេលមកប្រជុំនៅផ្ទះ តាញឹម នៅអន្លង់វិល ជិតវាលបែកចាន និងព្រលានយន្តហោះប៉ុណ្ណោះ ។ យ៉ន មិនស្គាល់ តាទិត ច្បាស់នោះទេ ។ ការប្រជុំភាគច្រើន តាម៉ុក មិនសូវបានចូលរួមនោះទេ ដោយសារគាត់យល់ថា មាន តាញឹម និង តាសៀន ហើយ ។ មួយរយៈក្រោយមក ការចាប់ខ្លួនកម្មាភិបាលក្នុងជួរបក្សមានជាបន្តបន្ទាប់ រហូតដល់ចាប់ខ្លួន តាញឹម តាឯក ជាដើម ។

ចំពោះការងារនៅកងធំផលិតវិញ គឺ យ៉ន បានឲ្យដឹងថា មានបញ្ហាពីតំបន់ ធ្វើស្រូវឲ្យបានបីតោនជាដាច់ខាត ។ តាម៉ុក បាននិយាយថា «បីតោន១ គឺចាំបីតោន ធ្វើបានមិនបាន គឺវិនិច្ឆ័យទៅតាមកម្លាំងកម្មាភិបាលប្រើប្រាស់គឺមាន ស្រេចតែលើយើងចាត់ចែងដីស្រែ គេមានកម្លាំងធ្វើ អ្នកឯងធ្វើមិនបាន ជារឿងស្លាប់របស់អ្នកឯង» ។ ចំពោះអ្នកដែលធ្វើមិនបានតាមផែនការអង្គការកំណត់ រាយការណ៍ពីការខ្វះខាតរបស់ប្រជាជន ជាពិសេស រឿងហូបចុក គឺត្រូវចាប់ខ្លួនតែម្តង ដោយអង្គការចោទថា «ក្បត់» ។ យ៉ន បានឲ្យដឹងថា គាត់ត្រូវដឹកនាំកងធ្វើស្រែប្រាំងចំនួនប្រាំរយហិកតា ហើយកម្លាំងនៅពេលនោះគឺមានគ្រប់គ្រាន់ ហើយលទ្ធផលក៏បានគ្រប់ផែនការដែលចាត់តាំងដែរ ។ តែអ្វីដែលចម្លែកនោះ គឺបញ្ហាប្រឈមប្រចាំថ្ងៃគឺខ្វះអង្ករសម្រាប់បរិភោគ ចំណែកម្ហូបវិញគឺមានគ្រប់គ្រាន់ ជាពិសេស គឺត្រីសម្បូរណាស់ ។ ចំណែកប្រពន្ធរបស់គាត់មាននាទីជាចុងភៅសម្រាប់កងរបស់គាត់តែម្តង ដោយមិនត្រូវបានចាត់តាំងឲ្យធ្វើអ្វីផ្សេងទៀតទេ ។

អំឡុងឆ្នាំ១៩៧៨ យ៉ន ឲ្យដឹងថា ការចាប់ខ្លួនត្រូវបានសម្រាលខ្លះ ក្រោយពី ខៀវ សំផន ចេញសេចក្តីប្រកាសតាមវិទ្យុនិងឯកសារថា «សម្រាលរដ្ឋអំណាច លែងមានប៉ះពាល់ ឬឲ្យវាយឲ្យអីដាច់ខាត» ។

ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ យ៉ន បានជួយសង្គ្រោះជីវិតមនុស្សពីនាក់ គឺមានឈ្មោះ ហៀប និង សៀន ។ អ្នកទាំងពីរត្រូវបានអង្គការស៊ើបដឹងថា ជាអតីតទាហាន លន់ នល់ ។ ក្រោយវៀតណាមវាយចូលភូមិគាត្តុល យ៉ន និងគ្រួសារបានភៀសខ្លួនដោយគ្មានគោលដៅ ហើយបានមកជួបនឹង តាម៉ុក នៅស៊ីងលាច ខេត្តពោធិ៍សាត់ ។ យ៉ន ក៏បានបន្តដំណើររហូតដល់កំរៀង និងស្នាក់នៅវត្តខ្លែម ។ បន្ទាប់មក ក៏មានការចរចាគ្នាជាមួយថៃ នៅត្រង់អូរមួយ ហើយគាត់បានកាប់គោមួយនឹមចែកគ្នាហូប ។ បន្ទាប់ពីចរចារួច ខាងថៃបានប្រាប់ទៅ យ៉ន ថា «ពួកអ្នកឯង ប្រាប់កូនចៅ ស្អែកប្រហែលជាម៉ោងមួយ ឬម៉ោងពីរ ខ្ញុំយកឡានមកដឹក ដូច្នេះរៀបចំដាំបាយអីគ្រប់គ្នាទៅ» ។

ក្រោយមក ខ្មែរក្រហមក៏មានរៀបចំជាកងទ័ពឡើងវិញ ដោយ យ៉ន មាននាទីជាកងរយ ផ្នែកខាងកាំភ្លើងធំ ដែលនៅជាប់ជាមួយកងពល២៥០ របស់ នី កន ជាប្រធានកងពល និង សារឿន ជាអនុកងពល ។ ពេលនោះ យ៉ន បានឲ្យដឹងថា ដោយសារកម្លាំងមានតិច ហេតុនេះ ក្នុងការធ្វើសង្គ្រាម គឺប្រើយុទ្ធសាស្ត្រសង្គ្រាមឈ្លប ។ ចំពោះបញ្ហាហូបចុកវិញ គឺមិនខ្វះនោះទេ ដោយមានអង្គការមនុស្សធម៌ដឹកមកទាំងឡាន១ ។

ក្រោយសមាហរណកម្មជាមួយរាជរដ្ឋាភិបាលរួចមក យ៉ន និងគ្រួសារបានត្រឡប់មករស់នៅក្នុងជីវភាពជាប្រជាពលរដ្ឋសាមញ្ញ ដោយប្រកបរបរធ្វើស្រែ និងដាំដំណាំ ។ យ៉ន មានកូនចំនួនប្រាំមួយនាក់ ស្រីពីរ-ប្រុសបួននាក់ ។ សព្វថ្ងៃគាត់រស់នៅស្រុកកំរៀង ខេត្តបាត់ដំបង ហើយយូរ១ម្តង ទើបគាត់ទៅលេងស្រុកកំណើតដើម្បីជួបជុំញាតិមិត្ត ។ **ផាន សារៈមុនិន្ទ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។


មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង
វិទ្យាស្ថានស្តីការពីសិក្សាបេតិកភណ្ឌវប្បធម៌ និងសិល្បៈកម្ពុជា ទាំងបែបទំនើប និងបុរាណ
ជាមូលដ្ឋានសម្រាប់ព្យាបាល និងផ្សះផ្សារបួសពីរបបខ្មែរក្រហម ។
“សន្តិភាពមានន័យថា ដំណេកនាពេលរាត្រីយ៉ាងស្កប់ស្កល់មួយ ហើយនៅពេលដែលភ្ញាក់ពីដំណេកនោះ
យើងមិនមានភាពភិតភ័យអំពីអ្វីទាល់តែសោះ...”

***រូបខាងលើ*** ៖ *ប្រាសាទកោះកេរស្ថិតនៅចម្ងាយប្រមាណ១២០គីឡូម៉ែត្រ នៅភាគឦសាននៃខេត្តសៀមរាប ។ គេអាចធ្វើដំណើរទៅកាន់ប្រាសាទនេះតាមរយៈផ្លូវជាតិ និងផ្លូវលំ ។ ទន្ទឹមនឹងនេះ ប្រាសាទនេះត្រូវបានហ៊ុមព័ទ្ធដោយទន្លេដែលហូរមកពីភ្នំនៅក្បែរៗ នោះ ។ តំបន់នេះជាប់ទាក់ទងជាមួយនឹងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ "ពីគ.ស.៩២៨ដល់គ.ស.៩៤១" ដោយទ្រង់បានយាងចេញពីរាជធានីអង្គរ ក្នុងគ.ស. ៩២១ ក្នុងគោលបំណងសាងអំណាចរបស់ព្រះអង្គនៅក្នុងតំបន់ ឆោកគគ្យ៉រ ដែលបច្ចុប្បន្នត្រូវបានស្គាល់ថាជាតំបន់កោះកេរ ។ ក្រោយពេលព្រះអង្គចូលទិវង្គត ក្សត្រដែលស្នងរាជ្យបន្ទាប់ពីព្រះបុត្រារបស់ព្រះអង្គ ព្រះនាម រាជេន្ទ្រវរ្ម័នទី២ បានកសាងរាជធានីអង្គរឡើងវិញ ដោយព្រះអង្គបានបោះបង់រាជធានីកោះកេរ នៅក្នុងសតវត្សរ៍ទី១៩ ។ (ពីប្រាសាទកោះកេរទៅកាន់ស្រុកអន្លង់វែង មានចម្ងាយ១៨៦គីឡូម៉ែត្រ ។ (រូបថតដោយ អ៊ូច មករា)*

*ដោយមានការគាំទ្រដ៏សប្បុរសពីសំណាក់ The Robert Bosch Stiftung GmbH និងរួមសហការជាមួយក្រសួងទេសចរណ៍របស់រាជរដ្ឋាភិបាលកម្ពុជា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានសេចក្តីសោមនស្សក្នុងការប្រកាសអំពីការបង្កើតនូវកម្មវិធីដំណើរទស្សនកិច្ចសន្តិភាពអន្លង់វែងរបស់ខ្លួន ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺជាកិច្ចផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។*

*កម្មវិធីដំណើរទស្សនកិច្ចសន្តិភាពអន្លង់វែង គឺជាកិច្ចផ្តួចផ្តើមដើម្បីឲ្យមានការផ្សះផ្សាសហគមន៍ ដែលមានគោលបំណងតភ្ជាប់ការបែងចែករវាងអតីតកម្មាភិបាលខ្មែរក្រហម នៅក្នុងទីតាំងកាន់កាប់ចុងក្រោយនៅអន្លង់វែង និងប្រជាជនជំនាន់ក្រោយៗរបស់កម្ពុជា ។ គោលបំណងនៃកម្មវិធីនេះគឺដើម្បីផ្តល់វេទិកាអប់រំ សម្រាប់ការសិក្សា (និងកាត់បន្ថយ) ជម្លោះរវាងមនុស្ស ព្រមទាំងដើម្បីជំរុញឲ្យមានការចូលរួមរបស់ប្រជាជនឲ្យកាន់តែទូលំទូលាយជាងមុន ។*

*ដោយប្រើប្រាស់បទពិសោធន៍ និងកិច្ចការ ពីមុនៗរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការអប់រំពីអំពើប្រល័យពូជសាសន៍ជាគំរូ គម្រោងនេះនឹងដឹកនាំសិស្សានុសិស្សក្នុងដំណើរទស្សនកិច្ចចំនួន៤ថ្ងៃ ទៅកាន់ទីតាំងកាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហមនៅអន្លង់វែង ដើម្បីចូលរួមក្នុងសកម្មភាពអប់រំប្រចាំថ្ងៃ ដែលទាមទារឲ្យមានការត្រិះរិះពិចារណា ការបង្ហាញមតិផ្ទាល់ខ្លួន និងការតស៊ូមតិ ព្រមទាំងផ្តល់ឱកាសក្នុងការប្រាស្រ័យទាក់ទង សន្ទនា និងសួរសំណួរទៅកាន់អតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះដែលរស់នៅក្នុងតំបន់នោះ ។*

*កម្មវិធីនេះ មិនត្រឹមតែផ្តល់នូវការយល់ដឹងស៊ីជម្រៅអំពីប្រវត្តិសាស្ត្រដ៏ហិង្សារបស់កម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានបំណងផ្តល់នូវការយល់ដឹងជាមូលដ្ឋានលើទ្រឹស្តីផ្សេងៗគ្នា ស្តីអំពីការដោះស្រាយ និងការកែប្រែជម្លោះ ។ ដំណើរទស្សនកិច្ចនេះនឹងសម្រេចនូវគោលដៅរបស់ខ្លួន តាមរយៈកិច្ចពិភាក្សារួមគ្នា ការធ្វើមគ្គុទ្ទេសក៍ទេសចរណ៍ទៅកាន់ទីតាំងប្រវត្តិសាស្ត្រក្នុងតំបន់ និងកម្មវិធីសិក្សាដែលប្រើប្រាស់នូវរឿងរ៉ាវផ្ទាល់ខ្លួន ដើម្បីផ្តល់នូវមេរៀនប្រវត្តិសាស្ត្រ និងសីលធម៌ ។ ដំណើរទស្សនកិច្ចនេះ ត្រូវបានរៀបចំឡើងដើម្បីជួយដល់ជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ដោយផ្តល់ឲ្យក្រុមទាំងពីរនូវឱកាសក្នុងការឆ្លុះបញ្ចាំង និងចែករំលែកការយល់ដឹងរបស់ខ្លួនទាក់ទងនឹងបទពិសោធន៍របស់ខ្លួនក្នុងអំឡុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ និងសង្គ្រាមស៊ីវិល (១៩៧៩-១៩៩៨) ដែល*

កើតមានបន្ទាប់ពីអំឡុងពេលនោះ ។

ដំណើរទស្សនកិច្ចនេះ ផ្អែកលើកម្មវិធីសិក្សាដែលបំផុសការគិត និងមានលក្ខណៈបុគ្គល ។ តាមរយៈកិច្ចពិភាក្សាផ្ទាល់ជាមួយនឹងជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម កម្មវិធីនេះនឹងជំរុញឲ្យអ្នកចូលរួមគិតពិចារណាលើភាពខុសប្លែកគ្នានៃបទពិសោធន៍របស់មនុស្ស (ឧទាហរណ៍រួមមានទាំង ភាពមនុស្សធម៌ និងភាពអមនុស្សធម៌) នៅក្នុងអំឡុងពេលនៃជម្លោះ និងចលាចលសង្គម ។ រឿងរ៉ាវទាំងនេះនឹងបញ្ជាក់អំពីសារសំខាន់នៃសកម្មភាពរបស់មនុស្សម្នាក់ៗ និងជួយធ្វើឲ្យប្រសើរឡើងនូវសមាសធាតុមូលដ្ឋាននៃការកែប្រែជម្លោះ និងជំនាញផ្នែកសង្គម ។ ទស្សនាទានមួយចំនួនដូចជាសមត្ថភាពក្នុងការឆ្លុះបញ្ចាំង ការគិតគូរ ប្រកបដោយសត្យានុម័តិ និងការយោគយល់គ្នាទៅវិញទៅមក គឺជាមូលដ្ឋានសំខាន់សម្រាប់សង្គម សន្តិភាព និងប្រជាធិបតេយ្យ ។ គម្រោងនេះនឹងផ្តោតលើការយោគយល់គ្នាតាមរយៈប្រវត្តិសាស្ត្រ ដែលជាកម្មវត្ថុចម្បង ហើយសិស្សានុសិស្សដែលចូលរួមក្នុងកម្មវិធីនេះ នឹងដើរតួនាទីជាអ្នកតំណាងនៅតាមសាលារៀនក្នុងតំបន់របស់ខ្លួន ដោយចែករំលែកនូវការសិក្សា និងការយល់ដឹងរបស់ខ្លួន ។

កម្មវិធីដំណើរទស្សនកិច្ចសន្តិភាពអន្លង់វែង បង្ហាញអំពីចំណុចចាប់ផ្តើមថ្មីមួយសម្រាប់ការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងឆ្ពោះទៅរកគោលបំណងរួមដែលបានពង្រឹង និងលើកកម្ពស់ សន្តិភាព ការអប់រំ និងសហគ្រាសដើម្បីប្រយោជន៍សង្គម ។ តាមរយៈគោលបំណងសំខាន់ៗទាំងនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានគោលដៅប្រែក្លាយខ្លួនទៅជាគ្រឹះស្ថានឈានមុខមួយក្នុងការអភិវឌ្ឍនូវវិធីសាស្ត្រប្រកបដោយនិរន្តរភាព ដើម្បីសម្រេចបាននូវការផ្សះផ្សា និងសន្តិភាពនៅក្នុងប្រទេសកម្ពុជា នៅក្នុងតំបន់ ព្រមទាំងនៅតាមបណ្តាទីតាំងដទៃទៀត ។



*អ៊ឹម ចែម នៅខាងឆ្វេង អង្គុយក្បែរលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅប្រាសាទព្រះវិហារស្ថិតលើកំពូលភ្នំដងរែក ដែលលាតសន្ធឹងនៅតាមព្រំប្រទល់កម្ពុជា ថៃ ។ អ៊ឹម ចែម គឺជាអតីតគណៈស្រុកមួយរូប ដែលតំបន់របស់គាត់មានប្រជាជនជាច្រើនបានស្លាប់បាត់បង់ជីវិត ដោយសារការសម្លាប់ ភាពអត់ឃ្លាន និងភាពល្ហិតល្ហៃក្នុងអំឡុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) ។ គាត់ត្រូវបានចោទដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អំពីទំនួលខុសត្រូវនៃឧក្រិដ្ឋកម្មទាំងអស់នេះ ។ នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ អ៊ឹម ចែម បានមកទស្សនាប្រាសាទព្រះវិហារដែលមានអាយុកាលជាងមួយសហស្សវត្សរ៍នេះ ជាលើកដំបូងក្នុងជីវិតរបស់គាត់ ។ ចាប់តាំងពីជម្លោះជាមួយថៃលើដីជុំវិញប្រាសាទព្រះវិហារបានផ្ទុះឡើងនាពេលថ្មីៗនេះ អ៊ឹម ចែម និងអ្នកភូមិរបស់គាត់ជួយផ្តល់ទាំងជំនួយផ្នែកស្មារតី និងសម្ភារជាបន្តបន្ទាប់ដល់ទាហានកម្ពុជាជួរមុខ ។ គាត់ និងប្រជាជននៅក្នុងភូមិដែលស្ថិតនៅចម្ងាយប្រហែល ៩០គីឡូម៉ែត្រពីប្រាសាទព្រះវិហារ ត្រូវបានទទួលរងនូវការបំផ្លាញយ៉ាងដំណំដោយសារការវាយប្រហារថ្មីៗនេះ បានរួមសាមគ្គីគ្នា និងជួយគាំទ្រដល់ការវាយប្រហារតបតទៅនឹងការលុកលុយរបស់ប្រទេសថៃ ។ ដូចគ្នានឹង អ៊ឹម ចែម ដែរ កងទ័ពដែលឈរជើងនៅតាមទីតាំងជម្លោះមួយចំនួនធ្លាប់ជាយោធាខ្មែរក្រហម ព្រមទាំងមួយចំនួនទៀតធ្លាប់ជាកងជំនួយដែលត្រូវបញ្ជូនចេញពីតំបន់របស់ អ៊ឹម ចែម ផ្ទាល់ទៅកាន់សមរភូមិ ។ យុទ្ធជនទាំងនេះមានការប្តេជ្ញាចិត្ត និងតស៊ូប្រយុទ្ធការពារនូវអ្វីដែលគេជឿជាក់ថាជាអធិបតេយ្យភាពរបស់កម្ពុជា ។ លោកបណ្ឌិត ចន ឌី. ឆរើអារី បច្ចុប្បន្នគឺជាសាស្ត្រាចារ្យបង្រៀនផ្នែកនីតិអន្តរជាតិ និងនយោបាយនៅសាកលវិទ្យាល័យមីឈីហ្គេន និងជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងបានចូលរួមក្នុងដំណើរទស្សនកិច្ចទៅកាន់ប្រាសាទព្រះវិហារជាមួយគ្នាផងនោះ បានមានប្រសាសន៍ថា តាមលក្ខខណ្ឌនៃការផ្សះផ្សាជាតិ រដ្ឋាភិបាលថៃបាន និងកំពុងតែជួយដល់រដ្ឋាភិបាលកម្ពុជា ។ យោងតាមសម្តីរបស់លោក យើងអាចលើកឡើងបានថា ការផ្សះផ្សាជាតិក្នុងកម្រិតដែលយើងមិនទាន់អាចសម្រេចបានកាលពីមុនមក អាចសម្រេចបានដោយសារការកើតមានជម្លោះព្រំដែនជាមួយថៃនៅលើដីនៅជិតប្រាសាទព្រះវិហារ ។ "អត្តសញ្ញាណរបស់ខ្មែរក្រហមត្រូវបានផ្លាស់ប្តូរ" អ្នកទាំងអស់នេះហាក់បីដូចជា បានលុបបំបាត់ពាក្យថា "ក្រហម" ដោយបច្ចុប្បន្នចាត់ទុកខ្លួនឯងថាជាខ្មែរតែមួយគត់ និងកំពុងតែប្រឆាំងការពារទឹកដីកម្ពុជាឲ្យរួចផុតពីការឈ្លានពានបរទេស ប្រកបដោយមោទកភាព ។ រាជរដ្ឋាភិបាលកម្ពុជាគ្រេកអរចំពោះអតីតយោធាខ្មែរក្រហម ដែលកំពុងការពារតំបន់ជម្លោះ និងប្រាសាទព្រះវិហារ ទន្ទឹមនឹងនេះ ប្រជាជនភាគច្រើនក៏សប្បាយចិត្តដែលមានយុទ្ធជនការពារប្រាសាទក្នុងរយៈពេលយូរអង្វែរ ។*

*ការពិពណ៌នា និងរូបថត ដោយៈ ជី ទេរិទ្ធិ*

***រូបភាពខាងលើ :*** *នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៣ តុលាការយុត្តិធម៌អន្តរជាតិ បានប្រកាសការបកស្រាយសាលក្រមឆ្នាំ១៩៦២ អំពីជម្លោះខ្មែរ ថៃ ទាក់ទងនឹងប្រាសាទព្រះវិហារ និងតំបន់ជុំវិញ (JDC) ។ ប្រាសាទព្រះវិហារ គឺជាប្រាសាទបុរាណបែបហិណ្ឌូ ដែលត្រូវបានកសាងឡើងក្នុងសម័យចក្រភពខ្មែរ ហើយប្រាសាទនេះមានទីតាំងស្ថិតនៅលើកំពូលភ្នំមួយកំពស់ ៥២៥ ម៉ែត្រ (ឬ១៧២២ហ្វីត) ក្នុងតំបន់ជួរភ្នំដងរែកក្នុងខេត្តព្រះវិហារ ប្រទេសកម្ពុជា ។ (ពីប្រាសាទព្រះវិហារទៅកាន់ស្រុកអន្លង់វែង មានចម្ងាយ ៧៨ គីឡូម៉ែត្រ ។ រូបថតដោយៈ អ៊ួច មករា*



***រូបខាងលើ៖*** *ប្រាសាទអង្គរវត្តរបស់ប្រទេសកម្ពុជា គឺជាវិមានសាសនាដ៏ធំផ្ដាច់គេក្នុងពិភពលោក ។ ប្រាសាទនេះត្រូវបានសាងសង់ឡើងដោយព្រះមហាក្សត្រខ្មែរ ព្រះនាម សូរ្យវរ្ម័នទី២ នៅដើមសតវត្សរ៍ទី១២ នៅក្នុងក្រុងយសោធរបុរៈ ដែលជារាជធានីរបស់ចក្រភពខ្មែរ ។ (ពីអង្គរវត្តទៅស្រុកអន្លង់វែងមានចម្ងាយ១២៩គីឡូម៉ែត្រ ។ រូបថតដោយ៖ ម៉េង គឹមឡុង*

*ឧត្ដម្ភដោយ៖*

*វិទ្យាស្ថានស្លឹករឹត, មជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍*

*ទូរស័ព្ទ៖ (+៨៥៥) ១២ ៥៧០ ៨៦៥/ សារអេឡិចត្រូនិច៖ truthsokkheang@dccam.org គេហទំព័រ៖ www.d.dccam.org*

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់៖*

*បណ្ឌិត លី សុខឃាង, នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង*

*អ្នកស្រី គ្រី ស៊ុយហៀង នាយិការរងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង*

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី ៖ អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

***(តពីលេខមុន)***

### ***ជំពូក៦៖ ការផ្លាស់ប្តូរឆាប់រហ័ស***

*ជំពូកនេះ មានបំណងផ្តើការស្រាយបំភ្លឺពីរបៀបផ្សេងៗជាច្រើនដែលជនជាតិចាមបានឆ្លើយតបទៅនឹងការផ្លាស់ប្តូរតាំងពីចប់សង្គ្រាមត្រជាក់ នៅពេលដែលប្រទេសកម្ពុជាបានបើកចំហទៅកាន់ពិភពលោក ។ ក្នុងន័យនេះ ជំពូកនេះនឹងពិនិត្យមើលកត្តាចម្បងៗជាច្រើននៅក្នុងសហគមន៍ចាម រួមទាំងការផ្លាស់ប្តូរដែលនាំមកដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជាដែលហៅកាត់ថា "អ៊ុនតាក់" សង្គមស៊ីវិលអ៊ីស្លាម បណ្តាញសកល និងឆ្លងប្រទេសសម្រាប់ការអប់រំ និងការរស់ឡើងវិញ នៃសាសនាអ៊ីស្លាម ការទំនាក់ទំនងនយោបាយក្នុងស្រុក ក៏ដូចជាការអប់រំនៅក្នុងសហគមន៍ចាម ។ ក្នុងការពិភាក្សាអំពីការអប់រំក្នុងចំណោមជនជាតិចាម អ្នកនិពន្ធនឹងពិនិត្យមើលពីការបែកបាក់រវាងក្រុមចាស់ និងក្រុមថ្មី (Kaum Tua vs. Kaum Muda) ប្រព័ន្ធសាលាអ៊ីស្លាម និងការអប់រំចាម នៅក្នុងប្រព័ន្ធអប់រំរបស់សាលារដ្ឋ ។ ចំណែកភេរវកម្មអ៊ីស្លាមនឹងត្រូវលើកយកមកពិភាក្សានៅជំពូកបន្ទាប់ ។*

### ***១) សេចក្តីផ្តើម***

*នយោបាយប្រទេសកម្ពុជាបានឈានចូលដំណាក់កាលថ្មី*



*ជនជាតិចាមប្រារព្ធពិធីបុណ្យម៉ាឡុត នៅវិហារកែវសរអូរឫស្សី ភូមិស្រែប្រិយ ឃុំស្រែប្រិយ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង*

មួយទៀត នៅទសវត្សរ៍ឆ្នាំ១៩៩០ ។ នៅពេលសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ជាមួយនឹងការដួលរលំនៃជញ្ជាំងក្រុងប៊ែរឡាំង *(the fall of Berlin Wall)* នៅក្នុងឆ្នាំ១៩៨៩ ប្រទេសកម្ពុជាបានត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរយ៉ាងខ្លាំង ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ។ គណបក្សនយោបាយកំពុងធ្វើការកែប្រែ និងផ្លាស់ប្តូរខ្លួនឯងដើម្បីសម្របខ្លួនទៅតាមកាលៈទេសៈប្រឈមនាពេលខាងមុខ ។ នៅខែកញ្ញា ឆ្នាំ១៩៨៩ កងទ័ពស្ម័គ្រចិត្តវៀតណាម បានដកទ័ពចេញរួចហើយ ។ បក្សប្រជាជនបដិវត្តន៍កម្ពុជាក៏ធ្វើការផ្លាស់ប្តូរឈ្មោះខ្លួនឯងឲ្យទៅជាឈ្មោះមួយដែលស្តាប់ទៅមិនមានលក្ខណៈកុម្មុយនីស្តនោះគឺ គណបក្សប្រជាជនកម្ពុជា ដែលទទួលបានជ័យជម្នះក្នុងឆ្នាំបន្តបន្ទាប់ នៅក្នុងសមរភូមិនយោបាយជាមួយគណបក្សរាជាធិបតេយ្យ ហ៊្វុនស៊ិនប៉ិច និងគណបក្សប្រឆាំង សមរង្ស៊ី ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានប្តូរឈ្មោះទៅជារដ្ឋកម្ពុជា ដើម្បីឆ្លុះបញ្ចាំងពីគោលបំណងរបស់ប្រទេសកម្ពុជា ក្នុងកំណែទម្រង់មុខមាត់ថ្មីរបស់ខ្លួនឲ្យមានលក្ខណៈប្រជាធិបតេយ្យ ដោយបានបោះបង់ចោលនូវមនោគមន៍វិជ្ជាកុម្មុយនីស្តដ៏យូរអង្វែងនោះចេញ ។

ការផ្លាស់ប្តូរដ៏ខ្លាំងក្លាបែបនេះ និងការដួលរលំនៃរបបកុម្មុយនីស្ត ប្រាកដជាបានប៉ះពាល់យ៉ាងខ្លាំងដល់ ម៉ាត់ លី ។ កន្លងមក គាត់ធ្លាប់ជាអ្នកគាំទ្រមនោគមន៍វិជ្ជាកុម្មុយនីស្តដ៏ស្មោះស្ម័គ្រមួយរូប ដោយសារគាត់មើលឃើញថា មនោគមន៍វិជ្ជាមួយនេះ គឺជាដំណោះស្រាយចំពោះភាពអយុត្តិធម៌សង្គម និងវិសមភាពសង្គមនៅប្រទេសកម្ពុជា ។ ប៉ុន្តែក្នុងរយៈពេលនៃអាជីពនយោបាយកាលពីមុនរបស់គាត់ គាត់បានមើលឃើញថា មនោគមន៍វិជ្ជាកុម្មុយនីស្តបាននាំមកនូវទុក្ខសោកមកឲ្យប្រជាជនកម្ពុជា និងចាម ច្រើនជាងសេចក្តីសុខ និងភាពរុងរឿង ។

ការផ្លាស់ប្តូរសង្គមដែលកើតឡើងបន្ទាប់ពីការដួលរលំនៃសង្គ្រាមត្រជាក់ គឺមានលក្ខណៈធំធេង រហូតធ្វើឲ្យទាំងអ្នកកាន់សាសនាព្រះពុទ្ធ និងសាសនាអ៊ិស្លាម ស្ទើរតែមិនអាចយល់បាន ។ សម្រាប់ជនជាតិចាម ការផ្លាស់ប្តូរទាំងនេះបានប្រកាន់យកទិសដៅជាច្រើន ។ ពួកគេមានប្រភពនៃការផ្លាស់ប្តូរពីបរទេសច្រើនជាងអ្នកកាន់សាសនាព្រះពុទ្ធ ហើយពួកគេមិនបានដឹងទេថាទិសដៅថ្មីទាំងនេះនឹងនាំពួកគេទៅណាទេ ។ ប៉ុន្តែ ជនជាតិចាមបានត្រៀមខ្លួនជាស្រេចសម្រាប់ការផ្លាស់ប្តូរបែបនេះ ព្រោះយ៉ាងហោចណាស់នៅក្នុងរដ្ឋប្រជាធិបតេយ្យនាពេលខាងមុខ សាសនាអ៊ីស្លាមនឹងត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិ បើកចំហជាងមុន ។ ជនជាតិចាមនឹងធ្វើការកែប្រែអត្តសញ្ញាណបន្ទាប់បន្សំរបស់ខ្លួនឯង ដោយពឹងផ្អែកទៅលើការផ្លាស់ប្តូរទាំងនៅក្នុងប្រទេស និងនៅលើសកលលោក ។

ការបញ្ចប់នៃសង្គ្រាមត្រជាក់ ក៏បាននាំមកនូវដំណោះស្រាយថ្មីមួយចំពោះជម្លោះនៅប្រទេសកម្ពុជា ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីស និងសេចក្តីសម្រេចជាបន្តបន្ទាប់របស់អង្គការសហប្រជាជាតិបានបង្កើតនូវភ្នាក់ងារឃ្លាំមើលបណ្តោះអាសន្នមួយ ដើម្បីធ្វើការគ្រប់គ្រងការបោះឆ្នោតបែបប្រជាធិបតេយ្យលើកទីមួយរបស់ប្រទេសកម្ពុជាក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមកនេះ ។ អង្គការសហប្រជាជាតិ បានបង្កើតនូវអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា ហៅកាត់ថា "អ៊ុនតាក់" "ដើម្បីធានាឲ្យបាននូវការអនុវត្តកិច្ចព្រមព្រៀងស្តីអំពីដំណោះស្រាយនយោបាយយ៉ាងទូលំទូលាយសម្រាប់ជម្លោះនៅប្រទេសកម្ពុជា ដែលចុះហត្ថលេខានៅទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១" ។ ការទទួលខុសត្រូវទាំងនោះ រួមបញ្ចូលទាំងវិស័យទាក់ទិននឹងសិទ្ធិមនុស្ស ការរៀបចំ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ការរៀបចំផ្នែកយោធារដ្ឋបាលស៊ីវិល ការថែរក្សាសណ្តាប់ធ្នាប់ និងច្បាប់ ការធ្វើមាតុភូមិនិវត្ត និងការតាំងទីលំនៅជាថ្មីឲ្យជនភៀសខ្លួន និងអ្នកត្រូវបានផ្លាស់ទីលំនៅការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជា" ។ ដូច្នេះ អ៊ុនតាក់បានដាក់ពង្រាយនូវកងរក្សាសន្តិភាពចម្រុះជាតិសាសន៍ និងប៉ូលីសស៊ីវិលមួយក្រុម ។ គួរឲ្យចាប់អារម្មណ៍ជាងនេះទៅទៀតនោះគឺ មនុស្សមួយចំនួននៃកងកម្លាំងនេះមកពីប្រទេសកាន់សាសនាអ៊ិស្លាម ដូចជា ប្រទេសអាល់ហ្សេរី បង់ក្លាដែស ប្រ៊ុយណេដារូសាឡឹម អេហ្ស៊ីប ឥណ្ឌា ឥណ្ឌូនេស៊ី ហ្ស៊កដានី ម៉ាឡេស៊ី ម៉ារ៉ុក ប៉ាគីស្ថាន សេនេហ្កាល និងទុយណេស៊ី ។ ប្រទេសកម្ពុជាបានទទួលបុគ្គលិកមនុស្សធម៌ដែលជាអ្នកកាន់សាសនាអ៊ិស្លាមមកពីបណ្តាប្រទេសទាំងនេះ ប៉ុន្តែការមកដល់យ៉ាងច្រើនកកកុញនៃបុគ្គលិកមនុស្សធម៌ទាំងនេះគឺមិនធ្លាប់មានពីមុនមកនោះទេ ។ ឥទ្ធិពលរបស់អ្នកទាំងនេះមកលើសាសនាអ៊ិស្លាម

នៅប្រទេសកម្ពុជាគឺធំធេងខ្លាំងណាស់ ។

បុគ្គលិកកាន់សាសនាអ៊ីស្លាមមួយចំនួនត្រូវបានចាត់តាំងឲ្យឈរជើងនៅតំបន់ដែលមានប្រជាជនចាមរស់នៅច្រើន ។ នៅខេត្តសៀមរាប កងទ័ពអ៊ុនតាក់បានបរិច្ចាគប្រាក់ខែមួយផ្នែករបស់ពួកគេ ដើម្បីចូលរួមកសាងវិហារអ៊ីស្លាមមួយខ្នងនៅភូមិស្ទឹងថ្មី ។ នៅខេត្តកណ្ដាល កងទ័ពឥណ្ឌូណេស៊ីបានរៃអង្គាសថវិកាជាងមួយម៉ឺនដុល្លារដើម្បីសាងសង់វិហារអ៊ីស្លាមមួយទៀតនៅក្នុងភូមិ ។ ការចូលរួមចំណែកបែបនេះពិតជាបានកើតឡើងនៅបណ្ដាកន្លែងមួយចំនួននៅទូទាំងប្រទេសដែលមានវត្តមានរបស់កងរក្សាសន្តិភាពមូស្លីម ។

គិតត្រឹមពេលនោះ ស្ថានភាពនៃសាសនាអ៊ីស្លាមកម្ពុជានៅតែដើរថយក្រោយខ្លះនៅឡើយ ។ ជនជាតិចាមតិចតួចណាស់ដែលអាចធ្វើដំណើរទៅដល់ទីក្រុងម៉ាកាស ដើម្បីបំពេញកាតព្វកិច្ចសាសនានៃការធ្វើធម្មយាត្រានៅក្នុងជីវិតរបស់ពួកគេ ។ វិហារអ៊ីស្លាមមានតិចតួច ហើយស្ថិតនៅឆ្ងាយ ដែលមិនបានផ្ដល់ភាពងាយស្រួលដល់ការថ្វាយបង្គំឲ្យបានប្រាំដងក្នុងមួយថ្ងៃ ។ នៅក្នុងទស្សនៈរបស់ក្រុមដាក់វ៉ះ ជនជាតិចាមយល់ឃើញថា ការថ្វាយបង្គំនៅព្រះវិហារ បានបុណ្យច្រើនជាងការថ្វាយបង្គំនៅផ្ទះរហូតដល់ទៅ ២៧ដងឯណោះ ។ ជាការពិតណាស់ គេត្រូវការវិហារអ៊ីស្លាមច្រើនជាងនេះ ដើម្បីឲ្យត្រឹមត្រូវទៅតាមស្តង់ដារមួយ ដែលសហគមន៍មូស្លីមគួរតែមាន ហើយជនជាតិចាមដឹងពីបញ្ហានេះ ។ ទាហានអ៊ុនតាក់ដែលកាន់សាសនាអ៊ីស្លាមបានជ្រួតជ្រៀបពីបញ្ហានេះ ដូចគ្នាទៅនឹងគណៈប្រតិភូមនុស្សធម៌អ៊ីស្លាមអ៊ីចឹងដែរ ដែលបានចាប់ផ្ដើមមកដល់ប្រទេសកម្ពុជាដើម្បីធ្វើការផ្ដល់ជំនួយ រួមទាំងក្រុមហ៊ុនអភិវឌ្ឍន៍អាជីវកម្ម និងសេដ្ឋកិច្ចមួយចំនួនផងដែរ ជាពិសេស មកពីប្រទេសម៉ាឡេស៊ី ។ ម៉ាឡេស៊ី នៅពេលនោះបានមើលឃើញប្រទេសកម្ពុជាថាមានសក្ដានុពលយ៉ាងខ្លាំងក្នុងវិស័យកសិកម្ម និងឧស្សាហកម្មដែលអាចរកប្រាក់ចំណេញច្រើន ។

ការបើកចំហប្រទេសកម្ពុជាតាមរយៈអ៊ុនតាក់ គឺជាព្រឹត្តិការណ៍ដែលទទួលបានការផ្សព្វផ្សាយយ៉ាងអស្ចារ្យ ដែលអនុញ្ញាតឲ្យពិភពលោកខាងក្រៅបានរៀនសូត្រ និងស្វែងយល់ពីចំណុចល្អ ចំណុចអាក្រក់ និងវិស័យដែលត្រូវការអភិវឌ្ឍន៍បន្ទាន់ជាងគេនៅក្នុងប្រទេសដែលទទួលរងភាពខ្ទេចខ្ទាំដោយសារសង្គ្រាមស៊ីវិលអស់រយៈពេលជាងម្ភៃឆ្នាំ ដែលអ្នកអង្កេតការណ៍ភាគច្រើនយល់ឃើញថា វាមិនមែនជាសង្គ្រាមដែលចាប់ផ្ដើមពីក្នុងប្រទេសកម្ពុជានោះទេ តែត្រូវបានបង្កឡើងដោយសង្គ្រាមត្រជាក់នៅលើសកលលោករវាងលោកខាងកើត និងខាងលិច ។ ឥឡូវនេះ សហគមន៍សកលមានបំណងសងមកប្រទេសកម្ពុជាវិញតាមរយៈអ៊ុនតាក់ និងបន្ទាប់ពីនោះមក គឺជំនួយផ្នែកមនុស្សធម៌ ។ ប្រទេស និងអង្គការអ៊ីស្លាម បានចូលរួមក្នុងឱកាសនេះ ។ អ៊ុនតាក់ ក៏បានជួយបង្កើតនូវរដ្ឋធម្មនុញ្ញកម្ពុជាថ្មីមួយ និងប្រព័ន្ធច្បាប់ដែលធានាឲ្យមានការគោរពសិទ្ធិជាមូលដ្ឋានរបស់មនុស្ស សេរីភាពនយោបាយ សេរីភាពបញ្ចេញមតិ និងលើសពីនេះទៅទៀតសម្រាប់ជនជាតិចាម គឺសេរីភាពជំនឿសាសនា ។

គិតត្រឹមពេលនោះ ដោយសារសាសនាអ៊ីស្លាមបានក្លាយទៅជាសាសនាសកលដែលមានសារសំខាន់ខាងនយោបាយខ្លាំង គណបក្សប្រជាជនកម្ពុជាបានបន្តការគាំទ្រ និងការលើកទឹកចិត្តចំពោះប្រជាជនចាម ដូចអ្វីដែលគណបក្សនេះបានធ្វើកន្លងមកនៅទសវត្សរ៍១៩៨០ ។ ទោះបីជាការរស់ឡើងវិញនៃសាសនាអ៊ីស្លាមដែលអាចទៅរួចនៅពេលអនាគត ក៏មិនបានធ្វើឲ្យគណបក្សប្រជាជនកម្ពុជា ងាករេចេញពីសេចក្ដីទុកចិត្តរបស់ខ្លួនថា អ្នកកាន់សាសនានេះនឹងមិនប្រឆាំងជាមួយខ្លួនឡើយក្នុងរយៈពេលខាងមុខនេះទេ ។ គណបក្សប្រជាជនយល់ឃើញត្រឹមត្រូវ ទោះបីជាមានជនជាតិចាមមួយចំនួន ក្រោយមក បានផ្លាស់មកគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច ដែលដឹកនាំដោយបុគ្គលជនជាតិចាម លេចធ្លោ ដូចជា អាម៉ាត់ យ៉ាស់យ៉ា និងតុលឡោះ ដែលទើបតែត្រឡប់មកពីបរទេស ។ ជាមួយនឹងរដ្ឋធម្មនុញ្ញថ្មី និងការគាំទ្រផ្នែកនយោបាយ សាសនាអ៊ីស្លាមមានសេរីភាពក្នុងការផ្លាស់ប្ដូរ សឹងតែដោយមិនទទួលបានការរិះគន់អ្វីទាំងអស់ ។ សាសនាអ៊ីស្លាមខ្លួនឯងនឹងត្រូវធ្វើការកំណត់ថា តើការផ្លាស់ប្ដូរនេះនឹងនាំទៅទីណា ហើយអ្វីទៅដែលល្អសម្រាប់សហគមន៍ចាម ។

បាតុភូតដ៏គួរឲ្យចាប់អារម្មណ៍មួយទៀតនៅដើមសករាជថ្មីមួយ ដែលមិនមានភាពច្បាស់លាស់ សម្រាប់ជនជាតិចាម គឺការឲ្យនិយមន័យ និងការកំណត់អំពីអ្វីដែលសហគមន៍ចាមត្រូវការ ។ បន្ទាប់ពីអំពើប្រល័យពូជសាសន៍ និងដប់ឆ្នាំនៃការរស់ឡើងវិញផ្នែក

សាសនាដែលនៅមានកម្រិត នៅចន្លោះឆ្នាំ១៩៧៩ ដល់ ១៩៨៩ គេមិនទាន់មានភាពច្បាស់លាស់នោះទេថា តើសាសនាអ៊ីស្លាមគួរតែត្រូវបានអភិវឌ្ឍន៍យ៉ាងខ្លាំងក្លានិងឆាប់រហ័ស ឬក៏ដោយប្រុងប្រយ័ត្ន ។ គេមិនដឹងទេថា តើជនជាតិចាម ចូលចិត្តរបៀបបង្រៀន និងការអនុវត្តបែបថ្មី មកពីបណ្តាញសាសនាអ៊ីស្លាមសកលជាងឬយ៉ាងណា ។ មិនមាននរណាដឹងអំពីរឿងនេះទេ សូម្បីតែ ម៉ាត់ លី និងអ្នកដឹកនាំសាសនាអ៊ីស្លាមដទៃទៀតទូទាំងប្រទេស ។ ក្រុមប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុកកិច្ចការអ៊ីស្លាមកម្ពុជា ដែលគ្រប់គ្រងកិច្ចការសាសនាអ៊ីស្លាមទាំងអស់ នៅទូទាំងប្រទេសកម្ពុជា មិនទាន់ត្រូវបានបង្កើតឡើងនោះទេ ។ ការស្ទង់មតិក៏មិនបានធ្វើឡើងដែរ ។ រដ្ឋាភិបាលខ្លួនឯង ក៏មិនដឹងថា នឹងត្រូវដោះស្រាយការផ្លាស់ប្តូរ និងការកំណត់ទិសដៅសម្រាប់ជនជាតិចាមយ៉ាងណានោះដែរ ។ លទ្ធផលចុងក្រោយគឺថា ការផ្លាស់ប្តូរទាំងនេះត្រូវបានអនុញ្ញាតឲ្យដើរតាមសម្រួលតាមធម្មជាតិរបស់វា ។ ដូចនៅក្នុងបណ្តាវិស័យផ្សេងៗរបស់កម្ពុជា មតិនិងចំណង់ចំណូលចិត្តនឹងត្រូវបានផ្លាស់ប្តូរទៅតាមការអភិវឌ្ឍ និងការផ្លាស់ប្តូរដែលបានកើតឡើង ។ គ្រប់គ្នានឹងរៀនដើរតាមចំណែកឯស្ថាប័នវិញ នឹងត្រូវបានបង្កើតឡើងជាចម្លើយតបនឹងបញ្ហាផ្សេងៗដែលកើតឡើង ។

## ៣) ស្ថាប័នសង្គមស៊ីវិលអ៊ីស្លាម និងបណ្តាញសកល

នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ តម្រូវការរបស់ប្រជាជនកម្ពុជា បរិយាកាសនយោបាយ និងពេលខ្លះព្រឹត្តិការណ៍ដែលធ្វើឡើងដើម្បីទាក់ទាញចំណាប់អារម្មណ៍សាធារណជនជាកត្តាកំណត់នូវទិសដៅសម្រាប់ការអភិវឌ្ឍ ។ ការរីកសុះសាយនៃសង្គមស៊ីវិលសកល នៅអំឡុងពេលនោះ មិនមែនជារឿងចៃដន្យនោះទេ ។ ទោះបីជាមិនមានអង្គភាពបង្កើតគោលនយោបាយណាមួយដែលត្រូវបង្កើតឡើងដើម្បីកំណត់ពីមធ្យោបាយសម្រាប់អភិវឌ្ឍ និងសម្រាប់ជ្រើសរើស ដូចនៅក្នុងវិស័យសេដ្ឋកិច្ចទីផ្សារសេរីដែលប្រទេសកម្ពុជាចាប់ផ្តើមឱបក្រសោបយ៉ាងងងឹតងងល់នោះ ជនជាតិចាមត្រូវតែកំណត់ទិសដៅអភិវឌ្ឍន៍ដែលត្រូវជ្រើសរើស ។

នៅទសវត្សរ៍ឆ្នាំ១៩៨០ ដូចដែលបានលើកឡើងខាងលើ



ពិធីសំណេះសំណាលជាមួយបងប្អូនជនជាតិចាម នៅវិហារកែវសរអូរឫស្សី ភូមិស្រែប្រិយ ឃុំស្រែប្រិយ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

ប្រទេសកម្ពុជាបានបិទជិតពីពិភពខាងក្រៅ ។ ដោយសារតែសកម្មភាពយោធាវៀតណាមប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវគេមើលឃើញថា ជារដ្ឋដែលពុំមានការទទួលស្គាល់ពីអន្តរជាតិ ។ របបនេះមិនត្រូវបានទទួលស្គាល់ពីលោកខាងលិចនោះទេ ប៉ុន្តែ របបនេះមានទំនាក់ទំនងល្អជាមួយប្លុកខាងកើត ។ មានប្រជាជនកម្ពុជាមួយភាគតូចប៉ុណ្ណោះដែលបានធ្វើដំណើរទៅកាន់ប្រទេសទាំងនោះ ហើយមានជនជាតិចាមរឹតតែតិចទៅទៀតដែលបានធ្វើដំណើរទៅក្រៅប្រទេស លើកលែងតែអ្នកដែលរស់នៅជំរំតាមព្រំដែនដែលត្រូវបានបញ្ជូនទៅតាំងទីលំនៅជាថ្មីដោយសន្ទឹមៗនៅក្រៅប្រទេស ។ ជនជាតិចាមរឹតតែតិចតួចទៅទៀត ដែលបានបំពេញកាតព្វកិច្ចធ្វើធម្មយាត្រាទៅកាន់ទីក្រុងម៉ាកាសនៅប្រទេសអារ៉ាប៊ីសាអូឌីដ ដែលជារដ្ឋសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក ។ នៅក្នុងលក្ខខណ្ឌនៃតម្រូវការផ្នែកសាសនា អវត្តមានក្នុងការធ្វើដំណើរបែបនេះបានឆ្លុះបញ្ចាំងពីឧទាហរណ៍មួយយ៉ាងច្បាស់នៃការដើរថយក្រោយរបស់ជនជាតិចាមនៅក្នុងក្រសែភ្នែករបស់សហគមន៍អ៊ីស្លាមសកល ។ ការធ្វើដំណើរបែបនេះគឺជាតម្រូវការមូលដ្ឋានខាងផ្នែកសាសនារបស់ជនជាតិចាម ។ អាស្រ័យហេតុនេះ សកម្មភាពចម្បងបំផុតក្នុងចំណោមសកម្មភាពជំនួយនានាដែលផ្តល់ឲ្យដោយពិភពអ៊ីស្លាមនោះ គឺការជួយដឹកនាំជនជាតិចាមទាំងនោះឲ្យបានធ្វើដំណើរឲ្យបានទៀងទាត់ទៅកាន់ទីក្រុងម៉ាកាស ។ អង្គការក្រៅរដ្ឋាភិបាលចាមដំបូងគេបង្អស់នៅប្រទេសកម្ពុជាបានកំណត់បញ្ហានេះជាគោលដៅអាទិភាពរបស់ខ្លួន ។

ម៉ាត់ លី បានបង្កើតសមាគមខ្មែរអ៊ីស្លាមនៅក្នុងឆ្នាំ១៩៨៨ ។ ទោះបីជាអង្គការរបស់គាត់ ធ្វើការផ្តល់ជំនួយផ្នែកអភិវឌ្ឍន៍ផ្សេងៗជាច្រើនដល់សហគមន៍ចាមក៏ដោយ ក៏គោលដៅជាចម្បងរបស់អង្គការនេះនៅតែផ្តោតទៅលើការធ្វើធម្មយាត្រាទៅកាន់ទីក្រុងម៉ាកាសដដែល ។ ការចំណាយភាគច្រើន សម្រាប់ការធ្វើដំណើរបែបនេះគឺទៅលើសំបុត្រយន្តហោះ និងការស្នាក់នៅ ។ តាមរយៈការជួយផ្គត់ផ្គង់ចំណាយនេះ ជនជាតិចាមអាចមានលទ្ធភាពលៃលកដោះស្រាយទៅលើចំណាយពាក់ព័ន្ធផ្សេងៗដោយខ្លួនឯងបាន ។ នៅឆ្នាំដំបូងៗ សមាគមខ្មែរអ៊ីស្លាមបានទទួលថវិកាសប្បុរសពីអ្នកជំនួញមានទ្រព្យសម្បត្តិពីឌូបៃពីររូប ឈ្មោះថា ម៉ាមូត អាប់ឌុលឡាកាស៊ីម *(Mahmoud Abdallah Kasim)* និង ហ៊ីសាម ណាសៀ *(Hisham Nasir)* ។ ក្នុងចំណោមជំនួយផ្សេងទៀត អ្នកមានទាំងពីរនាក់នោះ ក៏បានជួយរ៉ាប់រងលើចំណាយការស្នាក់នៅ និងសំបុត្រយន្តហោះសម្រាប់ជនជាតិចាម៣០នាក់ដើម្បីធ្វើធម្មយាត្រាទៅទីក្រុងម៉ាកាស ។ គេមិនដឹងច្បាស់នោះទេថា តើអ្នកទាំងពីរនាក់នោះអាចបន្តផ្តល់ថវិកា នៅឆ្នាំបន្ទាប់បានទៀតឬយ៉ាងណាទេ ប៉ុន្តែមានការរាយការណ៍មកថា សមាគមខ្មែរអ៊ីស្លាមបានរៀបចំដំណើរទស្សនកិច្ចច្រើនទៀតនៅឆ្នាំបន្ទាប់ៗ ។

អ្វីដែលគួរឲ្យកត់សម្គាល់ចេញពីជំនួយនៅដើមដំបូងនេះគឺថា ប្រទេសនៅអារ៉ាប់ និងសប្បុរជន ជាអ្នកជួយផ្គត់ផ្គង់ជនជាតិចាម ។ ប៉ុន្តែ ជំនួយរបស់ពួកគេហាក់បីដូចជា មិនមែនដើម្បីធ្វើការឃោសនាផ្នែកសាសនានោះទេ ។ ហេតុដូច្នេះ កេរ្តិ៍ឈ្មោះរបស់ពួកគេនៅក្នុងការអភិវឌ្ឍន៍សាសនាអ៊ីស្លាមនៅកម្ពុជា មិនមានភាពល្បីល្បាញទេ ។ ពួកគេគួរតែត្រូវបានទទួលស្គាល់ថា ជាអ្នកធ្វើកំណែទម្រង់សាសនាអ៊ីស្លាមនៅកម្ពុជានាំមុខគេ ជាជាងការទទួលស្គាល់ត្រឹមតែអង្គការម៉ាឡេ ។ ដោយសារមានជំនួយថវិកាជាបន្តបន្ទាប់មកពីឌូបៃ សមាគមខ្មែរអ៊ីស្លាមបានរួមចំណែកសាងសង់វិហារអ៊ីស្លាមបានជាង៣០ ។ អង្គការសប្បុរសធម៌ឌូបៃបានយល់ឃើញភ្លាមថា ការជួយដល់ជនជាតិចាមឲ្យធ្វើធម្មយាត្រាទៅកាន់ទីក្រុងម៉ាកាស គឺជារឿងមួយគួរឲ្យស្ញើចសរសើរក្នុងន័យសាសនាអ៊ីស្លាម ប៉ុន្តែ ការចំណាយថវិកាទៅលើ ការស្នាក់នៅ និងសំបុត្រយន្តហោះនឹងសាបរលាបពីភ្នែកសាធារណជនភ្លាមៗបន្ទាប់ពីចំណាយរួចហើយ ពួកគេនឹងមិនទទួលបានការផ្សព្វផ្សាយជាសាធារណដែលអំណោយផលដល់ពួកគេច្រើនប៉ុន្មាននោះទេ ។ ហេតុដូចនេះ នៅក្នុងការសាងសង់វិហារអ៊ីស្លាមបន្តបន្ទាប់មកទៀត ឈ្មោះរបស់វិហារនីមួយៗដែលទទួលបានជំនួយពីឌូបៃនឹងត្រូវបានដាក់ពាក្យថា ឌូបៃនៅពីមុខ ដូចជា ឌូបៃភ្នំពេញ ឌូបៃឃ្លាំងស្បែក និង ឌូបៃកោះកុង ។ ឌូបៃភ្នំពេញ ត្រូវបានសាងសង់ឡើងនៅក្នុងឆ្នាំ១៩៩៤ អស់ទឹកប្រាក់៣៥ម៉ឺនដុល្លារអាមេរិក ហើយក៏ជាទីតាំងគោលថ្នាក់ជាតិសម្រាប់ប្រជាជនកម្ពុជាទាំងអស់ផងដែរ ។

បន្ទាប់ពីការបង្កើតសមាគមខ្មែរអ៊ីស្លាម និងកិច្ចខិតខំប្រឹង

ប្រែងផ្នែកមនុស្សធម៌របស់សមាគមនេះ គឺជាការមកដល់របស់មេដឹកនាំធំនៃចលនាដាក់វ៉ះកម្ពុជា ។ ស៊ូឡៃម៉ាន អ៊ីប្រាហ៊ីម (Sulai man Ibrahim) បានមកដល់ប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ ដែលប្រហែលជាបន្ទាប់ពីបានដឹងពត្ថូវរបត់នយោបាយថ្មី និងការគិតពីតម្រូវការរបស់ជនជាតិចាម ។ គាត់ត្រឡប់មកវិញ បន្ទាប់ពីបានត្រាច់ចរ និងសិក្សាពីសាសនាអ៊ីស្លាមអស់រយៈពេលដប់ឆ្នាំនៅប្រទេសវៀតណាម ថៃ សហរដ្ឋអាមេរិក អេហ្ស៊ីប និងម៉ាឡេស៊ី រវាងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ ។ ជាមួយនឹងការមកដល់របស់ ស៊ូឡៃម៉ាន អ៊ីប្រាហ៊ីម ចលនា តាប្លីហ្គី ចាម៉ាត (Tablighi Jamaat) ដែលហៅកាត់ថា TJ បានមកដល់ប្រទេសកម្ពុជាយ៉ាងគំហុករូចទៅហើយ ។

មុនការមកដល់របស់ ស៊ូឡៃម៉ាន អ៊ីប្រាហ៊ីម គឺការមកដល់របស់អ្នកជំនាញចលនា TJ ជនជាតិ ប៉ាគីស្ថាន និងឥណ្ឌា នៅក្នុងឆ្នាំ១៩៨៧ និង១៩៨៨ នៅភូមិព្រែកប្រា ជិតទីក្រុងភ្នំពេញ ។ នេះជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលធ្វើឲ្យភូមិព្រែកប្រានេះ ក្លាយទៅជាទីកន្លែងគោរពមួយនៃចលនា TJ ហើយជាកន្លែងដែលមានអ្នកជឿស៊ប់លើចលនា TJ នេះច្រើនបំផុតដែរ នាពេលបច្ចុប្បន្ននេះ ។ នេះប្រហែលជាដោយសារការជ្រើសរើសដោយចៃដន្យ ហើយភូមិព្រែកប្រានេះ មានទីតាំងនៅជិតទីក្រុងភ្នំពេញ ដែលជាហេតុធ្វើឲ្យអ្នកជំនាញចលនា TJ កាលពីដើម ជ្រើសរើសយកភូមិនេះជាកន្លែងចាប់ផ្តើមដំណើរការឃោសនាចលនា TJ លើកដំបូងបង្អស់របស់ពួកគេនៅប្រទេសកម្ពុជា ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ផ្លូវថ្នល់នៅប្រទេសកម្ពុជាក៏ដូចជាមធ្យោបាយធ្វើដំណើរផ្សេងៗ គឺនៅមានកម្រិតនៅឡើយ ។ រយៈចម្ងាយពីទីក្រុងភ្នំពេញទៅខេត្តកំពង់ចាមមានត្រឹមតែ១៥០គីឡូម៉ែត្រតែប៉ុណ្ណោះ ប៉ុន្តែ ពេលខ្លះគេត្រូវចំណាយពេលអស់ពីរថ្ងៃឯណោះដើម្បីទៅដល់ ដោយសារតែមានការយាយីពីសំណាក់ខ្មែរក្រហម និងលក្ខខណ្ឌមធ្យោបាយធ្វើដំណើរដ៏លំបាក ។ ការគិតបែបនេះប្រហែលជាសម្រាប់ពួកអ្នកជំនាញចលនា TJ ដែលគិតថាការឃោសនាគួរតែចាប់ផ្តើមពីវិធីសាស្ត្រងាយស្រួលបំផុត ដើម្បីផ្សព្វផ្សាយទៅដល់សហគមន៍អ៊ីស្លាម ។ យូសុះ ខាន់ (Yusuf Khan) ដែលជាមេដឹកនាំចលនា TJ នៅអាស៊ីអាគ្នេយ៍ម្នាក់ ក៏បានទៅដល់ភូមិព្រែកប្រានេះ ដូចសមាជិកផ្សេងៗទៀតដែលមកពីប្រទេសម៉ាឡេស៊ី និងប្រទេសថៃខាងត្បូងផងដែរ ។

ប៉ុន្តែ ស៊ូឡៃម៉ាន អ៊ីប្រាហ៊ីម មិនយល់ឃើញបែបនេះនោះទេ ។ ក្នុងនាមជាអ្នកស្រុកខេត្តកំពង់ចាម គាត់មិនមានភាពរុញរាដោយសារបញ្ហាផ្លូវធ្វើដំណើរមានភាពលំបាក ឬក៏គិតចង់តែពាំនាំការឃោសនារបស់គាត់ទៅកន្លែងណាដែលមានលក្ខណៈងាយស្រួលនោះទេ ។ ស៊ូឡៃម៉ាន អ៊ីប្រាហ៊ីម បានជ្រើសរើសភូមិទ្រាធ្វើជាទីកន្លែងគោរពសម្រាប់ការខិតខំប្រឹងប្រែងឃោសនារបស់គាត់ ។ ដូចនេះ មិនមែនមានតែជនជាតិប៉ាគីស្ថាន និងឥណ្ឌានោះទេ ដែលគួរតែទទួលបានការស្ងើចសរសើរសម្រាប់ការផ្សព្វផ្សាយចលនា TJ នៅកម្ពុជានោះ ។ ជាមួយនឹងការខិតខំតស៊ូព្យាយាម ក៏ដូចជាការលះបង់អស់មួយជីវិតរបស់ ស៊ូឡៃម៉ាន អ៊ីប្រាហ៊ីម បានធ្វើឲ្យភូមិទ្រា និងកន្លែងដទៃជាច្រើនទៀតទូទាំងប្រទេសកម្ពុជាក្លាយទៅជាទីតាំងដ៏រឹងមាំរបស់ចលនា TJ ។ គាត់ក៏បានសាងសង់ម៉ាដ្រាស់សារមួយក្នុងចំណោមម៉ាដ្រាស់សារដំបូងគេនៅភូមិទ្រាក្នុងឆ្នាំ១៩៩២ ដោយមានជំនួយថវិកាពីប្រទេសម៉ាឡេស៊ី និងជនជាតិចាមដែលរស់នៅបរទេស ដែលបានភៀសខ្លួនចេញពីប្រទេសកម្ពុជានៅទសវត្សរ៍ឆ្នាំ១៩៧០ និងដើមទសវត្សរ៍ឆ្នាំ១៩៨០ ។ នាពេលបច្ចុប្បន្ននេះ ចលនា TJ គឺជាចលនារីកដុះដាលមួយដែលមានទីកន្លែងគោរពបូជាសំខាន់ៗ នៅភូមិទ្រា ព្រែកប្រា អូរជ្រៅ (ខេត្តព្រះសីហនុ) ភូមិអណ្តែតទឹកនៅកោះមនោ (ខេត្តពោធិ៍សាត់) និងទីកន្លែងគោរពជាច្រើនទៀតនៅបណ្តាខេត្តនានា ។ នៅអូរជ្រៅ ម៉ាដ្រាស់សារទទួលបានព្រះវិហារអ៊ីស្លាមមួយកសាងឡើងនៅក្នុងឆ្នាំ២០០០ ។

សមាជិកនៃចលនា TJ កម្ពុជាមានទំនាក់ទំនងជាមួយនឹងសហគមន៍ម៉ាឡេនៅប្រទេសថៃខាងត្បូង ជាពិសេសសហគមន៍ម៉ាដ្រាស់សារ ម៉ាកាស្ស តាប្លី (Madrasa Markaz Tabligh) នៅទីក្រុងយ៉ាឡា (Yala city) ដែលជាកន្លែងដែលគ្រូចលនា TJ កម្ពុជាត្រូវបានបញ្ជូនទៅសិក្សាហ្វឹកហ្វឺនហើយត្រឡប់មកវិញដើម្បីបង្រៀនជនជាតិចាមដទៃទៀតនៅកម្ពុជា ។ អ្នកអង្កេតការណ៍ខ្លះទៀតបានអះអាងថា ជនជាតិចាមក៏បានចូលរួមក្នុងម៉ាដ្រាស់សារនៅប្រទេសប៉ាគីស្ថានផងដែរ ប៉ុន្តែ គេមិនដឹងច្បាស់ទេ ថាតើការហ្វឹកហ្វឺនបែបនេះមានប្រជាប្រិយភាពដល់កម្រិតណានៅក្នុងចំណោមសមាជិក TJ

នៅកម្ពុជា ។ ទោះបីជាត្រូវបានហាមប្រាមនៅក្នុងរដ្ឋពីររបស់ប្រទេសម៉ាឡេស៊ី ដូចជា រដ្ឋសាបា នៅក្នុងឆ្នាំ១៩៨៥ និងម៉ាឡាកា នៅក្នុងឆ្នាំ១៩៩២ ចលនា *TJ* គឺជាកម្លាំងផ្នែកសតិអារម្មណ៍មួយដ៏ធំធេងនៅកម្ពុជា ហើយក៏ប្រហែលជាកំពុងនាំមកនូវការផ្លាស់ប្តូរជាច្រើនចូលក្នុងសង្គមចាម ជាជាងការផ្លាស់ប្តូរដែលពាំនាំមកដោយអង្គការមនុស្សធម៌អារ៉ាប់ទៅទៀត ។ ដូចគ្នាដែរ នៅប្រទេសថៃ ចលនា *TJ* ត្រូវបានអនុញ្ញាតឲ្យដំណើរការដោយមិនទទួលបានការរំខានពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច ដែលធ្វើឲ្យប្រទេសថៃភាគខាងត្បូងក្លាយទៅជាទីកន្លែងគោរពបូជាដ៏រឹងមាំមួយសម្រាប់ចលនា *TJ* នៅអាស៊ីអាគ្នេយ៍ ។ នៅទីនេះ យើងលើកយកករណីសិក្សាពីរមកពីប្រទេសកាន់ព្រះពុទ្ធសាសនា ដែលមានភាគរយនៃអាត្រាប្រជាជនកាន់សាសនាអ៊ីស្លាមប្រហាក់ប្រហែលគ្នា (តិចជាងដប់ភាគរយក្នុងប្រទេសនីមួយៗ) បានក្លាយទៅជាទីតាំងគោរពបូជាដ៏រឹងមាំសម្រាប់ចលនាមួយក្នុងចំណោមចលនាខ្លាំងក្លារបស់សាសនាអ៊ីស្លាម ។

ការចូលរួមរបស់បណ្ឌិតអ៊ីស្លាមសកល នៅក្នុងការអភិវឌ្ឍសហគមន៍ចាម នៅប្រទេសកម្ពុជា បាននាំមកនូវការរីកសុះសាយនៃអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលទទួលបានការឧបត្ថម្ភថវិកាពីស្ថាប័នហួសពីកម្រិតថ្នាក់ជាតិទៀត រួមជាមួយម្ចាស់ជំនួយថ្នាក់តំបន់ថ្នាក់ជាតិ និងឯកជនផងដែរ ។ តម្រូវការបន្ទាន់មួយទៀតសម្រាប់សហគមន៍ចាមកម្ពុជា គឺការអប់រំចាមក្មេងៗជំនាន់ក្រោយ ។ ដូចជនជាតិខ្មែរជាទូទៅដែរដែលទទួលរងការបំផ្លិចបំផ្លាញខាងផ្នែកសហគមន៍បញ្ញវន្ត ក៏ដូចជាកង្វះខាតការធ្វើឲ្យរស់ឡើងវិញនូវវិស័យអប់រំដ៏រឹងមាំមួយនៅទសវត្សរ៍ឆ្នាំ១៩៨០ គេទទួលស្គាល់ថា សហគមន៍ចាម ត្រូវការជាចាំបាច់នូវការធ្វើឲ្យប្រសើរឡើងវិញក្នុងវិស័យអប់រំទាំងផ្នែកសាសនា និងផ្នែកវិទ្យាសាស្ត្រ ។ ការឲ្យអាទិភាពទៅលើផ្នែកមួយក្នុងចំណោមផ្នែកទាំងពីរ ផ្នែកវិទ្យាសាស្ត្រ ឬផ្នែកសាសនា គឺនៅតែជាប្រធានបទពិភាក្សានាពេលបច្ចុប្បន្ននេះ នៅក្នុងចំណោមមេដឹកនាំសហគមន៍ចាម ក៏ដូចជាកូនសិស្សចាមដែរ ។ បើមិនមានការលើកទឹកចិត្តបែបនេះ កូនសិស្សចាមនឹងចូលចិត្តការអប់រំបែបវិទ្យាសាស្ត្រ ជាជាងការសិក្សាខាងសាសនា ។



ពិធីសំពះយាំងរបស់ជនជាតិចាម នៅវិហារកែវសរអូរឫស្សី ភូមិស្រែប្រិយ ឃុំស្រែប្រិយ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

ដោយយល់ឃើញពីតម្រូវការអប់រំថាជាតម្រូវការអភិវឌ្ឍមួយសំខាន់ជាងគេ ក្រុមបញ្ញវន្ត ចាមមួយក្រុមបានបង្កើតសមាគមនិស្សិតខ្មែរអ៊ីស្លាម (CAMSA) នៅក្នុងឆ្នាំ១៩៩៧ ។ ជំនួយឧបត្ថម្ភរបស់សមាគមន៍នេះ បានមកពីបណ្តាប្រទេសនៅអារ៉ាប់ម្ចាស់ជំនួយឯកជន ម៉ាឡេស៊ី អាល្លឺម៉ង់ និងមកពីប្រភពផ្សេងៗទៀត ។ គោលដៅចម្បងរបស់សមាគមន៍នេះ គឺមិនមែនក្នុងន័យសាសនាទេ ប៉ុន្តែ ដើម្បីការអភិវឌ្ឍន៍ក្មេងៗជនជាតិចាមនៅក្នុងវិស័យអប់រំបែបវិទ្យាសាស្ត្រ ជាពិសេសតាមរយៈការជួយឧបត្ថម្ភលើការស្នាក់នៅ និងថ្លៃសិក្សានៅសាលាទាំងក្នុង និងក្រៅប្រទេស ហើយក៏ជួយរកការងារឲ្យនិស្សិតដែលបានបញ្ចប់ការសិក្សាផងដែរ ។ យោងទៅតាម សុះ ម៉ូស៊ីន ដែលជាប្រធានសមាគមនាពេលបច្ចុប្បន្ននេះ សមាគមនិស្សិតខ្មែរអ៊ីស្លាមបានបញ្ជូននិស្សិតជាងមួយរយនាក់ទៅបន្តការសិក្សាថ្នាក់បរិញ្ញាប័ត្រនៅប្រទេសម៉ាឡេស៊ី និងបណ្តាប្រទេសនៅអារ៉ាប់ ហើយក៏បានជួយសម្រួលដល់ការសិក្សារបស់និស្សិតជាងមួយពាន់នាក់ផ្សេងទៀត ឲ្យទទួលបានការអប់រំនៅក្នុងស្រុកផងដែរ ។ បច្ចុប្បន្ននេះ សមាគមន៍និស្សិតខ្មែរអ៊ីស្លាមមានអាគារពីរខ្នងសម្រាប់សិស្សស្រីនៅមុំព្រះវិហារនៅបឹងកក់ និងនៅជ្រោយចង្វារ ដែលបានផ្តល់ទីកន្លែងស្នាក់នៅដល់សិស្សក្រីក្រចាមជិតពីរយនាក់ ។ ភាគច្រើននៃនិស្សិតទាំងនេះធ្វើការបន្តការសិក្សានៅថ្នាក់បរិញ្ញាប័ត្រនៅសកលវិទ្យាល័យន័រតុន នៅទីក្រុងភ្នំពេញ ក្រោមជំនួយឧបត្ថម្ភរបស់ អាម៉ាត់ យ៉ាស់យ៉ា នៃសមាគមអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម ។

តាមរយៈយោបល់ និងចំណេះដឹងដែលទទួលបាននៅក្នុងដំណើរការនៃការកសាងសង្គមចាម សមាគមនិស្សិតខ្មែរអ៊ីស្លាមបានពង្រីកវិសាលភាពរបស់ខ្លួនទៅធ្វើការផ្តល់ជំនួយដល់សហគមន៍ចាម លើផ្នែកធំទូលាយជាងមុន ដូចជា ការសាងសង់សាលា វិហារអ៊ីស្លាម និងអណ្តូងទឹក ក៏ដូចជាការផ្តល់សត្វសម្រាប់បូជានៅក្នុងពិធីគុរបាន និងពិធីសាសនាផ្សេងៗ ។ សមាគមនិស្សិតខ្មែរអ៊ីស្លាមក៏បានផ្តល់ថ្នាក់ហ្វឹកហ្វឺនលើជំនាញដូចជាកាត់ដេរ និងកុំព្យូទ័រ ក៏ដូចជាថ្នាក់ហ្វឹកហ្វឺនភាសាអង់គ្លេសផងដែរ ។ ដោយសារតែបេសកកម្មរបស់សមាគមន៍និស្សិតខ្មែរអ៊ីស្លាមមិនមែនក្នុងគោលបំណងសាសនាទើបធ្វើឲ្យសមាគមនេះ មានលទ្ធភាពក្នុងការទទួលបានជំនួយឧបត្ថម្ភមិនត្រឹមតែពីបណ្តាញអ៊ីស្លាមសកលនោះទេ ប៉ុន្តែ ថែមទាំងពីម្ចាស់ជំនួយមិនមែនអ៊ីស្លាមផងដែរ ដែលជាប្រភពជំនួយសម្រាប់អង្គការក្រៅរដ្ឋាភិបាលមិនមែនអ៊ីស្លាម ។

អង្គការក្រៅរដ្ឋាភិបាលចាមស្រដៀងគ្នាមួយ ដែលមានគោលដៅផ្តោតទៅលើការអប់រំនិស្សិតចាមត្រូវបានបង្កើតឡើងដោយ អាម៉ាត់ យ៉ាស់យ៉ា នៅក្នុងឆ្នាំ១៩៩៨ ។ គោលបំណងរបស់សមាគមន៍អភិវឌ្ឍន៍ខ្មែរអ៊ីស្លាម (Cambodian Islamic Development Association) គឺផ្តោតទៅលើការធ្វើឲ្យប្រសើរឡើងវិញនូវការអប់រំបែបវិទ្យាសាស្ត្រ សម្រាប់និស្សិតចាម និងម្យ៉ាងទៀត ទៅលើការធ្វើឲ្យប្រសើរឡើងវិញនូវសុខុមាលភាពរបស់ប្រជាជនចាមជាទូទៅ ។ នាពេលបច្ចុប្បន្ននេះ សមាគមន៍អភិវឌ្ឍន៍ខ្មែរអ៊ីស្លាមមានភាពលេចធ្លោជាងគេ នៅក្នុងការជួយឧបត្ថម្ភនិស្សិតចាមឲ្យទទួលបានការអប់រំថ្នាក់បរិញ្ញាប័ត្រនៅសកលវិទ្យាល័យឯកជនក្នុងស្រុកមួយ (សកលវិទ្យាល័យន័រតុន) ហើយនៅក្នុង ឱកាសកម្រខ្លះទៀត ទៅបន្តការសិក្សានៅប្រទេសម៉ាឡេស៊ី ។ សមាគមអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម បានបង្កើតនូវគម្រោងដែលមាននិរន្តរភាពមួយ ដោយឲ្យនិស្សិតដែលទទួលបានចំណាត់ថ្នាក់ខ្សោយរួមចំណែក បង់ថ្លៃសិក្សាដោយខ្លួនឯងវិញ ។ សម្រាប់និស្សិតក្រីក្រដែលទទួលបានចំណាត់ថ្នាក់ខ្ពស់នៅវិទ្យាល័យ សមាគមនឹងផ្តល់អាហាររូបករណ៍ពេញថ្លៃជូនដល់និស្សិតនោះ ប៉ុន្តែសម្រាប់និស្សិតផ្សេងទៀតគឺគ្រាន់តែទទួលបានអាហាររូបករណ៍មួយផ្នែកតែប៉ុណ្ណោះ ។ ដូចគ្នានឹងសមាគមនិស្សិតខ្មែរអ៊ីស្លាមដែរ គោលដៅចម្បងរបស់សមាគមអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម មិនមែនដើម្បីឃោសនាសាសនាទេ ប៉ុន្តែដើម្បីទំនុកបម្រុងសហគមន៍ចាមតាមរយៈគម្រោងអប់រំ និងសុខុមាលភាពផ្សេងៗ ។

អង្គការមនុស្សធម៌របស់ប្រទេសគុយវ៉ែត មានបំណងធ្វើការទៅលើផ្នែកទាំងពីរ ។ ក្នុងឆ្នាំ១៩៩៦ អង្គការដែលមានឈ្មោះថា ការរស់ឡើងវិញនៃសង្គមកេរដំណែលអ៊ីស្លាម (the Revival of Islamic Heritage Soceity ហៅកាត់ថា RIHS) បានបង្កើតសាលាបឋមសិក្សាដំបូងបង្អស់របស់ខ្លួន នៅចោមចៅនៅទីក្រុងភ្នំពេញ ។ យ៉ាម៉ាល់ យូសុះ ហាតាត (Yamal Yusof Hatat) ដែលជាមេដឹកនាំថ្នាក់តំបន់របស់អង្គការដើម្បីការរស់ឡើងវិញនៃសង្គម កេរដំណែល

អ៊ីស្លាម បានមកដល់ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៩៣ នៅពេលដែលគាត់បានជួបជាមួយ ម៉ាត់ លី ដើម្បីសួរនាំពីតម្រូវការបន្ទាន់ចំបាច់ជាងគេរបស់ជនជាតិចាម ។ ម៉ាត់ លី បានស្នើឲ្យ យ៉ាម៉ាល់ យូសុះ ហាគាត បើកសាលារៀន ក៏ដូចជាផ្តល់ជំនួយមនុស្សធម៌ដល់ជនជាតិចាម ។ ដោយសារតែអំពើប្រល័យពូជសាសន៍នៅកម្ពុជា បូកផ្សំនឹងជម្លោះក្នុងស្រុកជាបន្តបន្ទាប់ ធ្វើឲ្យក្មេងៗកម្ពុជាជាច្រើននាក់បានក្លាយទៅជាកុមារកំព្រា ។ បញ្ហានេះប្រហែលជាត្រូវបានជូនដំណឹងទៅឲ្យ យ៉ាម៉ាល់ យូសុះ ហាគាត ។ ក្នុងអំឡុងពេលប្រាំមួយឆ្នាំនៃការបង្កើតសាលាបឋមសិក្សាដំបូងរបស់ខ្លួន អង្គការដើម្បីការរស់ឡើងវិញនៃសង្គមកេរដំណែលអ៊ីស្លាម បានពង្រីកសាខាជាច្រើននៅតាមបណ្តាខេត្តនានាទូទាំងប្រទេស ហើយថែមទាំងផ្លាស់ប្តូរសាលាបឋមសិក្សានៅទីក្រុងភ្នំពេញឲ្យទៅជាអនុវិទ្យាល័យនៅក្នុងឆ្នាំ២០០០ ផងដែរ ។ នៅឆ្នាំ ២០០៣ សាលានេះបានក្លាយទៅជាវិទ្យាល័យដែលមានឈ្មោះថា វិទ្យាល័យរស្មីអ៊ីស្លាមកម្ពុជា ដែលទទួលសិស្សឲ្យចូលរៀនចាប់ពីថ្នាក់ទី៧ ដល់ទី១២ ដែលមានបង្រៀនទាំងមុខវិជ្ជាបែបវិទ្យាសាស្ត្រ និងសាសនាផងដែរ ។ ទាំងសមាគមន៍អភិវឌ្ឍន៍ខ្មែរអ៊ីស្លាម និងអង្គការដើម្បីការរស់ឡើងវិញនៃសង្គមកេរដំណែលអ៊ីស្លាម គឺជាអង្គការសាឡាហ្វ៊ី (Salafi Organizations) ។

បន្ទាប់មក គេសង្កេតឃើញថាអង្គការចាមហាក់បីដូចជាបានក្លាយជាមានលក្ខណៈប្រព័ន្ធនៅក្នុងគោលដៅរបស់ខ្លួន ហើយមានភាពសប្បុរសជាងមុននៅក្នុងការផ្តល់ជំនួយទៅដល់សហគមន៍ ។ នៅឆ្នាំ១៩៩៧ មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម ត្រូវបានបង្កើតឡើងដោយមេដឹកនាំសំខាន់ៗបីនាក់គឺ កាម៉ារ៉ូឌីន យូសូហ្វ (Kamarud din Yusof) អនាគតម៉ុវ្ទីរបស់សហគមន៍អ៊ីស្លាម ឧស្មាន ហាសាន់ (Osman Hassan) រដ្ឋលេខាធិការនៃក្រសួងការងារ និងជាទីប្រឹក្សាផ្ទាល់របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន សម្រាប់កិច្ចការអ៊ីស្លាម និង ហ្សាការីយ៉ា អាដាម (Zakariya Adam) រដ្ឋលេខាធិការនៃក្រសួងវប្បធម៌ និងសាសនា ។ អ្នកទាំងបីនាក់នេះជាអ្នកគាំទ្ររបស់ចលនា TJ ។ មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម មានគោលបំណងផ្តល់ការអប់រំទាំងបែបវិទ្យាសាស្ត្រ និងសាសនាដល់សហគមន៍ចាម និងចង់ធ្វើឲ្យប្រសើរឡើងវិញនូវសុខុមាលភាពរបស់សហគមន៍ចាមផងដែរ ។ ក្នុងពាក្យពេចន៍របស់លោក ហ្សាការីយ៉ា អាដាម ដែលជាអនុប្រធានរបស់មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម គោលបំណងចម្បង គឺធ្វើឲ្យប្រសើរឡើងវិញនូវជីវភាពរស់នៅប្រចាំថ្ងៃរបស់ជនជាតិចាម ដើម្បីស្វែងរកនូវវិធីដ៏ត្រឹមត្រូវមួយសម្រាប់ជំនឿ និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ ជំនួយឧបត្ថម្ភចម្បងរបស់មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាមបានមកពីប្រភពជំនួយជាច្រើន រួមទាំងបណ្តាប្រទេសនៅអារ៉ាប់, ម៉ាឡេស៊ី, ក្រុមប្រឹក្សាកិច្ចការអ៊ីស្លាមរបស់រដ្ឋថេរីង ហ្គានូ (Terrengganu), ប្រ៊ុយណេ, ឥណ្ឌូនេស៊ី, ជំនួយមូស្លីម (Muslim Aid), ថវិការបស់រដ្ឋាភិបាលកម្ពុជា, និងជំនួយឯកជនផ្សេងទៀត ។ មូលនិធិអភិវឌ្ឍន៍ ខ្មែរអ៊ីស្លាម ក៏ជាអ្នកដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អ៊ីស្លាម និងជាអង្គការដៃគូរបស់គម្រោងអាហារូបករណ៍របស់ធនាគារអភិវឌ្ឍន៍អ៊ីស្លាម សម្រាប់សហគមន៍មូស្លីម នៅបណ្តាប្រទេសដែលមិនមែនជាសមាជិក ។

សូម្បីតែសម្រាប់មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម ការអប់រំនិស្សិតចាមជំនាន់ក្រោយ នៅតែជាអទិភាពខ្ពស់ដដែល ។ កន្លងមកនេះ មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាមបានកសាងសាលារៀនច្រើនជាង១៥ ទៅហើយ ដែលមានកម្មវិធីសិក្សាចម្រុះសម្រាប់កុមារាកុមារីដែលភេទទាំងពីរនេះ ត្រូវបានដាក់នៅដាច់ពីគ្នា ។ សាលារៀនទាំងនេះមានបំពាក់ទៅដោយកុំព្យូទ័រ ហើយថ្នាក់ហ្វឹកហ្វឺនភាសានឹងត្រូវបានបង្រៀនជាភាសាម៉ាឡេ អង់គ្លេស និងអារ៉ាប់ ។ ការស្ទាបស្ទង់មតិជាច្រើនបានបញ្ជាក់ឲ្យឃើញថា កូនសិស្សចូលចិត្តភាសាអង់គ្លេសច្រើនជាងភាសាអារ៉ាប់ និងម៉ាឡេ ដោយសារតែការយល់ដឹងផ្នែកភាសាអង់គ្លេសបានផ្តល់នូវភាពងាយស្រួលជាងគេនៅក្នុងទីផ្សារការងារ ក៏ដូចជាផ្តល់ឱកាសធំទូលាយ ជាច្រើនដល់សិស្សានុសិស្សផងដែរ ។ សាលាទាំងនេះក៏ផ្តល់ការសិក្សាអប់រំចំណេះដឹងទូទៅរហូតដល់ថ្នាក់ទី១២ផងដែរ ។ អេកណេ ដឺ ហ្វ៊ីអូ (Agne De Feo) បានអះអាងថា សាលារៀន និងសកម្មភាព ភាគច្រើនរបស់មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម យកគម្រូប់តាមការអនុវត្តការអប់រំ និងអភិវឌ្ឍន៍របស់ប្រទេសម៉ាឡេស៊ី ដោយសារតែប្រទេសម៉ាឡេស៊ីមានបទពិសោធន៍ធ្វើឲ្យសាសនាអ៊ីស្លាមរស់ឡើងវិញ និងបញ្ចូលទៅក្នុងថ្នាក់ជាស្ថាប័នផងដែរ តាំងពីទសវត្សរ៍ឆ្នាំ១៩៧០មកម្ល៉េះ ។ ជាការពិតណាស់ ប្រទេសម៉ាឡេស៊ី ផ្តល់នូវ

ឧទាហរណ៍ល្អៗជាច្រើនចេញពីបទពិសោធន៍របស់ខ្លួន ប៉ុន្តែប្រទេសម៉ាឡេស៊ីមានប្រជាជនភាគច្រើនជាអ្នកកាន់សាសនាអ៊ីស្លាម ចំណែកនៅកម្ពុជាវិញ ប្រជាជនមូស្លីមកម្ពុជា គ្រាន់តែជាជនជាតិភាគតិចប៉ុណ្ណោះ ។ សញ្ញាបត្រចេញពីសាលារបស់មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម មានការទទួលស្គាល់ពីសកលវិទ្យាល័យក្នុងស្រុក និងក្រៅប្រទេសមួយចំនួនទៀត រួមទាំងសកលវិទ្យាល័យដ៏ល្បីល្បាញមួយឈ្មោះថា សកលវិទ្យាល័យ Al-Azhar នៅអារ៉ាប៊ីសាអូឌីត និង *(Kolej university Islam Malaysia KUIM)* ។ សិស្សដែលមកពីសាលារបស់មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាមប្រឡងបញ្ចប់ ស្របពេលនឹងការប្រឡងរបស់សាលារដ្ឋនៅទូទាំងប្រទេសដែរ ។

នៅពាក់កណ្ដាលឆ្នាំ ២០១១ មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម ទទួលបានគម្ពីរគួរអាន *(Quran)* ដល់ទៅ១ម៉ឺន២រយក្បាល ដែលសរសេរជាភាសាម៉ាឡេ និងកម្រាលសម្រាប់ថ្វាយបង្គំជាង១ពាន់ពីសំណាក់រដ្ឋមន្ត្រីក្រសួងការពារជាតិម៉ាឡេស៊ី គឺលោកបណ្ឌិតអាម៉ាត់ អាហ៊ីដ ហាមីឌី *(Ahmad ahid Hamidi)* ។ នៅក្នុងខែកញ្ញាឆ្នាំ២០១១ គេមានគម្រោងមួយធ្វើការបោះពុម្ពគម្ពីរគួរអាន១០ម៉ឺនក្បាល បន្ថែមទៀតដែលបកប្រែជាភាសាខ្មែរ ។ ការងារបកប្រែបានចប់សព្វគ្រប់ ហើយការចែកចាយ និងចាប់ផ្ដើមធ្វើឡើងនៅក្នុងឆ្នាំ២០១២ ហើយនឹងបន្តចែកចាយរយៈពេលប្រាំឆ្នាំ ។ នាពេលបច្ចុប្បន្ននេះ ក្នុងចំណោមគ្រួសារចាមចំនួន៦គ្រួសារនៅកម្ពុជា មានគម្ពីរគួរអានតែមួយក្បាលប៉ុណ្ណោះ ។ ការចែកចាយនេះ បានបង្ហាញពីការផ្ដោតទៅលើការលើកកម្ពស់ការគោរពសាសនា និងពីការយកចិត្តទុកដាក់ពីសំណាក់ស្ថាប័នម៉ាឡេស៊ីនានាជាពិសេស ក្រសួងការពារជាតិដែលជាប្រភពជំនួយមួយដ៏កម្រ ។

ក្រសួងនេះ ក៏បានបង្កើតជាកម្មវិធីទាយជ្ជទានគួរអានពិភពលោក *(World Quran Endowment Program)* ដែលទទួលបានជំនួយឧបត្ថម្ភពីប្រភពសាធារណៈ ក៏ដូចជាឯកជន ជាពិសេសជនជាតិម៉ាឡេស៊ីដែរ ។ ការបោះពុម្ពផ្សាយគម្ពីរគួរអានជាភាសា



ជនជាតិចាមអានគម្ពីរគួរ៉ាអាន មុននឹងចូលសូត្រធម៌នៅវិហារ

ខ្មែរ គឺជាកិច្ចសហការរវាងកម្មវិធីទាយជ្ជទាន គួរអានពិភពលោក និងមូលនិធិយ៉ាយ៉ាសាន់ រេស្ទូ *(Yayasan Restu Foundatiom)* ។

ថ្មីៗនេះ មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាមបានសម្លឹងមើលជ្រៅជាងនេះដោយក្រឡេកមើលទៅលើការអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មសម្រាប់ជនជាតិចាម ។ ជាថ្មីម្តងទៀត មូលនិធិនេះសង្ឃឹមថា នឹងទទួលបានកិច្ចសហប្រតិបត្តិការពីម៉ាឡេស៊ី ។ នៅពាក់កណ្តាលឆ្នាំ២០១១ មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម និងស្ថាប័នហិរញ្ញវត្ថុម៉ាឡេស៊ីឈ្មោះយ៉ាយ៉ាសាន់ រេស្ទូ បានព្រមព្រៀងលើសកម្មភាពថ្មីមួយ ដើម្បីធ្វើការបង្កើតសហគ្រាសមីក្រូហិរញ្ញវត្ថុមួយ ជាមួយនឹងដើមទុនដែលមានទឹកប្រាក់ ១លានដុល្លារ ក្នុងគោលបំណងផ្តល់ប្រាក់កម្ចីដល់សហគ្រាសអ៊ីស្លាមខ្នាតតូច និងមធ្យម ។ គួរឲ្យកត់សម្គាល់ផងដែរថា វិស័យធនាគារនៅកម្ពុជានៅតែកំពុងអភិវឌ្ឍន៍នៅឡើយ ប៉ុន្តែស្ថាប័នមីក្រូហិរញ្ញវត្ថុមានការរីកលូតលាស់យ៉ាងខ្លាំង ។ បច្ចុប្បន្ននេះ ក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសមានរហូតដល់ទៅជាងម្ភៃ ។

សមាគមន៍សុខុមាលភាពអ៊ីស្លាមកម្ពុជា *(Islamic Medical Association of Cambodia* ឬហៅកាត់ថា *IMAC)* បានមកដល់ក្រោយគេបន្តិច ។ បង្កើតឡើងនៅក្នុងឆ្នាំ២០០១ សមាគមនេះទទួលជំនួយមួយផ្នែកពីធនាគារអភិវឌ្ឍន៍អ៊ីស្លាម ។ សកម្មភាពចម្បងៗរបស់សមាគមនេះ រួមមានការផ្តល់ជំនួយសុខភាពចល័តដោយឥតគិតថ្លៃ នៅតាមតំបន់ជនបទ ក៏ដូចជាសាងសង់គ្លីនិកតូចៗនៅតាមមូលដ្ឋាន ។ អង្គការក្រៅរដ្ឋាភិបាលមួយទៀតដែលបង្កើតឡើងថ្មីៗនេះគឺសម្ព័ន្ធបញ្ញវន្តមូស្លីមកម្ពុជា *(Cambodian Muslim Intel lectual Alliance)* ។ សម្ព័ន្ធនេះមានគោលបំណងធ្វើឲ្យប្រសើរឡើងវិញនូវការអប់រំ សុខុមាលភាព និងការយល់ដឹងអំពីសហគមន៍អ្នកកាន់សាសនាអ៊ីស្លាមនៅកម្ពុជា ។ នៅខែកុម្ភៈ ឆ្នាំ២០១២ តាមរយៈសម្ព័ន្ធបញ្ញវន្តមូស្លីមកម្ពុជា អង្គការមនុស្សធម៌ម៉ាឡេស៊ីជាច្រើនបានផ្តល់ស្បៀងអាហារ និងជំនួយជាទឹកប្រាក់ដល់កុមារកំព្រាចំនួន៧២នាក់ ។ អង្គការទាំងនេះរួមមាន *GPM, Wadah, FGN, PKPIM, Hayrat, ABIM, KBI, TAQMIR* និង *Open University Malaysia* ។ សិស្សម្នាក់ៗទាំង៧២នាក់នោះ ទទួលបានទឹកប្រាក់ប្រាំរយដុល្លារជារៀងរាល់ឆ្នាំដើម្បីផ្គត់ផ្គង់ការសិក្សារបស់ពួកគេ ។

អង្គការរបស់អារ៉ាប៊ីសាអ៊ូឌីត ដែលរួមទាំងអង្គការអន្តរជាតិអ៊ុមអាល់គូរ៉ា *(Omal-Qura International Organization)* មូលនិធិអន្តរជាតិអាល់បាសា *(Al-Basar International Foundation)* សភាពិភពលោកនៃយុវជនកាន់សាសនាអ៊ីស្លាម *(World Assembly of Muslim Youths)* អង្គការផ្តល់ជំនួយសង្គ្រោះបន្ទាន់អ៊ីស្លាមអន្តរជាតិ *(International Islamic Relief Organization)* និងមូលនិធិអាល់ហារ៉ាម៉ាយន៍ *(Al-Haramayn Foundation)* ។ អង្គការអន្តរជាតិអ៊ុមអាល់គូរ៉ា បានមកដល់នៅឆ្នាំ១៩៩៨ បានជាប់ផុងនៅក្នុងការចោទប្រកាន់អំពីភេរវកម្ម ។ អង្គការនេះបានបង្កើតសាលាមួយនៅខេត្តកណ្តាល ដែលត្រូវបានបិទនៅក្នុងឆ្នាំ២០០៣ ពីបទបានផ្តល់ជម្រកសុវត្ថិភាពដល់ហាំបាលី និងអ្នករួមគំនិត ។ សព្វថ្ងៃនេះ សាលានេះត្រូវបានតុបតែងសាជាថ្មី និងដាក់ឈ្មោះថ្មីថា ជាមជ្ឈមណ្ឌលអ៊ីស្លាមកម្ពុជា *(Cambodian Islamic Center)* ។ សាលានេះត្រូវបានគ្រប់គ្រងដោយផ្ទាល់ ដោយក្រុមប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុកកិច្ចការសាសនាអ៊ីស្លាម និងបានផ្តល់ការអប់រំទាំងសាសនា និងវិទ្យាសាស្ត្រ ។ អ្នកគោរពសាលាហ្វ៊ីប៊ីបួន បានប្រាប់អ្នកនិពន្ធថា ហេតុការណ៍កាលពីឆ្នាំ២០០៣ គឺជាការព្យាយាមរបស់អ្នកគោរព *TJ* ដើម្បីរារាំងការរីកចម្រើនរបស់សាលាហ្វ៊ី ។ សភាពិភពលោកនៃយុវជនកាន់សាសនាអ៊ីស្លាម បានមកដល់កម្ពុជានៅឆ្នាំ២០០២ ។ អង្គការទាំងនេះ បាននាំយកមកនូវការបង្រៀនសាលាហ្វ៊ីមកឲ្យជនជាតិចាម ។

នៅពេលធ្វើការស្រាវជ្រាវនេះ អ្នកនិពន្ធរាប់បានស្ទើរតែ៣០នៃអង្គការស៊ីវិល មូលនិធិ និងសមាគម ។ បើទោះបីជាអង្គការសមាគមទាំងនេះ បម្រើឲ្យគោលបំណងសប្បុរសធម៌សម្រាប់សហគមន៍ចាម និងអ្នកកាន់សាសនាអ៊ីស្លាមផ្សេងទៀត ពួកគេត្រូវបានបែងចែកជាទស្សនវិជ្ជាពីរដាច់ពីគ្នា ៖ ចលនា *TJ* និងការនិយមសាលាហ្វ៊ី ។ ការប្រកួតប្រជែងគ្នារវាងក្រុមទាំងពីរនេះ ជួនកាលបាននាំឲ្យមានការបែកបាក់ និងជម្លោះនៅក្នុងចំណោមជនជាតិចាម ។ នៅភូមិឃ្សាំងស្បែក ជនជាតិចាមបានបំពានក្បួនច្បាប់សម្រាប់ការសាងសង់ព្រះវិហារសាសនាអ៊ីស្លាម ដោយការសាងសង់ព្រះវិហារសាសនាអ៊ីស្លាមពីរដែលមានចម្ងាយត្រឹមតែ២៥០ម៉ែត្រពីគ្នា ។ ព្រះវិហារសាលាហ្វ៊ីមានឈ្មោះថា អាល់ អាក់បា ខូបៃ ឃ្សាំង

ស្បែក ត្រូវបានសាងសង់ដោយជំនួយពីឌូបៃ នៅលើទីតាំងព្រះវិហារចាស់ ។ ព្រះវិហារថ្មីដែលបម្រើឲ្យអ្នកគោរពតាមសាលាហ៊ី មានឈ្មោះថា អាល់ ហ៊ីដាយ៉ា ។ ជម្លោះសាសនា រវាងអ្នកគោរពតាមសាលាហ៊ី និង *TJ* បានថមថយវិញនៅក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ ។ នៅក្នុងទសវត្សរ៍១៩៩០ ក្រុមទាំងពីរនេះមិនបាននិយាយរកគ្នាទេ ។

ស្ថាប័នទាំងនេះ មិនត្រឹមតែនាំយកនូវជំនួយ និងឥទ្ធិពលអ៊ីស្លាមសកលមកកម្ពុជាទេ ថែមទាំងចំណេះដឹងនៅនឹងកន្លែងពីកម្ពុជាទៅវិញ ជាឧទាហរណ៍សិក្សាមួយសម្រាប់សហគមន៍សកល ។ ឧទាហរណ៍ហិរញ្ញប្បទានខ្នាតតូចអ៊ីស្លាមរវាងមូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម និងមូលនិធិយ៉ាយ៉ាសាន់ រេស្វ នឹងក្លាយជាមេរៀនល្អមួយសម្រាប់ការអនុវត្តនៅក្នុងប្រទេសផ្សេងទៀត ជាពិសេសប្រទេសដែលមានអ្នកកាន់សាសនាអ៊ីស្លាមជាជនជាតិភាគតិច ។ តាមរយៈស្ថាប័នទាំងនេះ ជនជាតិចាមអាចទំនាក់ទំនងជាមួយបងប្អូនអ្នកកាន់សាសនាអ៊ីស្លាមផ្សេងទៀតនៅក្នុងសកលលោក នៅពេលធ្វើធម្មយាត្រាទៅកាន់ក្រុងម៉ាកាស ការអប់រំរបស់ពួកគេនៅក្នុងប្រទេសអ៊ីស្លាមទាំងនោះ ទំនាក់ទំនងពាណិជ្ជកម្មរបស់ពួកគេ និងចែករំលែកទុក្ខវេទនានៅពេលសង្គ្រាម និងវិបត្តិ ។ ក្នុងនាមជាអ្នកកាន់សាសនាអ៊ីស្លាម និងទទួលបានជំនួយយ៉ាងច្រើនពីពិភពអ្នកកាន់សាសនាអ៊ីស្លាម ជនជាតិចាមជានិច្ចកាល នឹងមានទំនាក់ទំនងខាងកិច្ចការសាសនាអ៊ីស្លាមនៅក្នុងប្រទេសផ្សេងទៀត ដែលរួមទាំងការវាយប្រហារថ្ងៃ១១ ខែកញ្ញា ការបំផ្ទុះគ្រាប់បែកនៅបាលី អន្តរាគមន៍សហរដ្ឋអាមេរិក ក្រោយពីនោះមកនៅអាហ្វហ្គានីស្ថាន និងអ៊ីរ៉ាក់ និងថ្មីៗបំផុតនេះ ភាពច្របូកច្របល់នយោបាយ នៅអេហ្ស៊ីប ស៊ីរី និងលីប៊ី ។

អ្នកជូនដំណឹងពីរបីនាក់របស់ខ្ញុំ ទទួលបានការអប់រំពីលីប៊ី ។ ពួកគេមានទំនាក់ទំនងទៅនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅប្រទេសនោះ បើទោះបីជាថាតើពួកគេបានផ្តល់ការគាំទ្រដល់ក្រុមបះបោរ ដែលថ្មីៗនេះ បានផ្តួលរំលំរបបវរសេនីយឯក មូអាម៉ា ហ្កាដាហ៊្វី (Colonel Muamma Gaddafi) ។ ពួកគេមានគំនិតផ្ទាល់ខ្លួនអំពីនយោបាយសហរដ្ឋអាមេរិក និងអឺរ៉ុប នៅក្នុងប្រទេសលីប៊ី ខ្មែរដែលជាជនភាគច្រើនហាក់បីដូចជាមិនចាប់អារម្មណ៍ដូចឲ្យជនជាតិចាមសោះ ។ ដូច្នេះ ជនជាតិចាម បាននាំយកកិច្ចការសាសនាអ៊ីស្លាមសកលមកកម្ពុជា និងបានដើរតួនាទីកាន់តែច្រើនជាងមុននៅក្នុងកិច្ចការទាំងនេះ ។ នៅពេលធ្វើដូច្នេះ ពួកគេបានបង្កើនភាពជាប់ពាក់ព័ន្ធនៃកម្ពុជានៅក្នុងសកលលោក តាមរយៈទំនាក់ទំនងឆ្លងព្រំដែន ។

## ៣) ទំនាក់ទំនងនយោបាយថ្នាក់មូលដ្ឋាន

នៅក្នុងរបបលន់ នល់ ជនជាតិចាមត្រូវបានបែងចែករវាងអ្នកទីក្រុង និងជនបទ ។ អ្នកដែលរស់នៅទីក្រុង ចូលរួមជាមួយរបបសាធារណរដ្ឋខ្មែរថ្មី ខណៈដែលអ្នករស់នៅតាមជនបទចូលរួមក្នុងចលនាកុម្មុយនីស្ត ដែលដឹកនាំដោយខ្មែរក្រហម ។ ទំនាក់ទំនងរបស់ពួកគេទៅចលនាទាំងនេះ អាស្រ័យទៅលើទីតាំងរស់នៅរបស់ពួកគេ ។ ដោយសារជនជាតិចាម ជាអ្នកគាំទ្រព្រះបាទនរោត្តមសីហនុ កាលពីទសវត្សរ៍១៩៥០ និង១៩៦០ និង ដោយសារតែទំនាក់ទំនងរឹងមាំរបស់ពួកគេជាមួយព្រះបរមរាជវាំងជនជាតិចាមនៅតំបន់ដាច់ស្រយាល មានជម្រើសតិចតួចប៉ុណ្ណោះ ក្រៅពីចូលរួមជាមួយខ្មែរក្រហម ។ ឧទាហរណ៍ល្អមួយ គឺ សុះ ម៉ាន ដែលជាអ្នកបដិវត្តន៍ចំណានមួយរូប ។ កូនប្រុសរបស់គាត់ ឈ្មោះ ម៉ាត់ លី ក៏បានចូលរួមជាមួយខ្មែរក្រហមដែរ ។ វាហាក់បីដូចជាថា ជនជាតិចាមមិនមានជម្រើសច្រើនអំពីជម្រើសនយោបាយរបស់ពួកគេទេ នៅពេលនោះ ។

យោងទៅតាម កែវ អ៊ីប្រូហ៊ីម អាយុ៦៣ឆ្នាំ សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក ជនជាតិចាមជាច្រើននៅទីក្រុង ព្រួយបារម្ភបំផុតចំពោះខ្មែរក្រហម ដែលបានហាមឃាត់ការប្រតិបត្តិសាសនាអ៊ីស្លាមនៅពេលឡើងកាន់អំណាច ។ កែវ អ៊ីប្រូហ៊ីម ជាកូនប្រុសរបស់ជនជាតិចាមមានទ្រព្យសម្បត្តិ និងកិត្តិយសម្នាក់នៅខេត្តកំពង់ចាម មានឈ្មោះថា ហាជី អូស្មាន់ផុង ឈ្មោះក្នុងព្រះបរមរាជវាំងផ្លូវការរបស់គាត់ គឺ បូតេ សេនា ដាក់ឲ្យដោយព្រះបាទស៊ីសុវត្ថិ ។ គិតម្តងទៀតទៅ គាត់និយាយត្រឹមត្រូវ ។ គាត់បាននិយាយថា នៅអំឡុងពីឆ្នាំ១៩៧០ ដល់១៩៧៥ ជនជាតិចាមមួយចំនួនធំ ស្ថិតនៅក្នុងជួរទ័ពរបស់សាធារណរដ្ឋខ្មែរ តាមរយៈការចាប់ទាហាន និងតាមការស្ម័គ្រចិត្ត ។ កែវ អ៊ីប្រូហ៊ីម ខ្លួនឯងផ្ទាល់ ជាឧត្តមសេនីយ ទទួលបន្ទុកភស្តុភារ ។ នៅពេលបច្ចុប្បន្ន ចៅប្រុសរបស់គាត់ម្នាក់ ជាឧត្តមសេនីយផ្កាយពីរ នៅខេត្តព្រះវិហារ ទីកន្លែងដែលមានជម្លោះព្រំដែនជាបន្តបន្ទាប់រវាងប្រទេសកម្ពុជា និងថៃ និងម្នាក់ទៀត ជាឧត្តមសេនីយ៍

ផ្កាយបីនៅក្រសួងមហាផ្ទៃ ។ ប៉ុន្តែ កែវ អ៊ីប្រហ៊ីម មិនបាននិយាយដល់ចំនួនជនជាតិចាមទាំងអស់នៅក្នុងជួរទ័ពសាធារណរដ្ឋខ្មែរទេ បើទោះបីជាកងវរសេនាតូចរបស់ ឡេះ កូសេម មានឈ្មោះល្បីល្បាញដោយសារជំនាញបច្ចេកទេស និងភាពក្លាហាន ។ ពួកគេទទួលបានជោគជ័យនៅលើសមរភូមិជាច្រើន ។ នៅអំឡុងពេលនោះ វាច្បាស់ណាស់ថា ជនជាតិចាមបានប្រយុទ្ធគ្នាទៅវិញទៅមក នៅក្នុងជម្លោះនៅពេលនោះ ។

នៅក្នុងទសវត្សរ៍១៩៨០ មិនមានជម្រើសច្រើនសម្រាប់ជនជាតិចាមរស់នៅក្នុងប្រទេសកម្ពុជាទេ ។ ម៉ាត់ លី ជាជនជាតិចាមលេចមុខលេចមាត់ម្នាក់នៅក្នុងរដ្ឋាភិបាលរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ គាត់កាន់បីបួនតំណែងក្នុងរដ្ឋាភិបាល ក៏ដូចជានៅក្នុងកិច្ចការសាសនាអ៊ីស្លាមនៅក្នុងប្រទេសកម្ពុជា ។ ដោយសារសាធារណរដ្ឋប្រជាមានិតកម្ពុជា អនុញ្ញាតឲ្យមានតែគណបក្សតែមួយដែលមានឈ្មោះថា បក្សប្រជាជនបដិវត្តន៍ខ្មែរ គេអាចអះអាងថា ជនជាតិចាមស្ទើរតែទាំងអស់ជាសមាជិករបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ បើទោះបីជាព្រះបាទនរោត្តម សីហនុ ដែលជារាជវង្សមួយរូប ដែលបានឱបក្រសោបចាម ជាសមាជិករបស់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ដែលមានសម្ព័ន្ធភាពជាមួយខ្មែរក្រហម ។ នេះគឺជាការក្រឡាប់ចាក់មួយខាងផ្នែកនយោបាយ ។ ខណៈដែលកាលពីអតីតកាល ជនជាតិចាមគាំទ្រក្រុមគ្រួសារញាតិវង្ស ប៉ុន្តែនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ជនជាតិចាមបានគាំទ្របក្សប្រជាជនបដិវត្តន៍ខ្មែរ និងក្រោយមកបក្សប្រជាជនកម្ពុជា ។ ប្រហែលជាដោយសារតែទំនាក់ទំនងរបស់ចាម ជាមួយបក្សមិនមែនរាជវង្សអស់រយៈពេលច្រើនជាងមួយទសវត្សរ៍ ជាមួយនឹងការយល់ឃើញរបស់ពួកគេ អំពីការរំដោះចេញពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ភាគច្រើននៃជនជាតិចាមសព្វថ្ងៃនេះ ជាសមាជិករបស់បក្សប្រជាជនកម្ពុជា ។ ប៉ុន្តែ កាលពីទសវត្សរ៍១៩៩០ នៅពេលបោះឆ្នោតរវាងគណបក្សធំពីរ គឺបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ជនជាតិចាមមានការបែកបាក់គ្នាខាងផ្នែកនយោបាយ ។ នៅក្នុងបរិយាកាសនយោបាយបច្ចុប្បន្ននេះ គណបក្សហ៊្វុនស៊ិនប៉ិច ស្ទើរតែលែងមានដំណើរការទាំងស្រុង ហើយបក្សប្រជាជនកម្ពុជាទទួលបានអំណាចកាន់តែធំ និងកាន់តែមានភាពស្របច្បាប់ជាងកាលពីសម័យបោះឆ្នោត ដែលរៀបចំដោយអ៊ុនតាក់កាលពីឆ្នាំ១៩៩៣ ។

ការមកដល់របស់អ៊ុនតាក់នៅក្នុងឆ្នាំ១៩៩១ បាននាំមកជាមួយនូវអ្នកនយោបាយចាមបីបួននាក់ ដែលជាសមាជិករបស់គណបក្សហ៊្វុនស៊ិនប៉ិច ដែលដឹកនាំដោយ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ (ដែលជារាជបុត្ររបស់ព្រះបាទនរោត្តមសីហនុ) ។ នៅពេលនោះ មានតែបក្សធំៗពីរប៉ុណ្ណោះ៖ គណបក្សហ៊្វុនស៊ិនប៉ិច និងបក្សប្រជាជនកម្ពុជា ។ សម រង្ស៊ី ជាសមាជិកមួយរូបរបស់គណបក្សហ៊្វុនស៊ិនប៉ិច និងបានក្លាយជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ ។ ជនជាតិចាមទាំងនោះ ប្រហែលជាបានចូលរួមបក្សរាជវង្ស ដោយសារបក្សនេះមានមូលដ្ឋាននៅតាមព្រំដែន ។ មូលហេតុមួយទៀត ប្រហែលជាទំនាក់ទំនងរបស់ជនជាតិចាមទាំងនេះ ជាមួយ ម៉ារី រណឫទ្ធិ ដែលជាអតីតមហេសីរបស់សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ដែលជាកូនកាត់ខ្មែរ-ចាម និងដែលធំដឹងក្តី នៅជ្រោយចង្វារ ក្រុងភ្នំពេញ ។ គាត់បានក្លាយជាប្រធានកាកបាទក្រហមកម្ពុជាចាប់ពីឆ្នាំ១៩៩៥ ដល់១៩៩៨ ។ វត្តមានរបស់គាត់នៅក្នុងគ្រួសាររាជវង្ស បានបន្ថែមនូវទំនាក់ទំនងមួយកម្រិតថែមទៀតរវាងជនជាតិចាម និងព្រះបរមរាជវាំង ដែលទំនាក់ទំនងនេះមានចាប់តាំងពីឆ្នាំ១៨៧១ នៅពេលដែលជនជាតិចាម បានផ្លាស់ទីលើកដំបូងមកកាន់ប្រទេសកម្ពុជា ។ ព្រះបាទរាមាធិបតីទី១ ក៏មានព្រះមហេសីជាជនជាតិចាមដែរ ។

ជនជាតិចាមដែលសំខាន់បំផុតនៅក្នុងគណបក្សហ៊្វុនស៊ិនប៉ិច គឺ តុល ឡោះ ទទួលអនិច្ចកម្មហើយ ដែលបន្ទាប់ពីការប្រយុទ្ធគ្នាកាលពីខែកក្កដា ឆ្នាំ១៩៩៧ បានក្លាយជាអគ្គលេខាបក្ស ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ តុល ឡោះ បានក្លាយជារដ្ឋមន្ត្រីក្រសួងអប់រំ ។ នៅពេលកាន់តំណែងនេះ គាត់បានព្យាយាមនាំយកនូវការផ្លាស់ប្តូរធំដល់ប្រព័ន្ធអប់រំពីថ្នាក់វិទ្យាល័យទៅដល់កម្រិតសកលវិទ្យាល័យ នៅក្នុងទម្រង់នៃការប្រលងតឹងរឹងមួយដែល ៩០ភាគរយនៃសិស្សដែលបានចូលរួមប្រលង បានប្រលងធ្លាក់ ។ នៅឆ្នាំ២០០២ តុល ឡោះ ជាឧបនាយករដ្ឋមន្ត្រី ។ គាត់ជាសមាជិកស្មោះត្រង់មួយរូបរបស់បក្សរាជវង្សមួយនេះ ប៉ុន្តែ មិនសូវនិយាយស្តីនៅក្នុងវេទិកាសាធារណៈទេ ។ សមាជិកជនជាតិ

ចាមមួយរូបទៀតរបស់គណបក្សហ៊្វុនស៊ិនប៉ិច និយាយជាសាធារណៈច្រើនជាងនេះ ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ អាម៉ាត់ យ៉ាស់យ៉ា ជាតំណាងរាស្ត្រនៅក្នុងបក្ស ។ ក្នុងនាមជាសមាជិកសភា គាត់ត្រូវបានគេស្រង់សម្តីជាច្រើនលើកច្រើនសា ទាំងនៅក្នុងសារព័ត៌មានក្នុងស្រុក និងអន្តរជាតិ ស្តីអំពីបញ្ហាច្បាប់ និងនយោបាយ ។

មានកំណើតនៅខេត្តកំពង់ចាមនៅឆ្នាំ១៩៤៥ អាម៉ាត់ យ៉ាស់យ៉ា បានស្វែងរកការជ្រកកោននៅប្រទេសបារាំង និងសហរដ្ឋអាមេរិកនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ និងជាអ្នកគាំទ្រហ៊្វុនស៊ិនប៉ិចនៅក្នុងទសវត្សរ៍ឆ្នាំ៨០ នៅពេលគណបក្សនេះកំពុងមានទីតាំងនៅតាមព្រំដែនកម្ពុជា-ថៃនៅឡើយ ។ នៅឆ្នាំ១៩៩២ អាម៉ាត់ យ៉ាស់យ៉ា ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងការិយាល័យសម្របសម្រួលនយោបាយ ។ នៅអំឡុងពេលបោះឆ្នោតដែលឧបត្ថម្ភដោយអង្គការសហប្រជាជាតិនៅខែឧសភា ឆ្នាំ១៩៩៣ គាត់ជាតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចនៅទីក្រុងភ្នំពេញ ដែលបន្ទាប់ពីនោះមក គាត់ឈ្នះកៅអីសភាមួយអាសនៈ ។ នៅពេលរដ្ឋសភាត្រូវបានបង្កើតឡើង គាត់ត្រូវបានតែងតាំងជាប្រធានគណៈកម្មការទទួលបន្ទុកកិច្ចការសាធារណការដឹកជញ្ជូន ទំនាក់ទំនងខ្សែរាហកម្ម ឋាមពល និងពាណិជ្ជកម្ម ។ គាត់ក៏ជាសមាជិកគណៈកម្មការទទួលបន្ទុកនីតិវិធីរដ្ឋសភា ។ បន្ទាប់ពីការវាយប្រហារថ្ងៃ៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ អាម៉ាត់ យ៉ាស់យ៉ា បានភៀសខ្លួនទៅកាន់ប្រទេសថៃ និងត្រឡប់មកវិញក្នុងឆ្នាំ១៩៩៨ នៅតែជាសមាជិកគណបក្សហ៊្វុនស៊ិនប៉ិចដដែល ។ គាត់បានចុះចូលជាមួយគណបក្សសមរង្ស៊ីវិញនៅខែមីនា ឆ្នាំ២០០៣ ហើយបន្ទាប់ពីនោះមក សមាជិកបក្សសំខាន់ៗចំនួន៧នាក់ទៀតក៏បានចុះចូលដែរ បួនខែមុនបោះឆ្នោតជាតិ ។ គាត់ត្រូវគេស្រង់សម្តីថា "ខ្ញុំមិនមានសង្ឃឹមចំពោះព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ហើយជាចុងក្រោយខ្ញុំសប្បាយចិត្តដែលបានចូលរួមជាមួយគណបក្សសមរង្ស៊ី" ។ ក្រោយមកទៀត គាត់បានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ។ សព្វថ្ងៃនេះ គាត់ជារដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងជាតំណាងរាស្ត្រប្រចាំខេត្តកំពង់ចាម ក្នុងនាមជាសមាជិកគណបក្សប្រជាជនកម្ពុជា ។ នៅពេលព្រះបាទនរោត្តមសីហនុ បានយាងត្រឡប់មកប្រទេសវិញក្នុងឆ្នាំ១៩៩៣ បើទោះបីជាព្រះអង្គជាសមាជិកគណបក្សហ៊្វុនស៊ិនប៉ិចក៏ដោយ អាម៉ាត់ យ៉ាស់យ៉ា ជំទាស់ទៅនឹងគំនិតអំពីព្រះមហាក្សត្រកាន់អំណាចនីតិប្រតិបត្តិ ។ គាត់បាននិយាយថា "ប្រសិនបើចង់ឲ្យព្រះមហាក្សត្រជាព្រះមហាក្សត្រពិតប្រាកដ ព្រះអង្គមិនត្រូវចូលរួមក្នុងនយោបាយទេ" ។ គាត់ក៏ជាអ្នកជឿជាក់តាមសាលាហ៊ី ។

ជនជាតិចាមផ្សេងទៀតដែលធ្លាប់គាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច រួមមាន ណាន់ ស៊ី ដែលជាអតីត ឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសប្រ៊ុយណេ (មកពីខេត្តកំពង់ឆ្នាំង), ស៊ីត អ៊ីប្រាហ៊ីម, ឡូត វ៉ាន់ម៉ាត់ (ស្លាប់), សាប៊ូ បាចា និង អ៊ីស្មាអែល អូស្មាន់ ។ អ៊ីស្មាអែល អូស្មាន់ ជាអ្នកនយោបាយសកម្មម្នាក់ ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ គាត់ជាអនុរដ្ឋលេខាធិការក្រសួងសាសនា ។ បច្ចុប្បន្ននេះ គាត់ជាសមាជិកគណបក្សប្រជាជនកម្ពុជា ។ ណាន់ ស៊ី ត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសប្រ៊ុយណេ ។ ជាក់ស្តែង គាត់ត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុកកិច្ចការសាសនាអ៊ីស្លាម និងក្រោយមក ត្រូវបានតែងតាំងដោយរដ្ឋាភិបាល ។ បន្ទាប់ពីនោះមក ដោយមានការអស់សង្ឃឹមពីសំណាក់សហគមន៍ចាមចំពោះការខ្វះការយកចិត្តទុកដាក់របស់ណាន់ ស៊ី ចំពោះសហគមន៍ នៅពេលគាត់កាន់តំណែងជាឯកអគ្គរដ្ឋទូត ។ ថ្មីៗនេះ គាត់ត្រូវបានដកចេញពីតំណែងពីបទចោទប្រកាន់អំពីអំពើពុករលួយលុយមួយចំនួនធំ ។ សំណុំរឿងនេះនៅតែមិនទាន់ត្រូវបានដោះស្រាយ ។

អូស្មាន់ ហាសាន់ និង ហ្សាការីយ៉ា អាដាម គឺជាមេដឹកនាំចាមសំខាន់ពីររូបនៅក្នុងជួរគណបក្សប្រជាជនកម្ពុជា ។ អូស្មាន់ ហាសាន់ កាន់កាប់ក្រុមហ៊ុនឯកជនមួយចំនួន មានអង្គការក្រៅរដ្ឋាភិបាលមួយ ឬច្រើន និងមានកាន់តំណែងនយោបាយ ។ ដូច្នេះគាត់ជាជនជាតិចាមម្នាក់ក្នុងជនជាតិចាមដែលមានទ្រព្យបំផុតនៅកម្ពុជា និងបើតាមការសន្មត ជាអ្នកដែលមានអំណាចបំផុតផងនៅក្នុងចំណោមជនជាតិចាម ។

ជនជាតិចាមស្ទើរតែទាំងអស់ សព្វថ្ងៃនេះ ជាសមាជិករបស់គណបក្សប្រជាជនកម្ពុជា ។ នេះមិនមែនមានន័យថាជនជាតិចាមបានផ្តាច់ការគាំទ្រពីមុនចំពោះញាតិវង្សស្តេចទេ ។ ការពិតទៅគឺថា មិនមានគណបក្សប្រឆាំងដែលដឹកនាំដោយញាតិវង្សស្តេច បើ

ទោះបីជាព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ កំពុងធ្វើឲ្យគណបក្សរបស់ព្រះអង្គរស់ឡើងវិញ និងកំពុងរៀបចំចូលរួមការបោះឆ្នោតជាតិខាងមុខក៏ដោយ ។ គណបក្ស សម រង្ស៊ី នៅតែជាគណបក្សប្រឆាំងដែលរឹងមាំជាងគេដដែល ។ ចាមមួយចំនួនតូចជាសមាជិកគណបក្សនេះដែលរួមទាំង សាឡេះ សាឡះ ដែលកំពុងតែឈរឈ្មោះជាតំណាងរាស្ត្រ ។

អ្នកគាំទ្រម្នាក់របស់គណបក្សប្រជាជនកម្ពុជា មានឈ្មោះថា កាម៉ារូឌីន យូសុះ ដែលត្រូវបានតែងតាំងកាលពីឆ្នាំ២០០១ ជាម៉ុវទី កាន់តំណែងអស់មួយជីវិត ។ នៅពេលសួរថាហេតុអ្វីបានជាគាត់គាំទ្រគណបក្សប្រជាជនកម្ពុជា គាត់ត្រូវបានគេដកស្រង់សម្តីថា “ខ្ញុំជាផ្នែកមួយរបស់គណបក្សប្រជាជន តាំងពីពេលបក្សនេះចាប់ផ្តើមម៉្លេះ ។ សូមអរគុណព្រះជាម្ចាស់ គណបក្សប្រជាជនកម្ពុជាបានក្លាយជាបក្សកាន់អំណាច និងមានសំឡេងគាំទ្រភាគច្រើន ។ ក្នុងនាមជាជនជាតិភាគតិច អ្នកកាន់សាសនាអ៊ីស្លាម ត្រូវការការគាំទ្រពីអ្នកភាគច្រើន ។ សមាជិករបស់ក្រុមជនភាគតិចអាចមករកខ្ញុំគ្រប់ពេលដើម្បីសុំជំនួយ ហើយខ្ញុំអាចស្នើសុំរកជំនួយតទៅរដ្ឋាភិបាល” ។ ពាក្យសម្តីរបស់ម៉ុវទី រូបនេះ ហាក់បីដូចជាបានបង្ហាញយ៉ាងច្បាស់នូវសារសំខាន់នៃយុទ្ធសាស្ត្រដើម្បីរស់របស់ជនជាតិចាមនៅកម្ពុជា ។ ជនជាតិចាមមិនត្រឹមតែសកម្មនៅក្នុងនយោបាយនៅក្នុងរបបនយោបាយ និងគណបក្សនយោបាយជាច្រើនប៉ុណ្ណោះទេ ពួកគេហាក់ដូចជាគាំទ្រស្ថាប័ននយោបាយដែលសមស្របបំផុតទៀតផង ។ ការនេះ បានបង្ហាញឲ្យឃើញនូវចេតនារបស់ពួកគេដើម្បីឲ្យសកម្មគាំទ្រ និងចូលរួមនៅក្នុងកិច្ចការរបស់ប្រទេសកម្ពុជា ប៉ុន្តែ នៅខាងអ្នកដែលមានអំណាចបំផុតនៃនយោបាយកម្ពុជា ។ ដូចដែល ជនជាតិចាមជាច្រើនបានលើកឡើងជាច្រើនដងចាប់តាំងពីសម័យអ៊ុនតាក់មក ជនជាតិចាមមិនមានមហិច្ឆិតាដើម្បីចង់បានស្វយ័តភាពនយោបាយឬគ្រប់គ្រងភាគច្រើននៃរដ្ឋាភិបាលកម្ពុជាទេ ។ ពួកគេភ្ជាប់នឹងកម្ពុជារដ្ឋ និងរដ្ឋាភិបាលកម្ពុជា ប៉ុន្តែក្នុងនាមជាក្រុមជាតិពន្ធុ និងក្រុមសាសនាដោយឡែក ។

គណបក្សប្រជាជនកម្ពុជា បានខិតខំប្រឹងប្រែងដើម្បីធានាឲ្យបាននូវការគាំទ្រពីជនជាតិចាម ។ នៅក្នុងការបោះឆ្នោតជាតិកាលពីឆ្នាំ១៩៩៨ គណបក្សប្រជាជនកម្ពុជាបានដាក់បេក្ខជនចាមចំនួន៧រូបឲ្យឈរឈ្មោះនៅក្នុងមណ្ឌលចំនួន៥ (ដែលមានជនជាតិចាមនិងជ្វា) ភាគច្រើន នៅក្រុងភ្នំពេញ កំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ និងកំពត ដើម្បីប្រកួតប្រជែងដណ្តើមអាសនៈនៅក្នុងរដ្ឋសភាជាតិ ។ ការបញ្ចូលបេក្ខជនចាមនេះ គឺស្របតាមគោលនយោបាយត្រីកោណរបស់គណបក្សប្រជាជនៈ ១) អភិវឌ្ឍន៍ធនធានមនុស្សចាម ២) បង្កើនជីវភាពសម្រាប់ជនជាតិចាម និង ៣) លើកកម្ពស់ និងថែរក្សាទំនៀមទម្លាប់ចាម ។ គោលនយោបាយទាំងនេះ ក៏បានបញ្ចូលផងដែរនូវកិច្ចខិតខំប្រឹងប្រែងពិសេស ដើម្បីបង្កើនការអប់រំនៅក្នុងចំណោមជនជាតិចាមតាមរយៈការកាត់បន្ថយអត្រានៃការបោះបង់ការសិក្សា ។

**(តទៅលេខក្រោយ)**

**អេង កុកថាយ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: truthbunthorn.s@dccam.org*
*Home page: www.dccam.org*

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬកា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល: truthmpechet@dccam.org ។

**◆ទីកន្លែង : អគារ "ក" ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# យុត្តិធម៌អន្តរកាលតាមរយៈការស្តាប់សំឡេងស្ត្រីកម្ពុជា

**(តចប់)**

**៣.៣) ធាតុផ្សំទាក់ទងនឹងសំណង**

នៅក្នុងបរិបទនៃដំណើរការយុត្តិធម៌អន្តរកាល ធាតុផ្សំទាក់ទងនឹងសំណង ត្រូវបានយល់បានថាជាទម្រង់ផ្សេងៗគ្នាដែលរដ្ឋត្រូវទទួលបន្ទុកសង សម្រាប់ការរំលោភសិទ្ធិមនុស្សជារួមដោយរដ្ឋដែលបានកំណត់នៅក្នុងគោលការណ៍ជាមូលដ្ឋាន និងសេចក្តីណែនាំស្តីពីសិទ្ធិទទួលបានសំណងសម្រាប់ជនរងគ្រោះពីការរំលោភច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ "គោលការណ៍ជាមូលដ្ឋាន" ។ បើប្រៀបធៀបនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនរងគ្រោះត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការសវនាការ ប៉ុន្តែគាត់មានសិទ្ធិទទួលបានត្រឹមតែសំណងដែលមានលក្ខណៈសមូហភាព និងសំណងជាការផ្សះផ្សារបួសផ្លូវចិត្តប៉ុណ្ណោះ នៅពេលដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធចំពោះបទឧក្រិដ្ឋដែលបានបង្កព្យសនកម្មដល់ជនរងគ្រោះ ។ ដោយសារតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានសិទ្ធអំណាចតិចជាងទម្រង់ដែលត្រូវបានទទួលស្គាល់នៅក្នុងគោលការណ៍ជាមូលដ្ឋាននៅក្នុងការផ្តល់សំណង ដូច្នេះហើយតុលាការមិនអាចផ្តល់



ប្រជាជនកម្ពុជាដែលនៅរស់រានមានជីវិត បានធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ ក្រោយរបបខ្មែរក្រហមខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩ ។ អ្នករស់រានមានជីវិតទាំងនេះ ភាគច្រើនជាស្ត្រី ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការស្តារជីវភាពគ្រួសារ និងសង្គមឡើងវិញ ។

សំណងជាទឹកប្រាក់សម្រាប់បុគ្គលម្នាក់ៗបានឡើយ ។ មួយវិញទៀត អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្លាប់បានសម្រេចថា តុលាការមិនអាចផ្តល់សំណងប្រឆាំងទៅនឹងរដ្ឋាភិបាលបានឡើយ ប៉ុន្តែគោលការណ៍ជាមូលដ្ឋានទាក់ទងនឹងសំណងបានចែងថា រដ្ឋមានកាតព្វកិច្ចត្រូវផ្តល់សំណង ។

វេទិកាស្តាប់សំឡេងស្ត្រី បានផ្តល់ជាទម្រង់បន្ថែមសម្រាប់ដោះស្រាយ ដើម្បីរួមចំណែកដល់ការស្តារឡើងវិញ និងបំពេញឡើងវិញពីការខូចខាត ។ មនុស្សទាំងអស់ដែលបានផ្តល់សក្ខីកម្មនៅក្នុងវេទិកានេះ ទទួលបានការថែទាំខាងផ្លូវចិត្តទាំងមុនអំឡុងពេល និងបន្ទាប់ពីការចូលរួមរបស់គាត់ដែលបានជួយជំរុញលើកទឹកចិត្តរបស់គាត់ឲ្យជាសះស្បើយពីរបួសផ្លូវចិត្ត ។ មនុស្សម្នាក់ដែលបានផ្តល់សក្ខីកម្មនៅក្នុងវេទិកាស្តាប់សំឡេងរបស់ស្ត្រីថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកនៅក្នុងឆ្នាំ២០១២ បានបង្ហាញពីយោបល់របស់ខ្លួនថា "ខណៈពេលដែលរឿងរ៉ាវរបស់ពួកគាត់ត្រូវបានចែករំលែកជាសាធារណៈ ពួកគាត់មានអារម្មណ៍ថា វាពិតជាលំបាកនៅក្នុងចិត្ត ហើយពួកគាត់មានអារម្មណ៍មួយទៀតថា ចាប់ផ្តើមមានភាពរឹងមាំ និងធូរស្រាលផ្លូវអារម្មណ៍ បន្ទាប់ពីបានចូលរួមក្នុងវេទិកានេះ" ដូចគ្នានេះដែរ នៅក្នុងឆ្នាំ២០១៣ ៖

> *ក្រុមស្ត្រីបាននិយាយថា មុនពេលដែលគាត់ផ្តល់សក្ខីកម្ម គាត់មានអារម្មណ៍ថាអស់សង្ឃឹម និងតូចចិត្តជាពន់ពេក ដោយសារតែកាលពីមុនគាត់មិនមានឱកាសបានចូលរួមដើម្បីមកបកស្រាយអំពីអំពើហិង្សា ដែលគាត់បានទទួលរង ។ គាត់មានអារម្មណ៍សប្បាយរីករាយ ដែលបាននិយាយនៅពីមុខសាធារណជនជាលើកដំបូង ។ បន្ទាប់ពីការចូលរួមនៅក្នុងវេទិកាស្តាប់សំឡេងរបស់ស្ត្រី មនុស្សបួននាក់សម្តែងនូវការធូរស្បើយក្នុងអារម្មណ៍ និងទទួលបានការគាំទ្រពីទស្សនិកជន ជាពិសេសនៅពេលដែលគាត់បានឃើញទស្សនិកជនយំព្រោះតែមានអារម្មណ៍អាណិតគាត់ ។*

អ្នកដែលរស់រានមានជីវិតមួយចំនួន ដែលបានលាតត្រដាងអំពីបទពិសោធន៍ផ្ទាល់ខ្លួនជាលើកដំបូងអំពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ អាចទទួលបានអត្ថប្រយោជន៍ជាច្រើនពីការធ្វើអន្តរាគមន៍ ជាពិសេសចំពោះករណីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ដូចជាក្រុមស្ត្រីជួយខ្លួនឯងជាដើម ។ យោងទៅតាមគោលការណ៍ជាមូលដ្ឋាន ការសងសំណងការខូចខាត គួរតែរួមបញ្ចូលការទទួលស្គាល់ការពិត និងការទទួលខុសត្រូវចំពោះការរំលោភបំពាននានា ។ ចំណុចទាំងពីរនេះត្រូវបានដោះស្រាយដោយវេទិកាស្តាប់សំឡេងរបស់ស្ត្រី ដូចបានរៀបរាប់ខាងលើនៅក្រោមធាតុផ្សំនៃការពិត និងយុត្តិធម៌ ។

ដោយសារគំនិតផ្តួចផ្តើមធ្វើឡើងដោយសង្គមស៊ីវិល និងមានលក្ខណៈឯករាជ្យពីកិច្ចដំណើរការផ្លូវការរបស់តុលាការ វេទិកាស្តាប់សំឡេងរបស់ស្ត្រី មិនអាចផ្តល់សំណងដូចដែលមានកំណត់នៅក្នុងគោលការណ៍ជាមូលដ្ឋាន ឬវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។ ទោះជាយ៉ាងណា វេទិកាស្តាប់សំឡេងរបស់ស្ត្រីអាចជាវេទិកាគំរូសម្រាប់សំណងដែលរៀបចំដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬអាចទទួលយកបានដោយរាជរដ្ឋាភិបាល បរិបទនៃកម្មវិធីសំណងទូទៅមួយ ។ សក្ខីកម្មរបស់ជនរងគ្រោះទាក់ទងទៅនឹងតម្រូវការ និងការស្នើសុំយ៉ាងហោចណាស់ត្រូវបានកត់ត្រាទុកនៅក្នុងអំឡុងពេលនៃវេទិកាស្តាប់សំឡេងស្ត្រីនេះ ។ ប្រធានបទសំខាន់ដែលកំពុងតែអនុវត្ត គឺការកត់ត្រាទុកនូវបទពិសោធន៍របស់ស្ត្រីជាជនរងគ្រោះសម្រាប់ក្មេងជំនាន់ក្រោយសិក្សារៀនសូត្រ និងទប់ស្កាត់អំពើហិង្សាដែលប្រឆាំងលើស្ត្រីនាថ្ងៃអនាគត ។ ការស្នើសុំរបស់ស្ត្រីជាជនរងគ្រោះ អាចនឹងត្រូវប្រើជាមូលដ្ឋានសម្រាប់កម្មវិធីសំណងដែលបញ្ចូលទៅក្នុងការអប់រំមួយ និងការគាំទ្រដល់ការទប់ស្កាត់អំពើហិង្សា និងបញ្ហាយេនឌ័រ ។ ការស្នើសុំមួយទៀត គឺការអំពាវនាវឲ្យបញ្ចប់ការរើសអើងប្រឆាំងនឹងជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទដែលអាចជាគ្រឹះសម្រាប់កម្មវិធីសំណងដែលជួយលើកស្ទួយការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបថ ។

### ៣.៤) ធាតុផ្សំដែលធានាមិនឲ្យមានអំពើបែបនេះកើតឡើងជាថ្មីម្តងទៀត

ធាតុផ្សំដែលធានាមិនឲ្យមានអំពើបែបនេះកើតឡើងជាថ្មីម្តងទៀត ជាចំណុចទាក់ទងនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ស្ថាប័នរដ្ឋដែលរួមបញ្ចូលទាំងកំណែទម្រង់វិស័យសន្តិសុខ និងច្បាប់ដើម្បី

ទប់ស្កាត់អំពើហិង្សាឲ្យបានកាន់តែទូលំទូលាយ និងមានលក្ខណៈជាប្រព័ន្ធនាពេលអនាគត ។ ក្នុងនាមជាហត្ថលេខីនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ រដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចត្រូវលើកកម្ពស់ការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។ នៅក្នុងការអនុវត្តជាក់ស្តែង អំពើហិង្សានៅក្នុងរដ្ឋមួយនៅតែមានជាទូទៅ ហើយការប្រើប្រាស់អំពើហិង្សាដ៏សាហាវនោះ គឺធ្វើឡើងដើម្បីប្រឆាំងនឹងអ្នកតវ៉ាស៊ីវិល ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានមើលឃើញថា ជាសាលាក្តីមួយដែលមានបំណងចង់បង្កើតមូលដ្ឋានសម្រាប់កំណែទម្រង់ប្រព័ន្ធតុលាការ តាមរយៈការអនុវត្តត្រឹមត្រូវតាមនីតិវិធីដើម្បីធ្វើជាតុលាការគំរូសម្រាប់តុលាការជាតិ ។ គម្រោងមួយចំនួនដែលកំពុងត្រូវបានអនុវត្ត គឺធ្វើឡើងក្នុងគោលបំណងដើម្បីចែករំលែកមេរៀនដែលបានសិក្សាទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងគោលការណ៍នៃនីតិរដ្ឋ ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅក្នុងប្រទេសកម្ពុជា បាននាំមុខនៅក្នុងវិស័យនេះ តាមរយៈការរៀបចំកិច្ចប្រជុំតុមូលជាមួយនឹងព្រះរាជអាជ្ញា និងចៅក្រមកម្ពុជា ។ ក្នុងកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានគ្រប់គ្រងបូព៌ាបស្ចិម ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានចេញផ្សាយសេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដោយប្រើប្រាស់សេចក្តីសម្រេចផ្នែកនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានពាក់ព័ន្ធនឹងមាត្រានានាដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។

វេទិកាស្តាប់សំឡេងស្ត្រីទាំងបីលើកបានចេញសេចក្តីថ្លែងការណ៍រួមជាមួយនឹងអនុសាសន៍ទាក់ទងនឹងគោលនយោបាយជាក់ជូនទៅរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត ។ ភាគច្រើននៃអ្នកទាំងនោះ បានរៀបរាប់អំពីវិធានការជាក់លាក់ដែលចាំបាច់ដើម្បីទប់ស្កាត់អំពើហិង្សាផ្សេងទៀតនាពេលអនាគត ជាពិសេសអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ និងដោះស្រាយបុសគល់ដើមនៃការរើសអើងភេទ ។

នៅក្នុងឆ្នាំ២០១១ នៅក្នុងចំណោមវិធានការផ្សេងៗទៀត ក្រុមវាគ្មិនបានផ្តល់អនុសាសន៍ទៅរាជរដ្ឋាភិបាលកម្ពុជាថា គួរជំរុញឲ្យមានលើកស្ទួយការយល់ដឹងជាសាធារណៈ និងបញ្ចូលទៅក្នុងកម្មវិធីសិក្សាអប់រំនៅក្នុងសាលារៀន ដើម្បីលុបបំបាត់ជំនឿដែលនៅជុំវិញអំពើហិង្សាផ្លូវភេទ ។ អនុសាសន៍សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមមានការបង្កើតឲ្យមានអ្នកជំនាញជាន់ខ្ពស់ផ្នែកយេនឌ័រ ដោយសហការជាមួយសមភាគីជាតិដើម្បីតស៊ូមតិឲ្យមានការដាក់បញ្ចូលនូវការផ្សព្វផ្សាយទស្សនៈអំពីយេនឌ័រ និងការយកចិត្តទុកដាក់នឹងអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ហើយចាំបាច់ត្រូវមានការធានាថារឿងទាំងនេះ គឺជាផ្នែកមួយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងច្បាប់ជាតិ ។ មានការអំពាវនាវ



ស្ត្រីកំពុងលក់ដូរនៅផ្សារ ក្រោយរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩ ។ ស្ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងការស្តារជីវភាពគ្រួសារ និងសង្គមឡើងវិញ ។

ឲ្យសង្គមស៊ីវិលជួយលើកកម្ពស់សិទ្ធិអំណាច និងប្រមូលផ្តុំអ្នកដែលរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ដោយការរក្សា និងការកសាងបណ្តាញនៃអ្នកដែលរស់រានមានជីវិត និងការគាំទ្រដល់ការពិភាក្សារបស់គាត់ ។

នៅក្នុងឆ្នាំ២០១២ ក្រុមវាគ្មិនបានផ្តល់នូវអនុសាសន៍សម្រាប់បណ្តាប្រទេសនីមួយៗដែលបានចូលរួម ។ សម្រាប់កម្ពុជា អនុសាសន៍ដែលផ្តល់ទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានស្នើឲ្យបញ្ច្រាបសំណួរទាក់ទងនិងអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ នៅក្នុងការចោទប្រកាន់ផ្សេងទៀតសម្រាប់សំណុំរឿង ០០៣ និង០០៤ ។ ក្រុមវាគ្មិនបានស្នើសុំឲ្យរាជរដ្ឋាភិបាលឲ្យចូលរួមគាំទ្រឯកសារជាប្រវត្តិសាស្ត្រ និងបទពិសោធន៍កាលពីអតីតកាលរបស់ជនរងគ្រោះ និងអ្នករស់រានមានជីវិតដើម្បីបំបែកភាពស្ងៀមស្ងាត់របស់គាត់ក្នុងការជួយព្យាបាលរបួសផ្លូវចិត្ត ។

នៅក្នុងឆ្នាំ២០១៣ វាគ្មិនដែលជាក្រុមនិស្សិតបានបង្ហាញអំពីដំណោះស្រាយទៅមិត្តភក្តិរបស់ខ្លួនដោយអំពាវនាវដល់យុវជនឲ្យចូលរួមក្នុងសកម្មភាពដោះស្រាយអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ដូចជា កម្មវិធីបណ្តុះបណ្តាល វេទិកាសាធារណៈ សិក្ខាសាលា និងដំណើរទស្សនកិច្ចសិក្សាផ្សេងៗទៀត ដើម្បីចែករំលែកព័ត៌មាន ចំណេះដឹង ក្នុងគោលបំណងដើម្បីលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាទាក់ទងនិងយេនឌ័រ ដើម្បីលុបបំបាត់ការរើសអើងដែលប្រឆាំងនឹងជនរងគ្រោះ ដើម្បីកំណត់មិនឲ្យប្រព្រឹត្តទម្រង់នៃអំពើហិង្សាយេនឌ័រណាមួយ និងដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋជាពិសេសក្រុមគ្រួសារ និងមិត្តភក្តិដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងផ្នែកយេនឌ័រ ។

សេចក្តីថ្លែងការណ៍មួយរបស់វាគ្មិនគឺផ្អែកលើការរកឃើញតាមរយៈការផ្តល់សក្ខីកម្មរបស់អ្នកចូលរួម និងពិនិត្យឯកសារឡើងវិញដោយអ្នកជំនាញផ្នែកច្បាប់ និងផ្នែកយេនឌ័រ ។ សេចក្តីថ្លែងការណ៍របស់ក្រុមវាគ្មិនត្រូវបានព្រាងដោយប្រុងប្រយ័ត្ន ហើយសេចក្តីថ្លែងការណ៍នោះ គឺជាធនធានដ៏មានតម្លៃសម្រាប់រាជរដ្ឋាភិបាល និងអាចផ្តល់នូវការណែនាំសម្រាប់ការអនុវត្ត និងសម្រាប់ការធានាមិនឲ្យកើតមានឡើងវិញម្តងទៀត ។ ខុសប្លែកពីកម្មវិធីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលផ្តោតតែទៅលើគោលដៅទាក់ទងនឹងច្បាប់ និងមានការផ្តោតតិចតួចនៅឡើយពាក់ព័ន្ធនឹងការផ្ទេរចំណេះដឹងផ្នែកច្បាប់ សេចក្តីថ្លែងការណ៍របស់វាគ្មិននៅក្នុងវេទិកាស្តាប់សំឡេងស្ត្រីបានជ្រើសយកវិធីសាស្ត្រកម្រិតគោលនយោបាយ ដើម្បីធ្វើការផ្តល់អនុសាសន៍សម្រាប់ការផ្លាស់ប្តូររចនាសម្ព័ន្ធដ៏ធំនេះ ។

នៅក្នុងឆ្នាំ២០១១ ក្រុមវាគ្មិនបានស្នើសុំរាជរដ្ឋាភិបាលកម្ពុជាបង្កើតមូលនិធិថ្នាក់ជាតិមួយសម្រាប់ផ្តល់សំណងជូនជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ។ លើសពីនេះទៅទៀតក្នុងនាមជាប្រធាននៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍នៅក្នុងឆ្នាំ២០១២ រាជរដ្ឋាភិបាលត្រូវបានស្នើសុំឲ្យធ្វើជាអធិបតីភាពនៅក្នុងអំឡុងពេលនៃការបើកសម្ពោធវិទ្យាស្ថានសន្តិភាព និងការផ្សះផ្សា ដើម្បីជាការលើកកម្ពស់ទស្សនៈរឹងមាំផ្នែកយេនឌ័រនៅក្នុងវិទ្យាស្ថាននេះនឹងធានាបានថា បញ្ហារបស់ស្ត្រី រួមមានបញ្ហាសន្តិភាព និងសន្តិសុខ បញ្ហាឧក្រិដ្ឋកម្មផ្លូវភេទទាក់ទងនឹងវិវាទកម្ម ត្រូវបានដោះស្រាយសម្រាប់តំបន់អាស៊ានទាំងមូល និងរក្សាបាននូវភាពជាអ្នកដឹកនាំលើបញ្ហាទាំងអស់នោះក្នុងឋានៈជាសមាជិកមួយរបស់អាស៊ាន ។

នៅក្នុងឆ្នាំ២០១២ ក្រុមវាគ្មិនបានផ្តល់អនុសាសន៍ទាក់ទងការអភិវឌ្ឍន៍យន្តការក្រៅប្រព័ន្ធតុលាការ និងការកសាងសន្តិភាព ដើម្បីផ្តល់ឱកាសជូនជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ និងធ្វើឲ្យសំឡេងរបស់គាត់ត្រូវបានផ្សព្វផ្សាយ និងបើកឲ្យទទួលស្គាល់ជាសាធារណៈសម្រាប់កិច្ចសន្ទនាស្តីពីបញ្ហានៃអំពើហិង្សាយេនឌ័រ ។ ក្រុមវាគ្មិនបានស្នើសុំរាជរដ្ឋាភិបាលឲ្យបង្កើតផែនការសកម្មភាពថ្នាក់ជាតិមួយសម្រាប់អនុវត្តចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិលេខ១៣២៥ និងលេខ១៨២០ ដោយផ្តោតទៅលើស្ត្រីសន្តិភាព និងសន្តិសុខ ដោយសហការជាមួយអង្គការមិនរាជរដ្ឋាភិបាលដែលធ្វើការផ្តោតលើស្ត្រី និងសិទ្ធិមនុស្ស ដោយមានបង្ហាញអំពីពេលវេលាច្បាស់លាស់ និងធនធានគ្រប់គ្រាន់ ។

នៅក្នុងឆ្នាំ២០១៣ វាគ្មិនដែលជាក្រុមនិស្សិតបានស្នើសុំឲ្យដាក់បញ្ចូលបញ្ហាអំពើហិង្សាយេនឌ័រទៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម និងពេលបច្ចុប្បន្នទៅក្នុងកម្មវិធីសិក្សានៃថ្នាក់អនុវិទ្យាល័យ

និងមហាវិទ្យាល័យនានា ។

វេទិកាស្តាប់សំឡេងស្ត្រីនៅក្នុងទម្រង់ដែលកំពុងអនុវត្តនៅក្នុងប្រទេសកម្ពុជា មានលក្ខណៈខុសប្លែកពីគណៈកម្មការស្វែងរកការពិត ព្រោះវេទិកានេះមិនមែនបង្កើតឡើងដោយរដ្ឋ ហើយគោលបំណងដ៏សំខាន់របស់វេទិកានេះ គឺដើម្បីផ្តល់សំឡេងសម្រាប់អ្នកដែលរស់រានមានជីវិតដែលរួចផុតពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ។ យោងតាមមជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល គណៈកម្មការស្វែងរកការពិតមិនមែនជាស្ថាប័នតុលាការទេ តែស្ថាប័នឯករាជ្យមួយដែលបង្កើតឡើងដោយច្បាប់ ឬអនុក្រឹតដែលចេញដោយស្ថាប័ននីតិប្រតិបត្តិ ដើម្បីកំណត់ពីអង្គហេតុ និងបរិបទនៃការរំលោភសិទ្ធិមនុស្ស ឬច្បាប់មនុស្សអន្តរជាតិកាលពីអតីតកាលរបស់ប្រទេសមួយ ។ អាណត្តិរបស់ស្ថាប័នរដ្ឋ មានលក្ខណៈទូលំទូលាយ ដែលអាចគ្របដណ្តប់លើរាល់បទឧក្រិដ្ឋកម្មសម្ងាប់រង្គាលនាពេលកន្លងមក និងអាចស្តាប់សំឡេងរបស់ជនរងគ្រោះ និងជនដែលដល់ក្នុងចំនួនច្រើនលើសលុបបាន ។ នៅក្នុងករណីខ្លះ គណៈកម្មការស្វែងរកការពិតបានបង្កើតសេចក្តីព្រមព្រៀង ចងកាតព្វកិច្ចមួយដោយចែងថា រដ្ឋត្រូវតែអនុវត្ត ហើយនៅក្នុងករណីផ្សេងទៀតរដ្ឋាភិបាលមានកាតព្វកិច្ចរាយការណ៍ជាសាធារណៈស្តីពីស្ថានភាពនៃអនុវត្តនេះ ។ នៅពុំទាន់មានអនុវត្តមុខងារណាមួយក្នុងចំណោមមុខងារទាំងនោះ ត្រូវបានបំពេញដោយវេទិកាស្តាប់សំឡេងស្ត្រីនៅក្នុងប្រទេសកម្ពុជានៅឡើយទេ ។

បន្ថែមពីលើនេះ វេទិកាស្តាប់សំឡេងស្ត្រី ត្រូវបានបង្កើតឡើងដោយឯករាជ្យពីអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ ដោយសារតែស្ថាប័នទាំងពីរត្រូវបានបង្កើតឡើងនៅក្នុងក្របខណ្ឌនៃដំណើរការយុត្តិធម៌អន្តរកាល និងដើម្បីដោះស្រាយចំណុចសំខាន់ទាំងបួនដែលបានរៀបរាប់ពីខាងលើ ដូច្នេះមានការចោទសួរថា ថាតើគេត្រូវជ្រើសរើសយកមួយ ហើយបោះបង់ចោលមួយឬយ៉ាងណា? ចម្លើយគឺច្បាស់ខ្លាំងណាស់ ៖ "ទេ" ។ យន្តការទាំងពីរបំពេញមុខងារផ្សេងគ្នា និងស្ថិតនៅក្រោមការគ្រប់គ្រងផ្សេងគ្នា ដោយពុំមានតួនាទីត្រួតគ្នាឡើយ ។

ការរៀបរាប់របស់បុគ្គលម្នាក់ៗ គឺជារឿងសំខាន់ដើម្បីស្វែងរកការពិត ហើយវេទិកាស្តាប់សំឡេងស្ត្រីពុំមែនរៀបចំឡើងរំពឹកនូវព្រឹត្តិការណ៍កាលពីអតីតកាលទូទៅដូចជាអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជានោះទេ ។ ទោះបីជាទិដ្ឋភាពមួយចំនួននៃយុត្តិធម៌ត្រូវបានផ្តល់ជូនតាមរយៈវេទិកាស្តាប់សំឡេងស្ត្រី ប៉ុន្តែជនល្មើសដែលបានប្រព្រឹត្តបទឧក្រិដ្ឋត្រូវតែទទួលខុសត្រូវចំពោះទោសកំហុសរបស់ខ្លួនដើម្បីឲ្យជនរងគ្រោះអាចទទួលបានយុត្តិធម៌ពេញលេញ និងដើម្បីកុំឲ្យមេដឹកនាំរដ្ឋប្រើប្រាស់អំណាចបំពានលើអ្នកដទៃ ។ ដំណើរការនៃការកាត់ទោសនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាក៏ចាំបាច់ដើម្បីធានានូវសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ និងបទដ្ឋានច្បាប់របស់អន្តរជាតិដទៃទៀតដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិរបស់ពលរដ្ឋ និងសិទ្ធិនយោបាយ រួមទាំងសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយឯករាជ្យ និងមិនលម្អៀង ឬការហាមឃាត់ចំពោះការផ្តន្ទាទោសពីរដងចំពោះបទល្មើសតែមួយ ។

ចំណុចខ្សោយរបស់វេទិកាស្តាប់សំឡេងរបស់ស្ត្រី គឺកង្វះខាតនៃការគាំទ្រពីរដ្ឋ ។ ការផ្តួចផ្តើមឲ្យមានសង្គមស៊ីវិល គឺត្រូវបានបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាលដើម្បីបំពេញចន្លោះខ្វះខាតដែលអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាពុំបានដោះស្រាយ ហើយលទ្ធផលសម្រេចបាន និងសារសំខាន់នៅក្នុងដំណើរយុត្តិធម៌អន្តរកាលនៅមានកម្រិតនៅឡើយ ។ ទាំងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ទាំងរាជរដ្ឋាភិបាលពុំបានផ្តល់ការគាំទ្រ និងទទួលស្គាល់វេទិកាស្តាប់សំឡេងរបស់ស្ត្រីថាជាវិធានការក្រៅប្រព័ន្ធតុលាការផ្លូវការ ដើម្បីដោះស្រាយបញ្ហាកាលពីអតីតកាលនៅឡើយទេ ។ យន្តការនានាត្រូវបានបង្កើតឡើង និងទទួលបានការគាំទ្រពីរដ្ឋដូចជាអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីបង្កើតជាទម្រង់ស្នូលនៃដំណើរការយុត្តិធម៌អន្តរកាលដែលទទួលបានជោគជ័យដែលបានទាមទារឲ្យមានការដឹកនាំ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលនៅក្នុងប្រទេសក្រោយជម្លោះ ។

ចំណុចសំខាន់ដែលបានរៀបរាប់ខាងលើ ទាក់ទងនឹងយុត្តិធម៌អន្តរកាល អាចដោះស្រាយតាមរយៈសកម្មភាពរបស់រដ្ឋ ។ មានតែយន្តការដែលគ្រប់គ្រងដោយរដ្ឋទាក់ទងនឹងកម្មវិធីស្វែងរកការពិត ការនិយាយពីការពិត និងសំណង ប៉ុណ្ណោះទើបអាចចូលរួម

ចំណែក ដើម្បីជួយអ្នកដែលរស់រានមានជីវិត និងដើម្បីផ្តល់ឱកាសឲ្យអតីតជនដែលដល់ក្នុងការរៀបរាប់រឿងរ៉ាវកាលពីអតីតកាល ។ មានតែយន្តការដែលគ្រប់គ្រងដោយរដ្ឋប៉ុណ្ណោះ ទើបអាចផ្តល់យុត្តិធម៌បាន ដោយសាររដ្ឋមានឯកសិទ្ធិក្នុងការចោទប្រកាន់ និងផ្តន្ទាទោសរាល់បទឧក្រិដ្ឋដែលកើតឡើងនៅក្នុងរដ្ឋនោះ ហើយមានតែកំណែទម្រង់ដែលធ្វើដោយរដ្ឋប៉ុណ្ណោះ ទើបអាចធានាបាននូវការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រាន់ដើម្បីបំពេញបាននូវការប្តេជ្ញាចិត្តដែលធានាមិនឲ្យកើតមានអំពើបែបនេះកើតឡើងវិញសាជាថ្មីម្តងទៀត ។

### ៥) សេចក្តីសន្និដ្ឋាន

វេទិកាស្តាប់សំឡេងស្ត្រីស្តីពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ក្នុងអំឡុងស្ថានភាពជម្លោះ បានរួមចំណែកដល់ដំណើរការយុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា ដោយផ្តល់នូវវេទិកាមួយសម្រាប់ជនរងគ្រោះដើម្បីស្វែងរកចំណុចសំខាន់បួន គឺ ការពិត យុត្តិធម៌ សំណង និងការធានាមិនឲ្យកើតមានអំពើបែបនេះសាជាថ្មីម្តងទៀត ។ វេទិកាទាំងនោះ ជាយន្តការក្រៅប្រព័ន្ធតុលាការដែលអនុវត្តអាណត្តិការងារនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដែលផ្តោតទៅលើបុគ្គលដែលរៀបរាប់ពីដំណើររឿងកាលពីអតីតកាល និងជនរងគ្រោះ ។ សម្រាប់អ្នកដែលរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រ មិនត្រូវបានដាក់បញ្ចូលនៅក្នុងដំណើរការរបស់តុលាការនោះទេ ប៉ុន្តែអ្នកទាំងនោះត្រូវការគាំទ្រ និងផ្តល់តម្លៃជាពិសេស ។ ប្រសិនបើសំណុំរឿង០០៤ បានដំណើរការទៅមុខជាមួយការចោទប្រកាន់ពីការរំលោភសេពសន្ថវៈ ដែលនៅក្រោមបរិបទនៃការបង្ខំឲ្យមានការរៀបការនោះ វេទិកាស្តាប់សំឡេងស្ត្រី គួរតែត្រូវបានផ្តល់តម្លៃជាមួយនឹងការជំរុញអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាឲ្យចាត់វិធានការដោះស្រាយលើបញ្ហានេះ ។

ទម្រង់នៃវេទិកាស្តាប់សំឡេងស្ត្រី អាចយកទៅអនុវត្តជាមួយនឹងជនដែលងាយរងគ្រោះផ្សេងទៀត ដូចជាក្រុមជនជាតិភាគតិចដែលទទួលរងនូវការរើសអើងនាពេលបច្ចុប្បន្ន ។ ដូចគ្នាទៅនឹងស្ថានភាពរបស់អ្នកដែលរស់រានមានជីវិតអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រដែរ ក្រុមមនុស្សងាយរងគ្រោះផ្សេងទៀត ដែលមានបទពិសោធន៍ក្នុងអំពើហិង្សា ហើយមិនត្រូវបានដាក់បញ្ចូលសំណុំរឿងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា គឺចាំបាច់ត្រូវមានវេទិកាមួយដើម្បីបង្ហាញពីបទពិសោធន៍របស់អ្នកទាំងនោះដែលធានាឲ្យមានបរិស្ថានសុវត្ថិភាព និងទទួលបានការគាំទ្រយ៉ាងកក់ក្តៅសម្រាប់ការចូលរួមរបស់គាត់ ។ ឧទាហរណ៍ៈ ខ្មែរកម្ពុជាក្រោមធ្លាប់បានទទួលរងគ្រោះអំពើហិង្សាដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម មិនត្រូវបានដាក់បញ្ចូលទៅក្នុងដីកាដំណោះស្រាយអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ៤២នោះទេ ។ នៅក្នុងទស្សនៈនៃការរើសអើងប្រឆាំងនឹងក្រុមជនជាតិភាគតិចនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ វេទិកាមួយចំនួនដែលមានទម្រង់ជាវេទិកាស្តាប់សំឡេងរបស់ស្ត្រីអាចធានាបាននូវកម្រិតនៃការការពារ ប៉ុន្តែស្របពេលជាមួយគ្នានេះ ការឈឺចាប់ និងបទឧក្រិដ្ឋដែលប្រឆាំងនឹងគាត់ក៏ត្រូវបានទទួលស្គាល់ដែរ ។

ទោះបីជាវេទិកាស្តាប់សំឡេងស្ត្រីពុំមែនផ្តួចផ្តើមគំនិតដោយរាជរដ្ឋាភិបាលក៏ដោយ ក៏វេទិកានេះនៅមានកម្រិតនៅក្នុងសកម្មភាពការងារ វិសាលភាព និងផលប៉ះពាល់ ។ នៅក្នុងទស្សនៈទាក់ទងនឹងសក្តានុពលនៃវេទិកាស្តាប់សំឡេងស្ត្រីក្នុងការដោះស្រាយការរំលោភសិទ្ធិមនុស្សកាលពីអតីតកាល រាជរដ្ឋាភិបាលកម្ពុជាគួរតែពិចារណាអំពីការប្រើប្រាស់ទម្រង់នៃវេទិកាក្រៅប្រព័ន្ធតុលាការសម្រាប់ជនរងគ្រោះ ដើម្បីធ្វើជាមធ្យោបាយបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិក្នុងការផ្តល់សំណងដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ដូចដែលបានអំពាវនាវដោយគណៈកម្មាធិការត្រួតពិនិត្យការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ។ នៅក្នុងកំណត់សម្គាល់មួយរបស់គណៈកម្មាធិការនេះបានលើកឡើងថា រាជរដ្ឋាភិបាលត្រូវបានស្នើឲ្យអភិវឌ្ឍន៍កម្មវិធីយុត្តិធម៌អន្តរកាលក្រៅប្រព័ន្ធតុលាការដែលមានប្រសិទ្ធភាពក្នុងនោះរួមមាន ការផ្តល់សំណងគ្រប់គ្រាន់ ការព្យាបាលរបួសផ្លូវចិត្ត និងការគាំទ្រផ្នែកផ្សេងៗទៀតសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាយេនឌ័រដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។

**បេនី យេ**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥

## សេចក្តីថ្លែងការណ៍
## របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣

នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់លោក មាស មុត ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ដូចខាងក្រោម៖

- អំពើប្រល័យពូជសាសន៍
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភលើផ្លូវភេទ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូរជាមនុស្សដោយសារស្ថានភាពនៃការឃុំខ្លួន)
- អំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការធ្វើទារុណកម្ម និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់
- ការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ក្នុងនោះរួមមាន មនុស្សឃាតដោយចេតនា

ឧក្រិដ្ឋកម្មទាំងនេះត្រូវបានចោទថាបានប្រព្រឹត្តផ្សេងៗគ្នា៖

- នៅមន្ទីរសន្តិសុខផ្សេងៗ ក្នុងនោះរួមមាន មន្ទីរសន្តិសុខ ស-២១ (ទួលស្លែង)
- ឧក្រិដ្ឋកម្មមកលើសមាជិកកងពលលេខ ១៦៤, ៥០២, ១១៧ និង ៣១០
- នៅមន្ទីរសន្តិសុខ វត្តឥន្ទញាណ
- នៅការដ្ឋានស្ទឹងហាវ

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555
www.eccc.gov.kh

- ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅលើកោះ និងជុំវិញកោះដែលកម្ពុជាប្រជាធិបតេយ្យ អះអាងថាជារបស់ខ្លួន
- នៅសហករណ៍តំបន់រាម រួមមាន ការដ្ឋាននៅកងកេង និងបិតត្រាំង ទីតាំងសម្លាប់មនុស្សចម្ការធូរេន និងមន្ទីរសន្តិសុខទឹកសាប។
- នៅកំពង់សោម

បទចោទមួយចំនួននៅក្នុងដីកាសម្រេចចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ដែលដាក់គាត់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ត្រូវបានលុបចោល។ ឥឡូវនេះ ដីកាសម្រេចនោះលែងមានសុពលភាព ហើយដីកាបង្គាប់ឲ្យនាំខ្លួនចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ក៏លែងមានសុពលភាពដែរ។ ដីកាបង្គាប់ឲ្យនាំខ្លួនចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ត្រូវបានលុបចោល ពីព្រោះថា លោក មាស មុត បានចូលបង្ហាញខ្លួនដោយស្ម័គ្រចិត្ត។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ
www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555
www.eccc.gov.kh

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥

## សេចក្តីថ្លែងការណ៍
## របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង 004

នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់លោក យឹម ទិត្យ ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ដូចខាងក្រោមៈ

- អំពើប្រល័យពូជសាសន៍ខ្មែរក្រោម
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញមកលើ "ប្រជាជន ១៧ មេសា" "អ្នកជម្លៀសមកពីភូមិភាគបូព៌ា" និងកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ ការធ្វើទុក្ខបុកម្នេញមកលើខ្មែរក្រោម និងជនជាតិវៀតណាម និងអំពើអមនុស្សធម៌ដទៃទៀត រួមមាន អាពាហ៍ពិពាហ៍ដោយបង្ខំ
- អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀត-ណាម ក្នុងនោះរួមមាន ការធ្វើមនុស្សឃាតដោយចេតនា និងការនិរទេស ឬការផ្លាស់ទីលំនៅជនស៊ីវិលដោយខុសច្បាប់
- ការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ក្នុងនោះរួមមាន មនុស្សឃាតដោយចេតនា។

ឧក្រិដ្ឋកម្មទាំងនេះត្រូវបានចោទថាបានប្រព្រឹត្តផ្សេងៗគ្នានៅខេត្តតាកែវ (ភូមិភាគនិរតី)នៅមន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្សភូមិព្រៃល ទីតាំងសម្លាប់មនុស្សវត្តអង្គុណទីតាំសម្លាប់មនុស្សព្រៃភូមិស្លែងទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ) នៅមន្ទីរសន្តិសុខគាស់ក្រឡ អន្លង់វិលប្រែង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធសហករណ៍ធិបតី រួមមានមន្ទីរសន្តិសុខវត្ត ធិបតី និងមន្ទីរសន្តិសុខ និងការដ្ឋានទួលម្ទេស ការដ្ឋានទំនប់កង្ហូតមន្ទីរសន្តិសុខបាណន់ មន្ទីរសន្តិសុខខ្នងគូ ការដ្ឋានរោងចក្រស្ករកំពង់គុល ការដ្ឋានភ្នំត្រដាក់ចិត្ត ទីតាំងសម្លាប់មនុស្សបន្ទាយអូរតាក្រី ស្រុកសំឡូត មន្ទីរសន្តិសុខវត្តធម្មយុត មន្ទីរសន្តិសុខវត្តសម្តេច ឃុំកំពង់ព្រៀង រួមមានភូមិកាច់រទេះ ភូមិថ្មី ភូមិសាលាត្រាវ និងមន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ ឃុំរាំងកេសី រួមមាន វត្តរាំងកេសី

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១ ៥៥៥ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555
www.eccc.gov.kh

និងភូមិរាំងកេសី មន្ទីរសន្តិសុខវត្តគិរីរម្យ និងមន្ទីរសន្តិសុខវត្តកណ្តាល ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ)នៅមន្ទីរសន្តិសុខភ្នំវាល មន្ទីរសន្តិសុខស្វាយជ្រំ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី គុកលេខ ៨ និងទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅខេត្តបន្ទាយមានជ័យ (ភូមិភាគពាយ័ព្យ) នៅមន្ទីរសន្តិសុខវត្តបន្ទាយនាង មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង ការដ្ឋានស្ពានស្រែង និងទំនប់ព្រៃរនាម វត្តព្រះនេត្រព្រះ ទីតាំងឃុំខ្លួន និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធនានា មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សភូមិចក្រី ទីតាំងសម្លាប់មនុស្សព្រៃតារ៉ូត ទីតាំងសម្លាប់មនុស្សវត្តចម្ការខ្នុរ និងការដ្ឋានទំនប់ត្រពាំងថ្ម។

ឥឡូវនេះ តាមរយៈមេធាវីរបស់គាត់ លោក យឹម ទិត្យ មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ហើយអាចចូលរួមកិច្ចស៊ើបសួរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


| | |
|---|---|
| **លោក ឡាស អូលសិន** | **លោក នេត្រ ភក្ត្រា** |
| មន្ត្រីទំនាក់ទំនងផ្នែកច្បាប់ | មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម |
| ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ០២៣ | ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦ |
| ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៦៦៩ | ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៥៦៤ |
| សារអេឡិចត្រូនិក: olsenl@un.org | សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh |


www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555
www.eccc.gov.kh

# ការពិភាក្សាលើការដាក់ភ័ស្តុតាងបន្ថែម ក្នុងសំណុំរឿង០០២/០២

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៥ មុនពេលដែលអង្គជំនុំជម្រះសាលាដំបូងបន្តស្តាប់សក្ខីកម្មសាក្សី ដែលផ្តល់សក្ខីកម្មទាក់ទងនឹងការដ្ឋានទំនប់ត្រពាំងថ្ម អង្គជំនុំជម្រះបានផ្តល់ឱកាសដល់ភាគីដើម្បីពិភាក្សាលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការដាក់បន្ថែមភ័ស្តុតាងថ្មីពាក់ព័ន្ធនឹងការប្រព្រឹត្តលើជនជាតិវៀតណាម ដែលជាប្រធានបទសំខាន់មួយនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២នេះ ។ ការស្នើសុំដាក់ភ័ស្តុតាងបន្ថែម របស់សហព្រះរាជអាជ្ញាសំដៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីម្នាក់ដែលជាសាក្សីនៅក្នុងសំណុំរឿង០០៣ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេល ឡាយសាក់ បានសំអាងលើមូលហេតុមួយចំនួន ដើម្បីគាំទ្រការស្នើសុំរបស់ខ្លួនដោយលើកឡើងថាសាក្សីថ្មីបានពន្យល់អំពីការសម្លាប់ និងមូលហេតុនៃការសម្លាប់ជនជាតិវៀតណាម ។ តំណាងសហព្រះរាជអាជ្ញាបានបន្តទៀតថា មេបញ្ជាការកងវរៈ បានទទួលការអប់រំ ផ្នែកនយោបាយ ហើយក្រោយមកមេបញ្ជាការនោះបានប្រាប់កូនទាហានរបស់ខ្លួនឲ្យចាត់ទុកជនជាតិវៀតណាមជាខ្មាំង ព្រមទាំងបានបញ្ជាឲ្យកូនទាហានរបស់ខ្លួនបាញ់សម្លាប់ទាហានវៀតណាមនិងប្រជាជនស៊ីវិល ។ ដោយបន្ថែមលើឯកសារទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា សហព្រះរាជអាជ្ញាបានបញ្ជាក់ថារហូតដល់ពេលដែលមានឯកសារពីការិយាល័យសហចៅក្រមស៊ើបអង្កេត ទើបសហព្រះរាជអាជ្ញាសម្រេចចិត្តស្នើសុំមកអង្គជំនុំជម្រះសាលាដំបូងដើម្បីដាក់ភ័ស្តុតាងបន្ថែម ។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី



នួន ជា និង ខៀវ សំផន នៅក្នុងសវនាការកាត់ទោសសំណុំរឿង០០២ (រូបថត ៖ អ.វ.ត.ក)

បង្ហាញជំហរគាំទ្រចំពោះសំណើរបស់សហព្រះរាជអាជ្ញាដោយហេតុផលថា វាជាទង្វើដ៏សំខាន់ក្នុងដំណើរស្វែងរកការពិតដល់ការសម្លាប់ជនជាតិវៀតណាម ។

ការស្នើសុំរបស់សហព្រះរាជអាជ្ញាទទួលរងការជំទាស់ពីមេធាវីការពារក្តីទាំងពីរក្រុមរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ។ មេធាវីអន្តរជាតិ វិចទ័រ កូបេ បានលើកឡើងថា វាជាលើកទីមួយក្នុងការលើកយកសាក្សីដែលត្រូវសម្ភាសន៍ក្នុងសំណុំរឿង ០០៣ និងជាអតីតកម្មាភិបាលនៅក្នុងកងពល១៦៤ ។ មេធាវីបានលើកឡើងទៀតថា សំណួរត្រូវលើកឡើងថាតើមានសាក្សីមកពីកងពល១៦៤តែម្នាក់ដែលត្រូវសហព្រះរាជអាជ្ញាស្តាប់ចម្លើយ ឬមានសាក្សីផ្សេងទៀត ។ ពុំមាននរណាម្នាក់ដឹងថាតើមានសាក្សីរូបនេះតែម្នាក់ ឬសាក្សីនឹងមកផ្តល់សក្ខីកម្មទាក់ទងនឹងចំណុចនេះ ។ មេធាវី កូបេ បានបន្ថែមទៀតថា រហូតដល់ពេលដែលសំណុំរឿង០០៣ ត្រូវបិទបញ្ចប់ការស៊ើបអង្កេត ទើបយើងអាចដឹងពីភាពជឿជាក់បាននៃសក្ខីកម្មរបស់សាក្សីថ្មីដែលកំពុងស្នើនេះ ។ ចំណុចសំខាន់មួយទៀតដែលមេធាវីបានលើកឡើងដើម្បីជំទាស់នឹងសំណើរបស់សហព្រះរាជអាជ្ញា គ្រង់ចំណុចដែលសហព្រះរាជអាជ្ញាផ្តោតលើតែភ័ស្តុតាងដាក់បន្ទុក ។ មេធាវីបញ្ជាក់ថាសហព្រះរាជអាជ្ញាស្នើសុំដាក់ភ័ស្តុតាងថ្មីចំពោះតែកំណត់ហេតុស្តាប់ចម្លើយចំនួនពីរដែលជាភ័ស្តុតាងដាក់បន្ទុកក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយដែលមានចំនួនប្រាំ ដែលរួមមានទាំងដោះបន្ទុក និងដាក់បន្ទុកផង ។ ចំណែកក្រុមមេធាវីការពារក្តី ខៀវ សំផន បានលើកយកពីភាពយឺតយ៉ាវនៃការស្នើសុំរបស់សហព្រះរាជអាជ្ញាថា កំណត់ហេតុស្តាប់ចម្លើយធ្វើឡើងតាំងពីឆ្នាំ២០០៧ មកម្ល៉េះបែរជាសហព្រះរាជអាជ្ញាទើបតែលើកសំណើនៅពេលនេះ ចុងឆ្នាំ២០១៥ ។ នេះជាពេលវេលាដែលសំណុំរឿងបានបិទបញ្ចប់រួចរាល់ហើយ ។ មេធាវីជាតិ គង់សំអុន ក៏បានលើកឡើងអំពីការជំទាស់របស់ខ្លួនទាក់ទងនឹងការដាក់ភ័ស្តុតាងថ្មីនេះ ដោយផ្តោតសំខាន់ទៅលើតួនាទីរបស់អយ្យការក្នុងការបង្ហាញទាំងភ័ស្តុតាងដាក់បន្ទុក និងភ័ស្តុតាងដោះបន្ទុក ។ នៅក្នុងដំណាក់កាលនេះ ការស្វែងរកភ័ស្តុតាងដាក់បន្ទុកបានកន្លងផុតទៅហើយ ។ ទាំងភាគីសហព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ជនជាប់ចោទមានពិរុទ្ធភាព ដោយហេតុនេះ ទើបមានការបញ្ជូនមកជំនុំជម្រះ ។ ដូច្នេះ ស្ថិតនៅក្នុងដំណាក់កាលនេះ សហព្រះរាជអាជ្ញា គួរតែរកភ័ស្តុតាងដោះបន្ទុកវិញ ពុំមែនដល់ដំណាក់កាលជំនុំជម្រះ ហើយសហព្រះរាជអាជ្ញានៅតែបន្តស្វែងរកភ័ស្តុតាងដាក់បន្ទុកទៀតនោះទេ ។


ខៀវ សំផន (រូបថត : អ.វ.ត.ក)


នួន ជា (រូបថត : អ.វ.ត.ក)

ការចេញសេចក្តីសម្រេចលើសំណើដាក់ភ័ស្តុងតាងថ្មីដោយភាគីសហព្រះរាជអាជ្ញា អាចនឹងធ្វើនៅក្នុងពេលឆាប់ៗខាងមុខនេះ ដោយផ្អែកលើហេតុផលបម្រើដល់ការស្វែងរកការពិត ។ អង្គជំនុំជម្រះសាលាដំបូងអាចចេញសេចក្តីសម្រេចយល់ស្របតាមសំណើរបស់ភាគីសហព្រះរាជអាជ្ញាប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយពុំអាចស្វែងរកបាននៅក្នុងដំណាក់កាលមុនការចាប់ផ្តើមជំនុំជម្រះ ។ ប៉ុន្តែ ដោយផ្អែកតាមវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចនឹងសម្រេចបដិសេធសំណើរបស់សហព្រះរាជអាជ្ញា ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា សំណើនោះមិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា ។ អង្គជំនុំជម្រះក៏អាចបដិសេធ ប្រសិនបើរកឃើញថា សហព្រះរាជអាជ្ញាពុំអាចរកភ័ស្តុតាងបន្ថែមបានក្នុងរយៈពេលសមស្របណាមួយ ឬមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការពិនិត្យភ័ស្តុតាង ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះក៏អាចបដិសេធ ប្រសិនបើរកឃើញថា ភ័ស្តុតាងថ្មីមានលក្ខណៈផ្ទុយពីច្បាប់ ឬភាគីមានចេតនាពន្យា កិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍ ។ **ឌី សុជាតា**

# រសាត់តាមខ្យល់

***(តពីលេខមុន)***



ខ្ញុំត្រូវបានមិត្តហួត ឲ្យនៅជួយការងាររចុងភៅជាមួយតាឆែត បន្តទៀត ហើយជាញឹកញយ ខ្ញុំបានឆ្លៀតឱកាសទៅជួបបងហឿង នៅឃ្លាំងផ្ទុកស្កររត្នោត ស្ថិតនៅពីមុខផ្ទះម៉ែឡាញ់ ដែលដីមួយវាល ពីមុខឃ្លាំងស្ករនោះ កំពុងតែរៀបចំសង់រោងបាយរួម ។ ថ្ងៃមួយនៅ ឃ្លាំងស្ករ បងហឿងបានបង្ហើបប្រាប់ខ្ញុំថា រូបគាត់ក៏ជាប្រជាជន ១៧មេសាដែរ ។ នៅពេលដែលខ្ញុំកំពុងតែភ្ញាក់ផ្អើលយ៉ាងខ្លាំងនឹង សំដីរបស់គាត់នោះ គាត់បានបន្តទៀតថា គាត់ស្រឡាញ់រាប់អាន និងទុកចិត្តខ្ញុំដូចជាប្អូនបង្កើត ហើយសូមកុំឲ្យខ្ញុំយល់ច្រឡំទៅលើ រូបគាត់ ។ កាលពីឆ្នាំ១៩៧៣ យុវជនក្នុងភូមិ ត្រូវអង្គការប្រមូល ឲ្យចូលបម្រើក្នុងជួរកងទ័ព ក្នុងនោះមានរូបគាត់ និងប្អូនជីទួតមួយ គាត់ម្នាក់នៅភូមិឃ្លៃឈ្មោះ អាសាឡួន ដែលត្រូវជាប្អូនប្រុសបង្កើត របស់មិត្តផន អនុប្រធានវរៈទីមួយចល័តឃុំសព្វថ្ងៃ ។

បងហឿង បាននិយាយប្រាប់ខ្ញុំបន្តទៀតថា ក្នុងអង្គភាពទ័ព គាត់នឹងអាសាឡួន មានគំរោងនឹងបានគិតទុក ស្រេចជាមុនហើយថា ឲ្យតែមានឱកាសហុចឲ្យនឹងនាំគ្នារត់ចោលជួរទម្លាក់អាវុធទៅសុំចុះ ចូលនឹងទាហានរដ្ឋាភិបាល ដើម្បីនាំគ្នាបន្តការសិក្សានៅឯភ្នំពេញ ។

ក្នុងឱកាសប្រយុទ្ធគ្នាមួយនៅនឹងសមរភូមិខ្សែក្រវាត់ការ ពារទីក្រុងកំពង់ធំ គាត់ និងអាសាឡួនដែលឈរជើងនៅនឹងខ្សែ ត្រៀមខាងមុខ បាននាំគ្នាទម្លាក់អាវុធរត់ចុះចូលជាមួយនឹងទាហាន រដ្ឋាភិបាល ។ ក្រោយពីគាត់ និងអាសាឡួន ត្រូវបានគេឃុំឃាំងខ្លួន នៅនឹងទីរួមខេត្តកំពង់ធំអស់រយៈពេលបីថ្ងៃ ដើម្បីសាកសួរចម្លើយ រួចមក គាត់ត្រូវបានគេដោះលែងឲ្យមានសេរីភាព ។ គាត់ និងអា សាឡួន ក៏បានបន្តដំណើរមកភ្នំពេញ ស្នាក់នៅក្នុងកុដិលេខ៦ វត្ត មហាមន្ត្រី និងបានចូលរៀនសារជាថ្មីនៅវិទ្យាល័យ១៨មីនា ក្រោយ ពីមានព្រឹត្តិការណ៍សម្លាប់លោកថាច់ ជា និងលោកកែវ សុងគីម មក វិទ្យាល័យ១៨មីនា ត្រូវបានប្តូរឈ្មោះជាវិទ្យាល័យកែវ (សុងគីម វិញ) ដោយល្ងាចៗគាត់និងអាសាឡួននាំគ្នាប្រកបមុខរបរធាក់ ស៊ីក្លូដើម្បីរកកម្រៃទប់ទល់ និងជីវភាពនិងការរៀនសូត្រ ។

ប៉ុន្មានថ្ងៃក្រោយពីដាច់ភ្នំពេញ រូបគាត់និងអាសាឡួន ក៏បាន វិលត្រឡប់មកដល់ភូមិកំណើត ដោយសច្ចានឹងគ្នាថាត្រូវលាក់រឿង នេះឲ្យជិតទោះជាក្នុងករណីណាក៏ដោយ គឺសុខចិត្តស្លាប់ ។

ក្នុងភូមិគ្មានអ្នកណាម្នាក់បានដឹងថាគាត់ និងអាសាឡួន ដាក់ អាវុធរត់ចុះចូលទាហានលន់ នល់ទេ គាត់ និងអាសាឡួន បាន ប្រាប់អ្នកភូមិព្រមគ្នាថា កាលនោះរូបគាត់ និងអាសាឡួន ត្រូវទាហាន លន់ នល់ ចាប់ខ្លួនបាន ។ ប្រមាណមួយសប្តាហ៍មុនពេលដែល មន្ទីរពេទ្យឃុំនឹងត្រូវបិទទ្វារជាស្ថាពរ អ្នកជំងឺនៅសល់ប្រហែលជាង ១០នាក់ប៉ុណ្ណោះ ។ នាព្រលប់ថ្ងៃមួយនោះពេលដែលអ្នកជំងឺទាំង អស់ បាននាំគ្នាសម្ងំដេកទៅហើយ ស្រាប់តែមានគេសែងអ្នកជំងឺម្នាក់ មកពីអង្គភាពចល័តឃុំយកមកដាក់ចោលកណ្តាលផ្ទះពេទ្យ ទុកឲ្យ នៅប្រកាច់តែម្នាក់ឯង ហើយពួកគេនាំគ្នាត្រឡប់ទៅវិញអស់ទៅ ។ យប់នោះមិត្តហួត ក៏មិននៅ មិត្តអ៊ឹម ទៅសម្រាកឯផ្ទះនៅភូមិខ្វែក ព្រោះប្រពន្ធគាត់ជិតគ្រប់ខែឆ្លងទន្លេ គ្មានមិត្តពេទ្យណាម្នាក់ប្រចាំការ សោះ ។ អ្នកជំងឺដែលកំពុងតែប្រកាច់គឺអាបុង ប្អូនប្រុសអាណេ វា បានលេបគ្រាប់ស្នែងសម្លាប់ខ្លួន ។

ខ្ញុំបានឃើញអាបុង កំពុងតែប្រកាច់ទាញកន្ត្រាក់ដៃជើងរឹង ថ្គាមខាំធ្មេញយ៉ាងជាប់ ភ្នែកទាំងគូរបិទជិតឈឹង ។ ខ្ញុំ និងបងអាំង

អេងថុង បាននាំគ្នាចូលទៅជិតមើលវា ខ្ញុំនឹកអាណិតអាសូរដល់រូបវាយ៉ាងខ្លាំង ស្របពេលជាមួយគ្នានោះ បងអាំង អេងថុង បាននិយាយមកកាន់ខ្ញុំថា អ្នកដែលពុលគ្រាប់ស្លែង គឺមានតែទឹកប្រហុកឆៅទេ ទើបអាចជួយបាន ។ គាត់និយាយមិនទាន់ផុតពីមាត់ស្រួលបួលផង ខ្ញុំស្ទុះភ្លេតទៅរកតាឆែត ដែលកំពុងតែសម្រាន្តលក់យ៉ាងស្កប់ស្កល់ ខ្ញុំដាស់គាត់ឲ្យភ្ញាក់សុំបានប្រហុកឆៅមួយចាន ។

ដោយមានបងអាំង អេងថុង យកស្លាបព្រាជួយគាស់បង្ហើបថ្គាមវាផង ខ្ញុំបានបញ្ចុកទឹកប្រហុកឆៅក្នុងមាត់អាបុងទាំងលំបាក ព្រោះពេលខ្លះគ្រាន់តែដាក់ស្លាបព្រាប៉ះដល់មាត់វាភ្លាម ស្រាប់តែវាប្រកាច់ទាញដៃទាញជើង តែខ្ញុំ និងបងអាំង អេងថុង នៅតែព្យាយាមបញ្ចុកដដែល ។ ប្រមាណជាងមួយម៉ោងក្រោយមក ខ្ញុំបានឃើញអាបុង ហាក់ដូចជាមិនសូវប្រកាច់ទាញដៃទាញជើងដូចមុន វាបានព្យាយាមហារមាត់តិចៗដោយខ្លួនឯង នៅពេលដែលខ្ញុំកំពុងតែបន្តបញ្ចុកថែមទៀតនោះ ។ ខ្ញុំបានដោះវ៉ែនតាដែលមានកញ្ចក់ក្រាស់ឃ្មឹកប្រលាក់ដោយទឹកប្រហុកចេញពីភ្នែកវា ។ អាបុង បានដឹងខ្លួនតិចៗឡើងវិញហើយ ដោយមានពេលខ្លះវាបានយកដៃមកកៀសស្លាបព្រាចេញពីមាត់វាផង ។

ព្រឹកស្អែកឡើង ខ្ញុំបានឃើញអាបុង អង្គុយបញ្ឈរជង្គង់ហុតរបបបបរជាមួយនឹងអ្នកជំងឺដទៃទៀតដែរ ។ ពីរថ្ងៃបន្ទាប់មកវាត្រូវបានមិត្តអ៊ីម បញ្ជូនទៅការដ្ឋានត្បែងកោងវិញ ។ ក្រោយពីមន្ទីរពេទ្យឃុំត្រូវបានរំសាយមក ខ្ញុំក៏ត្រូវបានវិលមកអង្គភាពចល័តនៅឯការដ្ឋានត្បែងកោងវិញដែរ ហើយប្រមាណកន្លះខែក្រោយមកក្នុងអង្គភាពវរៈទីមួយ មានយុវជនចំណូលថ្មីពីរនាក់ ដែលទើបតែនឹងរំសាយមកពីជួរកងទ័ព មានមិត្តឡេងជាអ្នកភូមិឈើទាល ជាកូនប្រុសរបស់ម៉ែឡាញ់ និងមិត្តស្រស់ ជាអ្នកភូមិឃ្លៃ ។

រដូវដកស្ទូងឆ្នាំនេះ នៅឯការដ្ឋានត្បែងកោង កម្លាំងគ្រប់កងគ្រប់វរៈ សម្រុកដកស្ទូងទាំងយប់ទាំងថ្ងៃលើ ផ្ទៃដីរាប់រយហិកតា ថ្ងៃណាក៏ដូចជាថ្ងៃបុណ្យដែរ ។ បងហឿង និងកម្លាំងអ្នកឡើងត្នោតតាមភូមិទូទាំងឃុំក៏ដូច្នោះដែរ ផុតរដូវធ្វើត្នោត ត្រូវមកចូលរួមជួយសម្រុកភ្ជួររាស់ ។ រោងសំណាក់សម្រាប់កងភ្ជួរសង់ជាជួរយ៉ាងវែងនៅ ពីក្រោយរោងវរៈទីមួយ និងទីពីរ ។

នៅទីងការដ្ឋានត្បែងកោង ប្រយុទ្ធការងារដប់ថ្ងៃបានឈប់សម្រាកមួយថ្ងៃនោះ ត្រូវចូលរួមមិទ្ទិញរៀនសូត្រពីមាគ៌ានយោបាយរបស់បក្សរយៈពេលកន្លះថ្ងៃ នៅសល់កន្លះថ្ងៃទៀតអាចសុំច្បាប់ប្រធានកងទៅលេង ភូមិបាន ។ ទន្ទឹមនឹងសភាពការណ៍វាយសម្រុកដកស្ទូងដ៏មមាញឹកនេះ នៅក្នុងឃុំកំពង់ថ្កូវ ស្រាប់តែមានការផ្លាស់ប្តូរ សមាសភាពថ្នាក់ដឹកនាំ ។ មិត្តលីម អាយុជាង៤០ឆ្នាំដែលមានអតីតភាពជាសាស្ត្រាចារ្យ បានមកធ្វើជាប្រធានឃុំកំពង់ថ្កូវថ្មីជំនួសមិត្តអាន ។

មិត្តលីម មានអត្តចរិតជាមនុស្សស្ងប់ស្ងៀម និយាយស្តីមួយៗ ជិះម៉ូតូហុងដាសេ.អិល មួយគ្រឿងពណ៌ក្រហម មានកងការពារម្នាក់ឈ្មោះមិត្តថ្លាង ជាអ្នកឃុំប្រាសាទ ជិះម៉ូតូហុងដា៧០ពណ៌ខៀវ ស្ពាយកាំភ្លើងអាកាបត់មួយដើម តាមការពារមិត្តលីម ពីក្រោយរហូត ។

ជារៀងរាល់ថ្ងៃមិត្តលីម បានមកចុះដាប់ចូលប្រយុទ្ធសម្រុកដកស្ទូងជាមួយនឹងប្រជាជនពីស្រែមួយទៅស្រែមួយយ៉ាងសកម្មនិងរាក់ទាក់ស្និទ្ធស្នាល ។ រហូតទល់ព្រលប់ទើបមិត្តលីម ជិះម៉ូតូត្រឡប់ទៅសម្រាកនៅឯមន្ទីរ កំពង់ថ្កូវិញ ។ រាល់ពេលសម្រាកកន្លះថ្ងៃពីការងារ ខ្ញុំបានសុំច្បាប់ពីមិត្តមឿន មកលេងភូមិរហូត ។ តាមភូមិទូទាំងឃុំហូបរបបបាយរួមជាច្រើនខែមកហើយ ពេលណាខ្ញុំមកលេងពូផន និងមីងណារុង នៅភូមិទួលសង្កែ ខ្ញុំទៅហូបនៅរោងបាយរួមដែលសង់ពីឬស្សីប្រក់ស្លឹកនៅខាងក្រៅភូមិតាមបណ្តោយមាត់ស្ទឹងជីនិត ។ ពេលនេះ ពូផន កំពុងមានជំងឺផង គាត់ឈឺហើមមិនអាចទៅធ្វើការបានទេ សម្រាកនៅនឹងខ្ទម គាត់ខំព្យាបាលជំងឺដោយខ្លួនឯងដោយហូបតែថ្នាំឫសឈើដែលតាតាសង្គមកិច្ចផ្សំឲ្យ ។ ពូផន ដើរទៅហូបនៅរោងបាយរួមមិនកើតផងបានលោកយាយកំពង់សៀមសុំបើករបបពីរោងបាយយកមកឲ្យគាត់ ចំណែកមីងណារុង ក៏មិនសូវបាននៅភូមិទេ ត្រូវទៅសម្រុកដកស្ទូងក្នុងកងវ័យកណ្តាលនៅឯការដ្ឋានត្បែងកោងដែរ ។

រោងបាយរួមតាមភូមិ វេនហូបមានចែកជាបីវេនដោយគោះជួងជាសញ្ញា ។ ស្នូរជួងទីមួយសម្រាប់ពួកកង កុមារទាំងអស់ក្នុងភូមិ ស្នូរជួងទីពីរវេនតាៗនិងយាយៗ ស្នូរជួងទីបី វេនពូមីងវ័យកណ្តាល ។

ខ្ញុំនៅតែចុះឡើងទៅលេងម៉ែឡាញ់ នៅឯភូមិឈើទាលជា

រឿយៗ ហើយមានពេលខ្លះ ខ្ញុំបានមិត្តឡើង កូនប្រុសរបស់គាត់ នៅទីនោះផង មិត្តឡើង មិនសូវនិយាយស្តីអីច្រើនជាមួយខ្ញុំទេ ។ ថ្ងៃមួយ នៅពេលដែលខ្ញុំកំពុងតែអង្គុយ នៅកណ្តាលផ្ទះតែពីរនាក់គាត់ ម៉ែឡាញ់ បានផ្តើមនិយាយជាមួយខ្ញុំ សួរពីរឿងគូស្រករគ្រួសារ ។ គាត់បានមើលឃើញកូនស្រីគេម្នាក់ ដែលគាត់ធ្លាប់បានស្គាល់យូរមកហើយ គឺកូនក្រមុំលោកសក្តិ៥ ត្រកូលថាច់ ដែលសព្វថ្ងៃរស់នៅភូមិព្រៃក្ល ឈ្មោះនាង ថាច់ សូរិយា ។ ម៉ែឡាញ់ នៅបានបន្តទៀតថា ជាអ្នកភ្នំពេញដូចគ្នា ហើយបើពេញចិត្តគាត់ចូលស្តីដណ្តឹងឲ្យ ។

គ្រាន់តែម៉ែឡាញ់ បង្ហើបសួរខ្ញុំពីរឿងគូស្រករ ស្រាប់តែអារម្មណ៍ខ្ញុំបែរជានឹកភ្នកដល់នាងរំដួល នៅឯកោះអណ្តែតភ្លាម ។ សម្រាប់ភ្នែកខ្ញុំ មិនខុសពីភ្នែកម៉ែឡាញ់ទេ នាងសូរិយាល្អណាស់ ទាំងរូបសម្ផស្ស ទាំងចរិតបុកពារ គួរជាទីស្រឡាញ់ តែសម្រាប់បេះដូងខ្ញុំ មុនពេលដែលខ្ញុំសម្រេចចិត្តរៀបគ្រួសារជាមួយនារីណាម្នាក់ គឺខ្ញុំចង់ឃើញនាងរំដួលជាថ្មីម្តងទៀតជាមុនសិន ។ ខ្ញុំខ្លួនឯងក៏មិនបានដឹងដែរថា បេះដូងខ្ញុំបានសម្រេចយ៉ាងដូច្នេះតាំងពីពេលណាមកនោះទេ ។ ខ្ញុំក៏បានជំរាបទៅម៉ែឡាញ់វិញថា អរគុណម៉ែណាស់ ដែលបានគិតគូរខ្វាយខ្វល់សព្វបែបយ៉ាងដល់រូបខ្ញុំ រឿងគូស្រករ ជម្រាបម៉ែតាមត្រង់ទៅ ខ្ញុំមិនទាន់ចង់កសាងសុភមង្គលក្នុងសភាពដូចសព្វថ្ងៃនេះទេ ។

គ្រាន់តែផុតរដូវភ្លៀងធ្លាក់ភ្លាម កងកម្លាំងចល័តយុវជនយុវនារីឃុំកំពង់ថ្មទាំងមូល ត្រូវបានលើកទៅការដ្ឋានទំនប់ទឹក១មករា ដែលបានចាប់ផ្តើមកាលពីជិតមួយខែមុននេះ មានកម្លាំងប្រជាជនជាច្រើនមកពីទំនប់នានាទូទាំងភូមិភាគ ។

ការដ្ឋានទំនប់ទឹក១មករា ជាការដ្ឋានភូមិភាគ ។ ក្នុងគោលដៅធ្វើជាម្ចាស់លើទឹក អង្គការបានបើកការដ្ឋាន លើកទំនប់ជីកប្រឡាយយ៉ាងធំបំផុតមួយនេះ ទប់ស្ទឹងជីនិតត្រង់ចំណុចភូមិស្នោ ដើម្បីសង់ទ្វារទឹកបើកទឹកដ៏ធំមួយ ដោយបង្វែរទឹកស្ទឹងជីនិតទាំងមូលឲ្យហូរទៅតាមខ្សែប្រឡាយដែលកំពុងតែជីកដោយកម្លាំងមនុស្សរាប់ម៉ឺនរាប់សែននាក់ ឆ្លាយដាប់កន្ទុយភ្នែករហូតដក់ឃុំកកោះដើងភ្នំសន្ទុក ដើម្បីយកទឹកមកស្រោចស្រពលើផ្ទៃដីសម្រាប់ធ្វើស្រែ ប្រពលវប្បកម្មឲ្យបានបីដងក្នុងមួយឆ្នាំ ។

ប្រជាជនដែលមកពីភូមិភាគបូព៌ា ស្នាក់នៅត្រើយម្ខាងស្ទឹងជីនិតក្នុងឃុំបារាយណ៍ កម្លាំងមកពីភូមិភាគពាយ័ព្យស្នាក់នៅត្រើយខាងជើងស្ទឹងតាមរោងដែលសង់ពីកូនឈើប្រក់ស្លឹកសង់តម្រៀបគ្នាជាជួរញឹកដូចម្រាមដៃ ។ ភូមិល្អក់ និងភូមិស្នោរទាំងពីរភូមិដែលចំមុខសញ្ញាទឹកហូរត្រូវលិចលង់ទាំងភូមិឋានទាំងដីដាំដុះ ។ ប្រជាជនទាំងអស់ត្រូវបោះបង់ចោលផ្ទះសម្បែងផលដំណាំ ហើយត្រូវបានអង្គការបញ្ជូនឲ្យមករស់នៅតាមភូមិនានាក្នុងឃុំកំពង់ថ្មទាំងមូល ។ ទ្វារបិទបើកទឹកដែលកំពង់តែសង់ដោយកម្លាំងមនុស្ស និងគ្រឿងយន្តជាច្រើនគ្រឿង នៅមិនទាន់រួចរាល់នៅឡើយ មានដោតទង់ជាតិ និងទង់បក្សជាច្រើនតម្រៀបគ្នាជាជួរ ដែលកំពុងតែត្រូវខ្យល់បក់រវិចៗលាយឡំនឹងបទចម្រៀងបដិវត្តន៍លាន់ឮយ៉ាងទ្រហឹងពីប្រដាប់បំពងសំឡេងដែលចងផ្អោបគ្នា និងបង្គោលឬស្សីបែរមុខទៅទិសទាំងបួន ។ នៅលើទំនប់ កម្លាំងមនុស្សច្រើនណាស់មើលទៅដូចហ្វូងស្រមោចឈូចុះឈូឡើងទាំងហ្វូងៗ រែកដីនៅនឹងបង្គីយកទៅចាក់លើខ្នងទំនប់បន្តបន្ទាប់គ្នាឡើងហុយទ្រលោមមិនដាច់ ។

តាំងពីព្រលឹមស្រាងៗ រែកដីរហូតដល់ពេលសម្រាកហូបបាយថ្ងៃត្រង់ ហើយកម្លាំងតាមកងនិមួយៗ ត្រូវតម្រង់គ្នាជាជួរដើរមកខ្ទមវិញ ពេលសម្រាកហូបបាយល្ងាចក៏ដូច្នោះដែរ ។ ហូបបាយល្ងាចរួច សម្រាកបានតែបន្តិច ត្រូវចេញទៅរែកដីបន្តទៀត ដោយនៅលើខ្នងទំនប់មានបញ្ចេះម៉ាស៊ីនភ្លើងអគ្គិសនីភ្លឺព្រោងព្រាត ។ ពេលដែលវិទ្យុកម្ពុជាប្រជាធិបតេយ្យចាប់ផ្តើមនាទីចាប៉ីដងវែងរបស់ស្មៀនឈាង ដែលច្រៀងរៀបរាប់ដដែលៗតែពីគុណបំណាច់របស់អង្គការបដិវត្តន៍កម្ពុជាយើងនោះ កម្លាំងពលកម្មទាំងអស់បានសម្រាកអង្គុយស្តាប់ ចាប៉ីលើខ្នងទំនប់ចំនួនដប់នាទី ហើយធ្វើការបន្តរហូតដល់ម៉ោង៩យប់ ទើបរំសាយពីការងារនាំគ្នាតម្រង់ជួរដើរត្រឡប់មកខ្ទមវិញ ។ នៅពេលដែលប្រជាជនតាមភូមិទូទាំង ឃុំកំពង់ថ្ម កំពុងតែជួបការខ្វះខាត ហូបបបរាវជួនកាលបបរលាយជាមួយដំឡូងឈើនោះ កម្លាំងចល័តដែលមកចូលរួមពលកម្មលើកទំនប់ភូមិភាគ១មករានេះ ត្រូវបានទទួលរបបហូបបាយទាំងព្រឹកទាំងល្ងាច តែទោះជាយ៉ាងនេះក្តី ដោយមនុស្សច្រើនពេកការរស់នៅខ្វះអនាម័យ និងការងារពលកម្មហួសកម្លាំង បណ្តាលឲ្យកើតជំងឺជាច្រើន ហើយគ្មានថ្នាំសង្កូវព្យាបាលផង ។

វត្តញកំពង់ថ្ម ត្រូវបានរៀបចំជាមន្ទីរពេទ្យភូមិភាគ ព្រោះ

មានទីតាំងនៅមិនឆ្ងាយប៉ុន្មានទេពីការដ្ឋាន ។ មានអ្នកជំងឺរាប់រយនាក់ត្រូវគេបញ្ជូនមកសម្រាកព្យាបាលក្នុងព្រះវិហារទាំងជាន់លើជាន់ក្រោមពេញទៅដោយអ្នកជំងឺគ្រប់ប្រភេទ ហើយអ្នកជំងឺដែលស្លាប់ភាគច្រើនដោយជំងឺអាសន្នរោគ ត្រូវបានគេយកទៅកប់ជាជួរតាមចន្លោះគល់គគីរមួយដុំដែលនៅមិនឆ្ងាយពីគល់ត្នោតដែលបងហឿងបានឲ្យទឹកត្នោតខ្ញុំមួយបំពង់កាលពីថ្ងៃមកដល់កំពង់ថ្មដំបូង ។

ក្រៅពីស្លាប់ដោយជំងឺ ស្ទើរតែរាល់យប់ខ្ញុំនៅបានឮសូរកាំភ្លើងរបស់ពួកមិត្តយោធាដេញបាញ់ប្រថាប់ពេញព្រៃ ។ បាញ់ពួកអ្នក១៧មេសាដែលព្យាយាមរត់ទៅស្រុកសៀម ហើយដែលមិនស្គាល់ស្ថានភាពភូមិសាស្ត្រច្បាស់លាស់ ដោយគិតស្មានថាមកដល់ការដ្ឋានទំនប់១មករានេះ អាចមានឱកាសភៀសខ្លួនទៅស្រុកសៀមបាន ។ តាមពិតនៅក្នុងព្រៃមានពួកយោធារាប់សិបនាក់យាមប្រចាំការទាំងយប់ទាំងថ្ងៃ ។ កាលនោះ ពួកយោធាច្រើនប្រើពាក្យថា បាញ់បានពួក "សៀមបាយត្រី" គឺពួកស៊ីបាយក្រៀម ។ នៅក្នុងពេលកំពុងរែកដី ខ្ញុំនៅបានឃើញមានប្រតិភូជាភ្ញៀវមកពីប្រទេសចិនប្រជាមានិតដែលមានពាក់អាវដៃខ្លីពណ៌សដូចគ្នាជាច្រើននាក់ ។ អង្គការបានរៀបចំទទួលភ្ញៀវយ៉ាងរាក់ទាក់កក់ក្ដៅ និងដោយមានកងកម្លាំងការពារយ៉ាងរឹងមាំផង ។ ប្រតិភូមកពីវៀតណាមក៏ធ្លាប់បានមកធ្វើទស្សនកិច្ចនៅទំនប់១មករាដែរ មានពេលខ្លះអង្គការបានចាត់តាំងកម្លាំងជាច្រើនស្រុកឲ្យរែកទឹកយកមកស្រោចលើខ្នងទំនប់ ដើម្បីកុំឲ្យដីហុយលើប្រតិភូជាភ្ញៀវ ។ នៅទីស្នាក់ការក្បាលទំនប់ទ្វារបិទបើកទឹកអង្គការមានទទួលភេសជ្ជៈទឹកក្រូចនិងដូងខ្ចីដល់ភ្ញៀវ ខ្ញុំនៅបានឃើញភ្ញៀវជាមិត្តហូបទឹកដូងនៅសល់ហើយបានចាក់ទឹកដូងចែកគ្នាលាងដៃទៀតផង ។

ក្រោយមកកងកម្លាំងវ័យកណ្ដាល ក៏បានលើកគ្នាពីវាលត្បែងកោងមកចូលរួមលើកទំនប់១មករានេះដែរ ដោយនៅសល់តែកងភ្ជួរនៅប្រចាំការភ្ជួររាស់នៅទីនោះ ។ ថ្ងៃមួយក្នុងឱកាសកំពុងតែរែកដីចាក់លើខ្នងទំនប់ក្បែរគ្នានឹងកម្លាំងប្រជាជនមកពីភូមិភាគបូព៌ា ខ្ញុំបានដឹងថា មីងណារុង គាត់បានជួបឬបានស្គាល់អ្នកណាមកពីកំពង់ចាម ឃុំពាមជីកងទេ តែក្នុងពេលសម្រាកគាត់បានមកប្រាប់ខ្ញុំដោយគាត់បានទទួលដំណឹងថាបងស្រ៊ាង បងសារុំ រំដួល ម្ដាយ និងប្អូនស្រីឈប់នៅកោះអណ្ដែតទៀតហើយ ដោយផ្ទះត្រូវអង្គការរុះយកទៅសង់រោងបាយរួម គាត់បានផ្លាស់ទីលំនៅមកនៅភូមិស្វាយតាហែន ត្រើយម្ខាងពាមជីកងជុំគ្នាជាមួយឪពុកម្ដាយខាងបងស្រ៊ាងវិញ ហើយគាត់ទាំងអស់គ្នាបានសុខសប្បាយជាទេ ទាំងបងសំអាង (បងប្រុសរំដួល) និងគ្រួសារគាត់បានមកនៅជួបជុំគ្នានៅភូមិស្វាយតាហែនដែរ ។ ខ្ញុំហាក់ដូចជាបានទទួលអារម្មណ៍រំភើបត្រេកអរ ព្រោះនេះជាលើកដំបូងបង្អស់ហើយ ដែលខ្ញុំបានទទួលដំណឹងសុខទុក្ខពីពួកគាត់ បន្ទាប់ពីបែកគ្នាជិតពីរឆ្នាំមកហើយនេះ ។

នៅនឹងការដ្ឋានទំនប់១មករា សម្រុកការងាររបស់ខ្ញុំដប់ថ្ងៃ បានសម្រាកមួយថ្ងៃដែរ ដោយការដ្ឋាននៅឆ្ងាយបន្តិចពីភូមិ ហើយត្រូវដើរកាត់ព្រៃយ៉ាងយូរទំរាំតែនឹងដល់ដើមភូមិឃ្លៃនោះ ខ្ញុំមិនសូវមកលេងភូមិប៉ុន្មានទេ តែរាល់ពេលដែលខ្ញុំមកលេងភូមិ ខ្ញុំតែងតែទៅជួបបងហឿង នៅឯរោងភ្ជួរ និងទៅលេងម៉ែឡាញ់ជារឿយៗហើយឱកាសចុងក្រោយនេះ ខ្ញុំបានទៅភូមិទួលសង្កែដើម្បីទៅសួរសុខទុក្ខពូផន ។

មីងណារុង មានផ្ទៃពោះ គ្រាដែល ពូផន ធ្លាក់ខ្លួនឈឺជាទម្ងន់ ជំងឺហើមរាលដាលរាងកាយរបស់គាត់កាន់តែខ្លាំង ដៃជើង និងខ្លួនគាត់ទាំងមូលហើមស្ទើរតែចេញទឹកមុខគាត់ហើមមើលសឹងតែមិនស្គាល់ គាត់សម្រាន្តនៅមួយកន្លែងក្រើកខ្លួនបានទាំងលំបាក ។ គាត់ក៏បានដឹងខ្លួនឯងយ៉ាងច្បាស់ថា គ្មានសង្ឃឹមនឹងបានរស់នៅតទៅទៀតទេ ព្រោះពីមួយថ្ងៃទៅមួយថ្ងៃកាន់តែដុនដាបទៅៗ ។

ខ្ញុំអង្គុយស្រក់ទឹកភ្នែក ដោយអាណិតអាសូរដល់រូបគាត់យ៉ាងខ្លាំង តែគាត់បែរជាពោលមកកាន់ខ្ញុំវិញ ដោយគ្មានតក់ស្លុតបន្តិចសោះថា ជីវិតពូមួយ ពូអត់សោកស្ដាយទេពូត្រេកអរទៅវិញ ដោយពូបានស្លាប់ក្នុងសភាពបែបនេះ ពូដឹងហើយថាពួកអាក្អែកខ្មៅអស់នេះ វាសាហាវព្រៃផ្សៃយ៉ាងណានោះ តែពូត្រេកអរប្រសើរជាជាងស្លាប់ដោយត្រូវនឹងត្បូងចបរបស់ពួកវា ។

ពូផន នៅបានផ្ដាំឲ្យខ្ញុំខំថែរក្សាខ្លួនប្រយ័ត្នប្រយែងពាក្យសំដីអត់ធ្មត់តស៊ូយ៉ាងណាឲ្យបាននៅរស់រានមានជីវិត តាមច្បាប់ធម្មជាតិអ្វីៗសព្វបែបយ៉ាងគង់តែនឹងផ្លាស់ប្ដូរ ស្រុកយើងក៏ដូច្នេះដែរ មិនមែនរស់នៅក្នុងរបបអមនុស្សធម៌ព្រៃផ្សៃអីចឹងរហូតទេ ។

ជាប់បន្តពីរោងកងចល័តយុវជនវរៈទីមួយ គឺរោងឃុំកកោះ ដែលមានគ្នាមិនដល់៣០នាក់ផង ហើយភាគច្រើនស្ថិតក្នុងវ័យ

កណ្តាល ។ ក្នុងចំណោមនោះខ្ញុំបានស្គាល់យុវជនម្នាក់ឈ្មោះ ឆារ៉ាក់ ដែលត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាអ្នកដណ្តាំស្ល ។

ឆារ៉ាក់ អ្នកភូមិកកោះ ឃុំកកោះ ស្រុកកំណើតនៅភូមិព្រៃជ្រើង ព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ ពេលជម្លៀសចេញពីភ្នំពេញបែកពីឪពុក សព្វថ្ងៃរស់នៅជាមួយម្តាយនិងប្អូនស្រីពីរនាក់ ។ ខ្ញុំ និងឆារ៉ាក់ បានស្រឡាញ់រាប់អានគ្នាជាភាតរៈ រាល់ៗលើក ពេលដែលខ្ញុំទៅលេងភូមិបានស្ករត្នោតពីបងហឿង ខ្ញុំបានចែករំលែកឲ្យឆារ៉ាក់ ហូប ព្រោះឃុំកកោះមិនសូវសម្បូរស្ករត្នោតទេ ហើយជាញឹកញយ ឆារ៉ាក់ បានលួចលាក់ត្រីងៀត ដោយសៀតនឹងដំបូលរោងមួយកន្លែងទុកឲ្យខ្ញុំ ។

នៅពីមុខរោងឃុំកកោះ ទន្ទឹមគ្នានឹងរោងយុវនារីវរៈទីពីរ គឺជារោងទីស្នាក់ការរបស់ពួកមិត្តយោធាស្រុក សន្ទុកដែលមានគ្នាប្រហែល២០នាក់យាមប្រចាំការទាំងយប់ទាំងថ្ងៃ ហើយមានចិញ្ចឹមឆ្កែមួយក្បាលផង ។

ព្រលប់ថ្ងៃមួយ ឆ្កែរបស់ពួកយោធាស្រុកមិនដឹងជាទៅកកាយពីណាមកទេ បានដៃខ្មោចមួយកំណាត់មក ទម្លាក់ចោលនៅកណ្តាលរោងយុវនារីវរៈទីពីរ ។ ដោយកត់ស្លុតភ័យខ្លាចពួកនារីៗស្រែកឆោឡោរត់ប្រសាចពេញរោង ខ្ញុំឃើញមិត្តយោធាម្នាក់បានយកស្លឹកត្បែងមួយសន្លឹកធំមកទ្រាប់កាន់ដៃខ្មោចមួយកំណាត់នោះ រត់ដេញ តាមបន្លាចពួកនារីៗលេងជាល្បែង ។

ប៉ុន្មានថ្ងៃក្រោយមកទៀត មានកើតហេតុចំឡែកមួយ ដែលកាលនោះអង្គការគ្រប់មូលកំពុងតែវាយបំបាត់អរូបិយជំនឿលើអារុក្ខអារក្សអ្នកតាខ្មោចព្រាយបិសាច ស្រាប់តែយប់នោះមានខ្មោចចូលនារីអ្នកមូលដ្ឋានចាស់ម្នាក់ប្រកាច់ទាញកន្ត្រាក់ដៃជើង ទាញមុខទាញមាត់ បើកភ្នែកធំៗ គ្រលួងមើលទៅគួរឲ្យខ្លាច ។

ជាមួយនឹងសម្រែកដោយសំឡេងគ្រលរៗ មិត្តនារីនោះស្រែកទាមទារហាក់ដូចជាមិនសុខចិត្តនឹងរឿងអ្វីមួយ ។ មិត្តនារីដែលជាប្រធានវរៈដោយពុំមានជំនឿទាល់តែសោះ បានទៅហៅពួកយោធាបីបួននាក់ឲ្យមកជួយចាប់ ។ មិត្តនារីខ្មោចចូលរាងតូចស្គមកំព្រឹង តែមិនដឹងជាមានកម្លាំងមកពីណា រហូតដល់មិត្តយោធាបីបួននាក់នោះចាប់សឹងពុំឈ្នះ ។

«យើងមិនសុខចិត្តទេ ទីកន្លែងដែលយើងធ្លាប់រស់នៅយ៉ាងសុខសាន្តតាំងពីដូនតាយើងមក ម៉េចក៏នាំគ្នាមកកាប់គាស់រុករាន ដុតបំផ្លាញខ្ទេចខ្ទីអស់ ថែមទាំងមានក្លិនស្អុយ ឆ្អេះឆ្អាបសព្វទីកន្លែងយ៉ាងដូច្នេះ យើងមិនសុខចិត្តទេ!» មិត្តនារីខ្មោចចូលបានស្រែកទន្ទ្រាំជើងយ៉ាងខ្លាំង ។

មិត្តសាយ ដែលកំពុងតែឈរមើលក្បែរនោះ បានលាន់មាត់ថា »បើអ្នកណាមិនជឿ ខ្ញុំជឿ...» រួចហើយ គាត់បានប្រាប់ទៅនារីប្រធានវរៈឲ្យរង់ចាំមួយភ្លែត គាត់ទៅរកចាស់ទុំ ។

មួយសន្ទុះក្រោយមក មិត្តសាយ បានដើរត្រឡប់មកវិញជាមួយអ៊ុំស្រីចុងភៅពីរនាក់ មានទាំងកាន់អង្ករពីរកូនចានមកជាមួយផង ។ ខ្ញុំឃើញគាត់ទាំងពីរនាក់ លើកចានអង្ករឡើងបួងសួងដោយគោរព គាត់គ្រវាសអង្ករទៅលើខ្លួននារីនោះ បណ្តើរ និយាយបណ្តើរថាៈ «សូមអស់លោកម្ចាស់ទឹកម្ចាស់ដី ម្ចាស់ព្រៃព្រឹក្សា មេត្តាកុំប្រកែប្រកាន់នឹងកូនចៅអី កូនចៅមកកាប់គាស់រុករាននៅទីនេះ មិនមែនមកធ្វើដោយចិត្តឯងទេ គឺមកតាមបញ្ជារបស់អង្គការ ដូច្នេះសូមកុំប្រកែប្រកាន់នឹងកូនចៅអី សូមអស់លោកទៅរកកន្លែងថ្មីរស់នៅឲ្យបានសុខសាន្តចុះ ហើយសូមឈប់មកធ្វើបាបកូនចៅទៀតទៅ កូនចៅអត់ដឹងអីទេ» ។

គ្រាដែលគាត់ទាំងពីរគ្រវាសអង្ករចុងក្រោយបង្ហើយពីចាន ខ្ញុំបានឃើញនារីនោះនៅអង្គុយស្ងៀមធ្មឹង ហាក់ដូចជាទទួលស្តាប់នូវពាក្យបែរបន់អង្វរក បន្តិចក្រោយមកជាមួយនឹងដង្ហើមធំយ៉ាងវែង ស្រាប់តែនារីនោះផ្តួលខ្លួនដាច់ផ្ងារទៅក្រោយ ហើយក៏ភ្ញាក់ដឹងខ្លួនឡើងវិញ ហាក់ដូចជាមិនដឹងថា មានរឿងអ្វីកើតឡើងទាល់តែសោះ ។

នៅនឹងការដ្ឋានទំនប់១មករា ថ្ងៃមួយខ្ញុំបានទទួលដំណឹងពីភូមិធនមោងមកថា បងតៃ ដែលត្រូវបានពួកយោធាចាប់ខ្លួនពីការដ្ឋានរលួសត្រពាំងវែងយកទៅដាក់គុកនៅទ្វីរូមខេត្តកំពង់ធំនោះ ត្រូវបានគេដោះលែងមកវិញហើយ ដោយមានយោធាតំបន់ម្នាក់ឌុបកង់យកគាត់មកទម្លាក់ចោលនៅមាត់ផ្លូវប្រកចូកទៅភូមិធនមោង ។

បងតៃ គាត់ស្គមនៅសល់តែស្បែកដណ្តប់ឆ្អឹង ពុំមានកម្លាំងនឹងវារពីមាត់ថ្នល់ចូលមកភូមិវិញផង គាត់ត្រូវបានអ៊ុំម្នាក់ជាឪពុករបស់មិត្តខុន ប្រធានកងមកជួយគ្រាហ៍គាត់ពីមាត់ថ្នល់ទៅរហូតដល់ផ្ទះ ។ ថ្ងៃសម្រាកបិទវគ្គដប់ថ្ងៃទើបខ្ញុំបានឆ្លៀតទៅជួបបងតៃ គាត់រស់នៅ

តែម្នាក់ឯងនៅនឹងកូនខ្ទមដែលបងស្រីគាត់នឹងក្មួយៗទាំងអស់ត្រូវបានអង្គការយកទៅសម្លាប់ប៉ុន្មានថ្ងៃបន្ទាប់ពីគាត់បានចេញទៅការដ្ឋានរលោះ ។ អ្នកមូលដ្ឋានចាស់នៅភូមិធនមោងជាច្រើននាក់ ជាពិសេសឪពុកម្តាយមិត្តខុនមានចិត្តអាណិតអាសូរជួយយកអាសារបងតៃ ដោយបានផ្តល់ចំណីចំណុកជាហូរហែ ។

គ្រាន់តែបានឃើញខ្ញុំភ្លាម បងតៃ ស្រវាឱបខ្ញុំយំទាំងទឹកភ្នែកហូរសស្រាក់ ពេលនោះខ្ញុំសែនក្តុកក្តួលក្នុងចិត្តឥតឧបមានឹកអាណោចអាធ័មដល់រូបកាយដ៏ស្គមស្គាំងភ្នែកទាំងគូរបស់គាត់រូងជ្រៅ មើលទៅហួសនិស្ស័យជាមនុស្ស ។ បងតៃ យំបណ្តើរ រៀបរាប់ប្រាប់ខ្ញុំបណ្តើរថា «ទឹកដោះម្តាយបងថ្លៃណាស់ ដោយបងមានវាសនាបាននៅរស់រានមានជីវិត អ្នកផ្សេងដែលពួកវាចាប់យកទៅជាមួយបងនោះត្រូវបានពួកវាសម្លាប់ចោលអស់ហើយ» ។

បងតៃ នៅបានរៀបរាប់ប្រាប់ខ្ញុំទៀតថា ជាប់ក្នុងគុកកំពង់ធំជិតមួយឆ្នាំមកនេះ វេទនាហួសនិស្ស័យ គុករបស់អង្គការគឺ ជាឋាននរកពិតៗ ។ ពេលដែលខ្ញុំសួរគាត់ពីការធ្វើទារុណកម្មលើអ្នកទោសក្នុងគុក បងតៃ បានតបមកខ្ញុំវិញថារូបគាត់មិនអាចនិយាយបានទេ ព្រោះមុនពេលដែលគេដោះលែង គេបានឲ្យគាត់ចុះកិច្ចសន្យាថាមិននិយាយប្រាប់អ្នកណាទាំងអស់ពីអ្វីដែលកើតមានឡើងនៅក្នុងមន្ទីរឃុំឃាំងនេះ ។ បងតៃ បានបន្តថា ប្រធានគុកខេត្តកំពង់ធំ មានអតីតភាពជាបញ្ញវន្តមកពីស្រុកបារាំង មានអាយុប្រមាណជាង៤០ឆ្នាំ ជាមនុស្សទ្រឹស្តីនិយម និងគំនិតនិយមបំផុត ។ អ្នកទោសទាំងអស់បានទទួលរបបទឹកបបរាវមួយពេលមួយវែកត្រូវបង្ខំឲ្យធ្វើការជាទម្ងន់ មានអ្នកទោសច្រើនណាស់ដែលដួលស្លាប់ក្នុងពេលធ្វើការ ។ ក្នុងមួយខែម្តងអ្នកទោសត្រូវបានគេនាំយកទៅធ្វើទារុណកម្មម្តងដើម្បីសួរចម្លើយមានអ្នកទោសភាគច្រើនដែលទ្រាំទ្រពុំបាន និងទារុណកម្មដ៏សាហាវព្រៃផ្សៃបំផុតនោះ ក៏ចេះតែឆ្លើយសារភាពដាក់អ្នកនេះអ្នកនោះតែទីបំផុតក៏ត្រូវបានពួកវាយកទៅសម្លាប់ចោលដដែល ។ រាល់ពេលធ្វើទារុណកម្មសួរចម្លើយរូបគាត់ដែលជាបញ្ញវន្តមួយរូបដែរនោះ មានការប្រឈមមុខគ្នាយ៉ាងខ្លាំងជាមួយប្រធានគុក ហើយទោះជារងនូវទារុណកម្មខ្លាំងយ៉ាងណាក៏ដោយ ក៏គាត់នៅតែរក្សាចម្លើយរបស់គាត់ដដែល ។ ទីបំផុតអស់រយៈពេលជិតមួយឆ្នាំ ដោយរកពុំឃើញមានកំហុសអ្វីបន្តិចសោះ ប្រធានគុកក៏បានសម្រេចដោះលែងរូបគាត់ឲ្យត្រឡប់មកភូមិវិញ ។

ប្រមាណពីរខែបន្ទាប់មក សភាពការណ៍ទូទាំងស្រុកសន្ទុកមានការប្រែប្រួលយ៉ាងខ្លាំង ជាពិសេសក្នុងឃុំកំពង់ថ្ម ។ សមមិត្តលឹម ប្រធានឃុំបានធ្វើការផ្លាស់ប្តូរសមាសភាពប្រធានសហករណ៍តាមភូមិសាជាថ្មី ។

សមមិត្ត លន អតីតយោធាត្រូវបានចាត់តាំងជាប្រធានភូមិថ្មីនៅភូមិទួលសង្កែ សមមិត្ត ទុយ (ហៅអន្ទិតទុយ) ប្រធានក្រុមក្នុងកងយុវជនចល័តឃុំ ត្រូវបានចាត់តាំងជាប្រធានភូមិកងសៅ មិត្តនារីហេង កូនស្រីពៅរបស់តាសាំងគ្រូខ្មែរ មានអាយុ១៧ឆ្នាំ ត្រូវបានចាត់តាំងជាប្រធានភូមិឈើទាល ។ ទន្ទឹមនឹងនោះសកម្មភាពបោសសម្អាតចាប់ខ្លួនខ្សែរយៈ «ពួកក្បត់អង្គការ» ទាំងខ្សែៗតាំងពីថ្នាក់ភូមិភាគរហូតដល់ថ្នាក់មូលដ្ឋានភូមិឃុំ មានសភាពកាន់តែខ្លាំងក្លាដែលបង្កឲ្យមានភាពច្របូកច្របល់យ៉ាងខ្លាំង ជាពិសេស ក្នុងចំណោមពួកអ្នកមូលដ្ឋានចាស់ ។

ប្រជាជនអ្នកមូលដ្ឋានចាស់ជាច្រើនគ្រួសារដែលមានអតីតភាពជាអ្នកផ្សារនៅភូមិកំពង់ថ្ម ត្រូវបានអង្គការយកទៅសម្លាប់ទាំងគ្រួសារៗ ហើយក្រោយមកទើបបានលេចឮដំណឹងតៗគ្នាមកថា ក្រុមគ្រួសារទាំងនោះមានឈាមជ័រកាត់យួន ។

នៅឯការដ្ឋានត្បែងកោង មិត្តស្រស់ ដែលទើបតែនឹងរំសាយពីអង្គភាពយោធា មកជួបម្តាយមេម៉ាយនៅ ភូមិឃ្លៃមិនទាន់បានកន្លះឆ្នាំផង ក៏ត្រូវបានអង្គការយកទៅសម្លាប់ចោលដែរ ។

ប្រជាជនទូទាំងឃុំកំពង់ថ្មមានការភ្ញាក់ផ្អើលខ្លាំង លើសនោះទៅទៀត ដោយតាសួងនៅភូមិទួលសង្កែដែល ផ្ទះគាត់អ្នកស្រុកអ្នកភូមិធ្លាប់បានស្គាល់ថាជាផ្ទះអង្គការនោះ នារសៀលថ្ងៃមួយត្រូវបានអង្គការយករថយន្តឡង់រ៉ូវេរពណ៌ប្រផេះមួយគ្រឿងមកទទួលយកគាត់ទៅចូលរួមប្រជុំនៅឯភ្នំពេញ ។

ប៉ុន្មានថ្ងៃក្រោយមក ខ្ញុំបានធ្វើដំណើរទៅលេងភូមិ ដើម្បីទៅសួរសុខទុក្ខពូជន ហើយពេលដែលខ្ញុំឆ្លៀតឱកាសចូលទៅសួរសុខទុក្ខគ្រួសារលោក អ៊ុក ភឹន ជាគ្រូបង្រៀនមានដើមកំណើតនៅភូមិក្បាលកោះអណ្តែតដែលត្រូវបានអង្គការបានចាត់តាំងឲ្យមករស់នៅនឹងជង្រុកស្រូវតាសួង តាំងពីថ្ងៃជម្លៀសមកពីស្រុកទន្លេដំបូងនោះ ដោយចៃដន្យ ខ្ញុំបានជួបលោកយាយប្រពន្ធតាសួង និងបងចាន់ធូ

កូនប្រសារស្រីរបស់គាត់នៅឯមាត់អណ្តូងទឹកខាងក្រោយផ្ទះ ។

ដោយទឹកមុខក្រៀមក្រំស្រពាប់ស្រពោន លោកយាយប្រពន្ធតាសួង បាននិយាយមកកាន់ខ្ញុំថា គេយកឡានមកទទួលតាឲ្យទៅប្រជុំនៅឯភ្នំពេញ តែតាបានត្រៀមខ្លួនជាស្រេចមិនចាញ់បោកកលល្បិចឲ្យពួកវាធ្វើបាបគាត់បានទេ គាត់បានដាក់ថ្នាំពុលសម្លាប់ខ្លួនភ្លាម ។

បីថ្ងៃក្រោយមក រថយន្តឡង់រ៉ូវែរដែលបានទទួលយកលោកយាយ បងចាន់ ធូ និងកូនតូចរបស់គាត់ ដែលពរជាប់នៅនឹងដៃ ដោយអង្គការបានប្រាប់ថា នាំយកពួកគាត់ទៅលេងតានៅភ្នំពេញ ។ ខ្ញុំនឹកស្រណោះដល់បងចាន់ធូ ខ្លាំងណាស់ ព្រោះរាល់ពេលដែលគាត់បានជួបខ្ញុំ គាត់តែងតែនិយាយលេងនឹងខ្ញុំថាៈ «ឃើញប្អូនឯងស្លៀកខោជ្ជេរ៩ អ៊ីចឹង ធ្វើឲ្យបងនឹករលឹកដល់ប្តីបងយ៉ាងខ្លាំង ប្តីបងទាំងមាឌទាំងកម្ពស់កម្ពរដូចប្អូនឯងបេះបិទ» ។ បងចាន់ ធូ ធ្លាប់បានប្រាប់ខ្ញុំថា ប្តីគាត់ជាកូនបង្កើតរបស់តាសួង ជានិស្សិតវិស្វករ បែកពីរូបគាត់ និងកូន នៅថ្ងៃដែលពួកខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។

ជាមួយនឹងសកម្មភាពដ៏ក្តៅគគុក ដែលអង្គការបានឲ្យឈ្មោះថា «បោសសម្អាតរនុកក្នុងយួន» នោះក្នុងជួររដ្ឋអំណាចគ្រប់ជាន់ថ្នាក់ សភាពការណ៍កាន់តែចលាចលច្របូកច្របល់ខ្លាំងឡើងៗ ធ្វើឲ្យបដិវត្តន៍ ក្រោមការដឹកនាំរបស់អង្គការតែមួយ មិនដឹងជាអ្នកណាក្បត់អ្នកណា ទីបំផុតស្រាប់តែបាត់ខ្លួន ដោយត្រូវបានអង្គការចោទថាជាខ្សែរយៈក្បត់ ឬជារនុកក្នុងយួន ។ល ។

ខែមីនា ឆ្នាំ១៩៧៧ អង្គការបានជម្លៀសប្រជាជនប្រមាណជិតបីរយគ្រួសារពីក្រុងកំពង់សោម ឲ្យមករស់នៅក្នុងស្រុកសន្ទុកទាំងមូល ក្នុងចំណោមនោះមានប្រជាជនប្រមាណជិតមួយរយគ្រួសារ ត្រូវបានអង្គការបញ្ជូនឲ្យមករស់នៅតាមភូមិនានា ក្នុងឃុំកំពង់ថ្ម ។ អ្នកជម្លៀសមកពីកំពង់សោម ភាគច្រើនជាប្រជាជនថ្មីដែលតាំងពីថ្ងៃដាច់ភ្នំពេញមកម្ល៉េះ ត្រូវបានអង្គការប្រមូលឲ្យចូលបម្រើការងារវិញតាមអង្គភាពនានានៅក្រុង និងនៅកំពង់ផែកំពង់សោម ។

អ្នកជម្លៀសមកពីកំពង់សោម មានយុវជន យុវនារីកម្លាំងពូមីងក្នុងវ័យកណ្តាល ត្រូវបានរដ្ឋអំណាចតាមភូមិនានា បែងចែកឲ្យចុះទៅប្រយុទ្ធការងារតាមការដ្ឋានភ្លាមៗ ។

បងស្រីម្នាក់ ដែលគ្រួសារគាត់ និងគ្រួសារអ្នកកំពង់សោមមួយចំនួនទៀត ត្រូវបានអង្គការចាត់តាំងឲ្យមករស់នៅភូមិឈើទាល បាននិយាយប្រាប់ខ្ញុំថា ពួកគាត់ជាប្រជាជនស្លូតត្រង់ធ្វើការធម្មតាក្នុងអង្គភាពមួយនៅក្រុងកំពង់សោម អត់បានដឹងរឿងអីទាំងអស់ ស្រាប់តែលេចឮដំណឹងតៗគ្នាថា ប្រធានអង្គភាពរបស់ពួកគាត់ក្បត់អង្គការ ប្រុងសើរើប្រឆាំងនឹងអង្គការ ទើបអង្គការជម្លៀសពួកគាត់ចេញពីកំពង់សោម ។

ដំបូងទិសដៅរបស់អង្គការគឺជម្លៀសពួកគាត់ទៅខេត្តកំពង់ចាម ឲ្យពួកភូមិភាគបូព៌ាសម្លាប់ចោល តែដួនពេលនោះសភាពការណ៍នៅភូមិភាគបូព៌ាកំពុងតែច្របូកច្របល់ដោយគណៈភូមិភាគបូព៌ាក្បត់ដែរនោះ ទើបបានអង្គការដាក់ទិសបញ្ជូនពួកគាត់ឲ្យមកកំពង់ធំភូមិភាគពាយ័ព្យនេះវិញ ។

ប្រជាជនអ្នកជម្លៀសមកពីកំពង់សោមខំប្រឹងធ្វើការណាស់ អត់ហ៊ានមាត់កអីទាល់តែសោះ ។ ខ្ញុំនៅចាំយ៉ាងច្បាស់ណាស់ក្នុងចំណោមអ្នកមកពីកំពង់សោមទាំងអស់ គ្រួសារលោក យក់ សាម៉េត នៅភូមិកំពង់ថ្ម មានកូនស្រីពីរនាក់ឈ្មោះអារ៉ា, អារុំ ដែលកំពុងតែប្រយុទ្ធការងារយ៉ាងសកម្មនៅឯការដ្ឋាន ត្រូវបានអង្គការយកទៅសម្លាប់ទាំងគ្រួសារមុនគេបង្អស់ ។

សភាពការណ៍ដ៏ចម្លែកថ្មីមួយទៀតបានកើតឡើងនៅឯភូមិទួលសង្កែ សមមិត្តលន ដែលមិត្តលឹម ទើបតែនឹងបានចាត់តាំងឲ្យធ្វើជាប្រធានភូមិថ្មីៗ មិនទាន់បានបីខែផង យប់មួយក្នុងឱកាសយាមល្បាតក្នុងភូមិមិត្តលន ត្រូវបានកងឈ្លបពីរនាក់ជាបងប្អូនបង្កើតនឹងគ្នាកាប់សម្លាប់ចោលនឹងកាំបិតផ្គាក់ ។

តាំងពីពេលដែលមានភាពយ៉ាងច្របូកច្របល់នោះមក អ្នកមូលដ្ឋានចាស់ដែលមានគំនុំមានវិវាទនឹងគ្នា បានឆក់ឱកាសធ្វើការកាប់សម្លាប់សងសឹកគ្នាទៅវិញទៅមកយ៉ាងសាហាវ ហើយម្នាក់ៗសំលៀងកាំបិតពូថៅត្រៀមលក្ខណៈរៀងខ្លួន ។

មិត្តឈាង ប្រធានគុកស្អរ ត្រូវបានចាត់តាំងជាប្រធានភូមិជំនួសខ្មោចមិត្តលន ។ ក្នុងពេលប្រជុំរួមជាលើកដំបូង ក្រោយពីបានឡើងធ្វើជាប្រធានភូមិថ្មីៗ មិត្តឈាង បានប្រកាសប្រាប់ ប្រជាជនទូទាំងភូមិថា ភូមិយើងមានស្អរគ្មោតច្រើនណាស់រាប់គោននៅក្នុងឃ្លាំងដែលប្រធានភូមិមុនៗទុកសម្រាប់បញ្ជូនទៅឲ្យអង្គការលើ

តែពេលនេះខ្ញុំ មិត្តឈាង សម្រេចចិត្តចំពោះមុខបងប្អូនទាំងអស់ថាៈ «អង្ករការលើចាំក្រោយ ខ្ញុំសូមគិតគូរចែកជូនបងប្អូនប្រជាជនក្នុងភូមិជាមុនសិន» ។ កាលនោះខ្ញុំនឹកគុណមិត្តឈាង មិនស្ទើរទេ ព្រោះពួកខ្ញុំដែលជាកងយុវជន យុវនារីប្រយុទ្ធការងារនៅឯការដ្ឋាន មិនដែលមានវត្តមាននៅក្នុងភូមិ ក៏មិត្តឈាង នៅបានចែករំលែករបបស្ករត្នោតទុកឲ្យដែរ មិនត្រឹមតែប៉ុណ្ណោះ ពេលដែលពួកខ្ញុំបានសម្រាកទៅលេងភូមិ មិត្តឈាង បានហៅពួកខ្ញុំឲ្យទៅបើករបបក្រមានៅឯ រោងតម្បាញកាត់ពីកីថ្មីៗដូចដណ្ដើមពីយាយៗកំពុងត្បាញ ។ មិត្តឈាងនៅបាននិយាយប្រាប់យាយៗជាអ្នកតម្បាញក្រមាថាៈ «ត្បាញបានក្រមាមួយកាត់មួយ ត្បាញបានក្រមាពីរកាត់ពីរចែកជូនបងប្អូនក្នុងភូមិឲ្យអស់ ឲ្យបានគ្រប់ៗគ្នាសិន សឹមយើងគិតអង្ករជាក្រោយ» ។

នៅនឹងការដ្ឋានទំនប់១មករា មិត្តសាយ ប្រធានវរៈកំពុងតែធ្លាក់ខ្លួនឈឺចុះក្អួតរាករុសយ៉ាងខ្លាំង ។ នៅថ្ងៃបន្ទាប់មិត្តជន អនុប្រធានវរៈបានចាត់តាំងកម្លាំងយុវជនបួននាក់ឲ្យសែងមិត្តសាយ យកទៅមន្ទីរពេទ្យភូមិភាគនៅឯវត្តកំពង់ថ្ម សែងទៅជាបន្ទាន់ទាំងយប់ ។

ខ្ញុំក៏ស្ថិតនៅក្នុងចំណោមយុវជនទាំងបួននាក់នោះដែរ យើងសែងមិត្តសាយដែលកំពុងដេកស្ដឹកក្នុងអង្រឹងក្រណាត់កៅស៊ូពណ៌ស្វឹកឈើនឹងស្នែងឫស្សីមួយកំណាត់មានមិត្តអឿង មិត្តសំ អ្នកភូមិឈើទាលសែងផ្លាស់ប្ដូរជាមួយខ្ញុំ និងមិត្តសិនអ្នកភូមិឃ្លៃ ។ ទាំងកណ្ដាលយប់ងងឹត យើងនាំគ្នាសែងមិត្តសាយដើរកាត់ព្រៃរហូតដល់វាលអាគ្រាត្រ ទើបបានមកដល់មន្ទីរពេទ្យ ។

មានអ្នកជំងឺច្រើនណាស់កំពុងតែដេករណ្ដូករណែលពេញ ក្នុងវិហារ និងខាងក្រៅជុំវិញវិហារខាងក្រៅក៏ពេញដែរ យើងសែងមិត្តសាយ មកដាក់នឹងខឿនវិហារជ្រុងខាងជើង ហើយមិត្តអឿង ក៏បានដើរទៅរកពេទ្យ ។

ពេលត្រឡប់មកវិញ មិត្តអឿង បាននិយាយប្រាប់ខ្ញុំថាបន្តិចទៀតពេទ្យគេមកមើលហើយ មិត្តឯងកំដរ មិត្តសាយ នៅទីនេះចុះពួកខ្ញុំនាំគ្នាទៅសម្រាកនៅឯភូមិ ។ និយាយរួចពួកគាត់នាំគ្នាដើរចេញទៅភូមិរៀងៗខ្លួនទៅ ។ មួយសន្ទុះក្រោយមក មានមិត្តនារីពេទ្យម្នាក់បានមកដល់យកថ្នាំមកឲ្យមិត្តសាយ លេប ។ ពេញមួយយប់នោះខ្ញុំគ្មានបានសម្រាកបន្តិចឡើយ សូម្បីតែភ្នេចមួយស្រឡេតក៏មិនបានផង ព្រោះមិត្តសាយ រាកផងក្អួតផងជាច្រើនដង ។

ដោយអស់កម្លាំង មិត្តសាយ សម្ងំដេកស្ងៀមក្នុងអង្រឹង ខ្ញុំក៏សណ្ដូកជើងផ្អែកខ្នងទម្រេតខ្លួនទៅនឹងជញ្ជាំងវិហារភ្នេចភ្នែកសម្ងំ ។ បានតែមួយស្របក់ស្រាប់តែមិត្តសាយ ក្រោកអង្គុយហើយគាត់បាននិយាយមកកាន់ខ្ញុំថាៈ «មិត្តឯងស្គាល់ផ្ទះខ្ញុំទេ?» ខ្ញុំបានឆ្លើយទៅគាត់វិញភ្លាមថាៈ «បាទខ្ញុំស្គាល់» មិត្តសាយ បានសួរមកខ្ញុំទៀតថាៈ «មិត្តឯងហ៊ានដើរទៅភូមិទេ?» លើកនេះខ្ញុំបានឆ្លើយទៅគាត់វិញទាំងប្រថុយប្រថាន «បាទហ៊ាន» តែតាមពិតខ្ញុំខ្លាច ខ្ញុំគ្មានសេចក្ដីក្លាហានអ្វីបន្តិចទាល់តែសោះ ។

ភូមិឈើទាលនៅជិតបង្កើយ មើលទៅឃើញដំបូលផ្ទះអ្នកភូមិ តែក្នុងអារម្មណ៍ក្នុងចិត្តខ្ញុំកំពុងតែនឹកខ្លាច ដោយចុះពីព្រះវិហារទៅ ខ្ញុំត្រូវដើរកាត់កន្លែងកប់ខ្មោចអ្នកជំងឺដែលចោលភ្នែកមើលទៅឃើញតែខ្នងផ្នូររាប់រយតម្រៀបគ្នាក្រោមដើមគគីរខ្ពស់ៗមួយជួរ ។ ផុតពីនោះទៅ ខ្ញុំត្រូវដើរកាត់វាលមួយដែលមានដើមត្នោតទាបខ្ពស់ជាច្រើនដើមឈរទ្រឹងទាំងកណ្ដាលយប់ងងឹតស្ងាត់សូន្យដូចពួកព្រាយអសុរកាយ ដែលមានទម្ងាក់ធាងងាប់ៗធ្លាក់សំយ៉ុងចុះក្រោមត្រូវខ្យល់ជំនោរយោលតិចៗ ប៉ះទង្គិចគ្នាលាន់សូរជ្រោកៗគួរឲ្យខ្លាចព្រឺព្រួច ។

ពេលមកដល់មាត់ច្រកផ្លូវចូលភូមិ ខ្ញុំនឹងត្រូវដើរកាត់ច្រកចូលស៊ុបទ្រុបងងឹតស្លុបដោយមានដើមឫស្សីជាច្រើនគុម្ពដុះប្រក់ជុំជិត ។ ផ្ទះទីមួយនៅនឹងដើមភូមិ គឺជាផ្ទះដែលគ្មានមនុស្សនៅត្រូវបានគេបោះបង់ចោល ស្ងាត់ជ្រងំទាំងយប់ទាំងថ្ងៃ ។

ពីមុនក្នុងផ្ទះនេះមានគ្រួសារខ្មែរអ៊ីស្លាមជម្លៀសមកពីស្រុកក្រូចឆ្មារ ខេត្តកំពង់ចាមមួយគ្រួសាររស់នៅ ដែលមានកូនស្រីក្រមុំម្នាក់ឈ្មោះមិត្តយះ និងកូនប្រុសតូចៗពីរនាក់ទៀត ។ មិត្តយះ ជាកូនស្រីបងបង្អស់មានរូបសម្ផស្សស្អាតណាស់ សុភាពទន់ភ្លន់ នាងស្អាតរហូតដល់ខ្ញុំខ្លួនឯង ពេលដែលបានឃើញហើយសឹងតែមិនជឿភ្នែកថា ក្នុងលោកយើងនេះមាននារីស្រស់ស្អាតដល់ម្លឹង ។ កម្មអកុសលគ្រួសារមិត្តយក្ស ទាំងមូលត្រូវបានអង្គការយកទៅសម្លាប់បន្ទាប់ពីមករស់នៅភូមិឈើទាលនេះបានប្រហែលកន្លះឆ្នាំ ។

ពេលដែលអារម្មណ៍ខ្ញុំកំពុងតែស្ទុងវិលវល់យ៉ាងច្របូកច្របល់នោះ មិត្តសាយ បាននិយាយមកកាន់ខ្ញុំថា «មិត្តឯងទៅដាស់

ម៉ែខ្ញុំឲ្យគាត់ដាំបបរឲ្យខ្ញុំហូបបន្តិចមក» ។ ខ្ញុំឈានជើងចេញពីមិត្តសាយ ទាំងស្រាលខ្លួនថ្ងើកដូចដីឡី ខ្ញុំខិតខំបន្ទប់អារម្មណ៍ខ្ញុំកុំឲ្យនឹកខ្លាច តែពេលដែលខ្ញុំបោះជំហានទៅមុខមួយជំហានៗ ហាក់ដូចជាស្រាលជើងផុតៗពីដី គ្រាន់តែដើរហួសពីកន្លែងកប់ខ្មោចភ្លាម ខ្ញុំបន្ថែមល្បឿនរត់យ៉ាងលឿនប្រុយគ្មានហ៊ានងាកក្រោយបន្តិចឡើយ ។

ក្នុងភូមិទាំងមូលមានសភាពស្ងាត់ជ្រងំ ពេលថ្មើរហ្នឹងអ្នកភូមិគ្រប់ផ្ទះកំពុងតែលង់លក់ក្នុងដំណេកយ៉ាងស្កប់ស្កល់ ខ្ញុំឈានជើងឡើងកាំជណ្ដើរផ្ទះដោយថ្នមៗរួចខ្ញុំគោះទ្វារម្ដាយមិត្តសាយ ភ្ញាក់ពីដំណេករួចបើកទ្វារឲ្យខ្ញុំ ។ គ្រាដែលម្ដាយមិត្តសាយ កំពុងដាំបបរនៅឯចង្ក្រាន ឪពុក និងបងស្រីគាត់បានមកអង្គុយសំណេះសំណាលជាមួយខ្ញុំ គាត់ថាគាត់បានទទួលដំណឹងតាមរយៈមិត្តអឿង និងមិត្តសំបូលមកប្រាប់ ។ កណ្ដាលផ្ទះដែលមានដុតចន្លុះជ័រចុងមួយដើមបំភ្លឺក្រោលរនាបឈើតូចៗយ៉ាងរលោងត្រជាក់ សំណេះសំណាលគ្នាបណ្ដើរ អារម្មណ៍ខ្ញុំនឹកគិតបណ្ដើរដល់ឱកាសដែលនឹងត្រូវដើរត្រឡប់ទៅវត្តវិញ ។ គ្រាន់តែបបរឆ្អិនភ្លាម ម្ដាយមិត្តសាយ បានដួសដាក់ចានយួរមួយដែលមានគំរបបិទយ៉ាងជិត មានទាំងងៀតកូនត្រីផ្ទក់អាំងថ្មីៗ ចោលក្លិនយ៉ាងឈ្ងុយឆ្ងាញ់គួរឲ្យឃ្លានមួយកន្ទុយផង ។

ខ្ញុំបានយួរចានបបរដើរត្រឡប់មកវត្តវិញ ខ្ញុំខ្លួនឯងក៏មិនបានដឹងដែរថា ពេលដែលដើរត្រឡប់មកវិញ ខ្ញុំបានដើរលឿនដល់កម្រិតណាឡើយ តែខ្ញុំគ្រាន់តែបានដឹងថា ហាក់ដូចជាឆាប់បានមកដល់ ។ ខ្ញុំឃើញមិត្តសាយ កំពុងតែទន្ទឹងរង់ចាំដួវខ្ញុំ ។ ខ្ញុំរៀបបបរឲ្យគាត់ហូប មិត្តសាយ ហុតបបរក្ដៅៗបានតែពីរបីស្លាបព្រា ស្រាប់តែក្អួតរឹកចេញមកវិញអស់ ។

«មិត្តឯងហ៊ានដើរទៅភូមិម្ដងទៀតទេ?» លើកនេះខ្ញុំបានឆ្លើយតបទៅគាត់វិញដោយស្ម័យប្រវត្តិថា ៖ «បាទហ៊ាន» គាត់ក៏បានពោលមកកាន់ខ្ញុំទៀតថាៈ «បើអីចឹងមិត្តឯងទៅប្រាប់ម៉ែឲ្យរកដូងខ្ចីបានមួយផ្លែពីរមក» ។ ពេលដែលខ្ញុំបានដើរមកដល់ ពួកគាត់បានបិទទ្វារផ្ទះចូលទៅសម្រាន្តវិញអស់ហើយ ក្រោយពីខ្ញុំគោះទ្វារ បងស្រីមិត្តសាយ បានចេញមកបើកទ្វារឲ្យខ្ញុំ ខ្ញុំបានជម្រាបគាត់សព្វគ្រប់រួចហើយ គាត់ក៏បានដើរចូលទៅក្នុងបន្ទប់ ដែលបាំងដោយវាំងននក្រណាត់ទៅដាស់ប្ដីគាត់ដែលកំពុងតែសម្រាន្ត ។

បងប្រុសដែលស្ថិតក្នុងវ័យជាងសែសិបឆ្នាំ ស្លៀកខោខ្លី លែងខ្លួនទទេ យកក្រមាមកចងចង្កេះយ៉ាងណែន យកខ្សែគោមួយចង្វាយនិងកាំបិតភ្នោតមួយផង ចុះដើរតម្រង់ទៅមុខផ្ទះដែលមានដើមដូងជាច្រើនដើមដុះជុំក្បែរអណ្ដូងទឹក ។ ក្រោមពន្លឺព្រះច័ន្ទដ៏ស្រទន់ដែលកំពុងតែចាំងរស្មីព្រាកៗតាមចន្លោះស្លឹកដូង ខ្ញុំឃើញគាត់យកខ្សែគោចងផ្លែ ដូងទាំងធ្លាយរួចកាប់សម្រួតថ្នមៗចុះមកក្រោមរហូតដល់ដី ។

មាន់រងាវទៀបភ្លឺល្មម ពេលដែលខ្ញុំបានត្រឡប់មកដល់វត្តវិញ ។ ហូបទឹកដូងរួចមិត្តសាយ សម្ងំដេក ខ្ញុំអង្គុយឱបដៃដោយរងារនឹងខ្យល់ដំនោរលាយឡំដោយទឹកសន្សើមដ៏ត្រជាក់នាពេលព្រឹកព្រលឹម ខ្ញុំអង្គុយស្ដាប់សំឡេងមាន់រងាវតគ្នា ឮសូរល្ហើយៗយ៉ាងពិរោះពីភូមិឃ្លៃ និងភូមិកងសៅក្បែរនោះ ។ ស្អែកឡើង អ៊ឹឈួន ឪពុកមិត្តសាយ អ៊ឹប៉ែន ជាម្ដាយ បងសៃ ជាបងប្រុស បងតាំង ជាបងស្រី និងប្ដីគាត់ ឈ្មោះបងឈុំ ឧស្សាហ៍ផ្លាស់ប្ដូរគ្នាទៅមកសួរសុខទុក្ខ និងយកបាយទឹកម្ហូបចំណីមកឲ្យមិត្តសាយ ដល់មន្ទីរពេទ្យ ។ តាំងពីថ្ងៃមកដល់មន្ទីរពេទ្យជំបូងមិត្តសាយ មិនដែលហូបរបបពេទ្យដូចអ្នកជំងឺផ្សេងទៀតឡើយ ។

មួយសប្ដាហ៍ក្រោយមក មិត្តសាយ ក៏បានជាសះស្បើយឡើងវិញ ។ មិត្តសាយ ត្រូវសម្រាកនៅភូមិមួយរយៈសិន ខ្ញុំក៏គាត់មិនទាន់ឲ្យទៅការដ្ឋានទំនប់១មករាវិញភ្លាមៗដែរ ។ មួយរយៈពេលដែលខ្ញុំនៅភូមិជាមួយគាត់នោះ ឪពុកម្ដាយបងប្អូនប្រុសស្រីទាំងអស់គ្នាក្នុងគ្រួសាររបស់មិត្តសាយ បានបង្ហាញនូវសណ្ដានចិត្តអាណិតស្រឡាញ់រាប់អានចំពោះរូបខ្ញុំ ជាពិសេសមិត្តសាយ ផ្ទាល់ បាននិយាយ ប្រាប់ខ្ញុំចំពោះមុខឪពុកម្ដាយ និងបងប្អូនគាត់ ថាៈ «បើមិត្តឯងឈឺថ្កាត់អី មិត្តឯងមកសម្រាកនៅនឹងផ្ទះខ្ញុំចុះ ទីនេះមានពុកម៉ែ និងបងប្អូនខ្ញុំជួយមើលថែទាំ ម្យ៉ាង ដើម្បីឲ្យពួកខ្ញុំបានសងគុណមិត្តឯងវិញផង» ។

ថ្ងៃមួយអ៊ឹឈួន ឪពុកមិត្តសាយ បាននាំខ្ញុំទៅហូបបាយថ្ងៃត្រង់នៅរោងបាយរួមដែលមានបងតាំង ធ្វើជាចុងភៅនៅទីនោះផង ។ ដោយមនុស្សច្រើនពេក ព្រោះវេនអ្នកដែលត្រូវហូបមុនមិនទាន់ចប់សព្វគ្រប់ គាត់ក៏បាននាំខ្ញុំទៅអង្គុយរង់ចាំនៅជ្រុងម្ខាង ដែលមានវត្តមានប្ដីម៉ែឡាញ់ និងចាស់ៗមួយចំនួនទៀត ។

ក្នុងចំណោមអ្នកភូមិជាច្រើននាក់ ស្រាប់តែអ៊ឹឈួនផ្ទុះសំណើច

ហើយពេលដែលគាត់ចាប់ផ្ដើមនិយាយ ហាក់ដូចជានិយាយមកកាន់រូបខ្ញុំ គាត់ថាៈ «អាក្មួយឯងដឹងទេ រួមហ្នឹងបានគេហៅរួមពិតមែន!» ។ អឹឈ្លួន បន្អង់បន្តិច គាត់បឺតបារីស្លឹកសង្កែដែលកំពុងតែបៀមជាប់នៅនឹងមាត់មួយដង្ហើមយ៉ាងវែង រួចគាត់យកដៃទៅកាន់បង្វិលបារីមួយជុំពីរ ហើយងើយបន្ហុយផ្សែងយ៉ាងត្រគោលទៅលើ គាត់បាននិយាយបន្តទៀតថាៈ «កាលពីបើករោងបាយហូបរួមដំបូង ម្នាក់ៗមិនខ្វះទេសុទ្ធតែហូបនឹងចានថ្ម ចានបញ្ចុរុក្ក ហើយកែវទឹក មានដឹកគ្រប់ដៃតែមិនទាន់បានប៉ុន្មានផង ឥឡូវនេះបើអាក្មួយឯងមិនកាន់ត្រឡោកមកពីផ្ទះទេនោះ មិនដឹងជាបានស្អីដឹកទឹកទេ! អា ហ្នឹងបានចំជារួមពិតមែន!»

ខ្ញុំបានត្រឡប់មកទំនប់ទឹក១មករាវិញ មួយសប្ដាហ៍ក្រោយមកមិត្តសាយ ក៏បានត្រឡប់មកការដ្ឋានវិញដែរ ។ ពេលនោះជំងឺអាសន្នរោគបាន និងកំពុងតែរាតត្បាតយ៉ាងខ្លាំងក្លា មុខសញ្ញាអ្នកស្រុកតាំងក្រសោមានស្លាប់ដោយ ជំងឺអាសន្នរោគច្រើនជាងគេ ។ នៅតាមរោងបាយនានា ដោយមេឃកាន់តែក្ដៅខ្លាំងកើតមូស កើតរុយកាន់តែច្រើន រុយរោមបានឡើងខ្មៅ ក្នុងខ្ទះសម្លឃើញមានរុយអណ្ដែតពាសពេញ ។

មួយសប្ដាហ៍ក្រោយមកទៀត មិត្តជន អនុប្រធានវរៈទី១ ចាប់ផ្ដើមក្អួតផង ចុះរាគផង ខ្ញុំនឹកគិតម្នាក់ឯង ក្នុងចិត្តថា «ផុតពីប្រជាជនចូលដល់វេនអនុប្រធានម្ដង» ។ ដោយជំងឺរបស់មិត្តជនហាក់ដូចជាមិនបានធូរស្រាលសោះ ម្យ៉ាងគ្មានថ្នាំសង្កូវសម្រាប់ព្យាបាលផង មិនហ៊ានបន្អង់ទៀតឡើយ នៅថ្ងៃបន្ទាប់ខ្ញុំក៏ត្រូវបានគេចាត់តាំង ឲ្យសែងមិត្តជន មកមន្ទីរពេទ្យទាំងយប់ទៀត ។

មុនពេលចេញដំណើរមិត្តសាយ បានហៅខ្ញុំទៅខ្សឹបប្រាប់ថាៈ «មិត្តឯងនៅកំដរមិត្តជនផង ចាំដល់ពេលមិត្តជន បានជាសះស្បើយសឹមមិត្តឯងវិលត្រឡប់មកការដ្ឋានវិញ» ។ មិត្តជន ជាអ្នកភូមិឃ្លៃ តាំងពីថ្ងៃដំបូងដែលគាត់បានមកសម្រាកនៅមន្ទីរពេទ្យភូមិភាគនេះ គាត់ក៏ដូចជាមិត្តសាយដែរ គឺមិនដែលហូបរបបមន្ទីរពេទ្យឡើយ ដោយភូមិឃ្លៃនៅជិតបង្កើយ ខ្ញុំត្រូវដើរទៅមកដើម្បីយកបាយសម្លដែលម្ដាយគាត់បានដាំស្លទុកឲ្យ ។

ផ្ទះមិត្តជន ស្ថិតនៅកណ្ដាលភូមិ ហួសពីផ្ទះតាឃី គ្រូខ្មែរបន្តិច រំលងមួយផ្ទះពីនោះគឺផ្ទះមិត្តស្រស់ ដែលជាញឹកញយ ខ្ញុំបានឃើញម្ដាយមិត្តស្រស់អង្គុយនៅនឹងកណ្ដាលផ្ទះតែម្នាក់ឯងយ៉ាងត្រម៉ង់ត្រមោចក្រោយពីពេលដែលអង្គការយកមិត្តស្រស់ដែលជាកូនតែមួយគត់របស់គាត់យកទៅសម្លាប់ចោលទៅ ។ មិត្តជន មានបងប្អូនបង្កើតបីនាក់ គាត់ជាកូនប្រុសច្បងដែលពីមុនពេលសង្គ្រាមធ្លាប់បានរៀនសូត្រដល់ថ្នាក់មធ្យមសិក្សាបឋមភូមិដូចមិត្តសាយ និងមិត្តប៉ាចដែរ ។ ប្អូនស្រីតែមួយរបស់មិត្តជន ឈ្មោះ សាវិន មានអាយុប្រហែល១៧ឆ្នាំ សម្បុរស្រអែមស្រស់ មានបុកពារយ៉ាងសុភាពរាបសារ ដែលទើបតែនឹងបានរំសាយពីអង្គភាពកាត់ដេរកងទ័ពត្រឡប់មកនៅភូមិវិញថ្មីៗ ។ ប្អូនប្រុសពៅរបស់មិត្តជន ឈ្មោះសាឡុន ម្ដាយមិត្តជន ខ្ញុំមិនបានចាំឈ្មោះគាត់ទេ មានអាយុប្រហែលជាង៥០ឆ្នាំ ប្រហាក់ប្រហែលនឹងវ័យចំណាស់របស់ប្ដីគាត់ដែរឈ្មោះតាឡៅ ។ ក្រោយពីសម្រាកព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេលពីរសប្ដាហ៍ មិត្តជន ក៏បានជាសះស្បើយឡើងវិញ ។ ចេញពីមន្ទីរពេទ្យគាត់បាននាំខ្ញុំមកសម្រាកនៅភូមិបានតែមួយយប់ទេ គាត់ក៏នាំខ្ញុំមកការដ្ឋានទំនប់១មករាវិញ ព្រោះសភាពការណ៍ក្នុងភូមិក៏ដូចជាក្នុងឃុំទាំងមូលមានសភាពមិនស្រួលសោះ ។

ពេលដែលយើងមកដល់ទំនប់១មករាវិញ ការដ្ឋានកំពុងតែរៀបចំរំសាយជាបណ្ដើរៗហើយ ។ កម្លាំងដែលមកពីតំបន់នានាឆ្ងាយៗ ត្រូវបានអង្គការរំសាយឲ្យវិលត្រឡប់ទៅភូមិស្រុកវិញ ដោយរក្សាទុកតែកម្លាំងមួយចំនួននៃស្រុកសន្ទុក ដែលនឹងត្រូវទៅបន្តជីកប្រឡាយនៅការដ្ឋាម៦មករាក្នុងឃុំកកោះវិញ ។

ដំណឹងដែលពួកយោធាបានទៅចាប់ខ្លួនអាសាឡុន ពីផ្ទះយកទៅធ្វើទារុណកម្មវាយសួរចម្លើយក្នុងគុកវត្តជីនិត បានលេចឮមកដល់ពួកខ្ញុំនៅឯការដ្ឋាន ។ មិត្តជន មានទឹកមុខយ៉ាងស្រពាប់ស្រពោនខ្វាយខ្វល់ រំលងមួយថ្ងៃបន្ទាប់មកទៀត ស្រាប់តែលេចឮដំណឹងដ៏សែនស្លុតរន្ធត់ដែលពុំមាននរណាម្នាក់នឹកស្មានដល់មកថា បងហឿង បានចងកសម្លាប់ខ្លួននៅនឹងរោងកង់ភ្ជួរឯត្បែងកោង ស្លាប់បាត់ទៅហើយ ។ ដំណឹងចុងក្រោយនេះធ្វើឲ្យខ្ញុំសែនស្រយុតស្រយង់ក្នុងចិត្ត ខ្ញុំនឹកអាណិតសោកស្ដាយរូបគាត់ ដែលខ្ញុំធ្លាប់បានចាត់ទុកគាត់ថាជាមនុស្សម្នាក់ដ៏ល្អបំផុតក្នុងមួយជីវិតខ្ញុំនេះ ។

**(តទៅលេខក្រោយ)**

**ប៉ុក ប៉ុនសូម៉ាង**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 192, 2015 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.